ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការថែរក្សាប្រវត្តិសាស្ត្រជាប្រភពធនធានជាតិដ៏សំខាន់ រួមជាមួយទីតាំង
- មគ្គុទ្ទេសក៍ទេសចរណ៍ទទួលចំណេះដឹងពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២១៩ ខែមីនា ឆ្នាំ២០១៨

ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២១៩ ខែមីនា ឆ្នាំ២០១៨

## មាតិកា

◆ ការថែរក្សាប្រវត្តិសាស្ត្រជាប្រភពធនធានជាតិដ៏សំខាន់ ........................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ គឹម យន ហៅ ភាព មន្ទីរពិសោធន៍ធ្វើថ្នាំ .............៦

◆ ចម្លើយសារភាពរបស់ចារនារី ផ្សៀង ធីសាង ទាក់ទងប្រវត្តិរូប ............១២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជា..........១៥

◆ ជីវិតតស៊ូក្នុងសម័យខ្មែរក្រហម..................................................២២

◆ សារី សយ ត្រូវចាប់ខ្លួនបន្ទាប់ពីជម្លោះរវាង ប៉ុល ពត និង តាម៉ុក ......២៤

◆ អតីតកម្មាភិបាលភូមិភាគកណ្តាលបានមករស់នៅអន្លង់វែង ................២៨

◆ ភូមិទួលសាលាដែល ហែម ឃិន មករស់នៅដំបូង ...........................៣០

◆ អតីតកម្មកររោងចក្រកាត់ដេរក្លាយជាប្រធានភូមិថ្នល់កែង .................៣៣

**ផ្នែកច្បាប់**

◆ អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការបិទបញ្ចប់.......៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ មគ្គុទ្ទេសក៍ទេសចរណ៍ទទួលចំណេះដឹងអំពីតំបន់ប្រវត្តិសាស្ត្រ...........៤២

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ..............................៤៨

◆ ព្រលឹងមាសម្តាយ ...........................................................៥៤

◆ ដំណឹងស្វែងរកម្តាយមីងដែលបាត់ខ្លួន៦០ ...............................៦០



សុន សេន

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១៣ម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ កែវ សុភី, សុខ វណ្ណៈ, ស៊ិន សុធីតា, ចៅ ព្រហស្បតិ៍, រ៉ូនិត អារី, សើ សាយប្រាណា, ស សារិន, អ៊ុង វណ្ណា, ហេង្វែន គ្រាន ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ ឆេង វ៉េង, ហូ ថុនា, ដារ៉ារដ្ឋ មេត្តា ***អ្នកបកប្រែ*** ៖ ម៉ែន ខឿន និង យូ វលក្ខណ៍ ***និពន្ធនាយកទូទៅ*** ៖ ឆាំង យុ ***ជំនួយការនិពន្ធនាយក*** ៖ សោម ប៊ុនថន, ឡុង ដានី ***ក្រាហ្វិកកុំព្យូទ័រ*** ៖ សោម ប៊ុនថន ***គ្រប់គ្រងការចែកផ្សាយ*** ៖ សន ល័ក្ខ **Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, khmerrougehistory.org www.truthcambodia.com**

# ការថែរក្សាប្រវត្តិសាស្ត្រដើម្បីធ្វើជាប្រភពធនធានជាតិដ៏សំខាន់របស់ប្រទេស ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ

ដូចគ្នាទៅនឹងប្រភពធនធានផ្សេងៗទៀត ប្រវត្តិសាស្ត្រត្រូវតែមានការការការពារ និងថែរក្សា ។ ការមិនយកចិត្តទុកដាក់ និងការព្រងើយកន្តើយ ក៏ដូចជាការបំផ្លាញដោយចេតនា អាចធ្វើឲ្យយុវជនជំនាន់ក្រោយបាត់បង់ឱកាសសិក្សាស្វែងយល់ពីវត្ថុបុរាណ និងទីតាំងប្រវត្តិសាស្ត្រនានា ។

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដែលបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងទេសចរណ៍ កំពុងខិតខំព្យាយាមធ្វើការដើម្បីថែរក្សាប្រវត្តិសាស្ត្រកម្ពុជាតាមរយៈការធ្វើកំណត់សម្គាល់ទីតាំងប្រវត្តិសាស្ត្រដែលប្រឈមនឹងការបំផ្លិចបំផ្លាញ និងភាពសឹករេចរឹល ។ នៅក្នុងដំណើរទស្សនកិច្ចថ្មីៗ ក្រុមការងារបានប្រទះឃើញ ក្រុមហ៊ុនសាងសង់ផ្លូវបានចាក់ដីលុបលើទីតាំងបូជាសពរបស់ សុន សេន និងក្រុមគ្រួសារដោយអចេតនា ។

ទីតាំងបូជាសពរបស់ សុន សេន មានទីតាំងស្ថិតនៅជាប់នឹងផ្លូវលំមួយ ក្នុងឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ទីតាំងនេះ គឺជាទីតាំងប្រវត្តិសាស្ត្រមួយក្នុងចំណោមទីតាំងប្រវត្តិសាស្ត្រទាំង១៨កន្លែង នៅក្នុងស្រុកអន្លង់វែង ។ ដើម្បីស្តារទីតាំងនេះឡើងវិញ និងការពារទីតាំងនេះពីការខូចខាត ក្រុមការងារបានកាយដីដែលកប់លើទីតាំងប្រវត្តិសាស្ត្រមួយនេះ ហើយដាំបង្គោល និងព័ទ្ធខ្សែលួសជុំវិញដើម្បីដៅ ព្រមទាំងការពារទីតាំងនេះសម្រាប់ពេលអនាគត ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**



អ្នកបើកបរកំពុងបញ្ឈប់ត្រាក់ទ័រឈូសដីចេញពីកន្លែងបូជាសពរបស់ សុន សេន អតីតរដ្ឋមន្ត្រីការពារជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ដែលក្រុមហ៊ុនសាងសង់ផ្លូវបានចាក់ដីលុប ។

# ទីកន្លែងបូជាសព សុន សេន ក្នុងឃុំត្រពាំ









# ងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ














ANLONG VENG PEACE CENTER
TRANSIT




LONG VENG PEAC CENTER

# ចម្លើយសារភាពរបស់ គីម យន ហៅ ភាព មន្ទីរពិសោធធ្វើថ្នាំពេទ្យព-៣១

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព J០០០៤២***

គីម យន ហៅ ភាព ជាអ្នកទោសនារីម្នាក់ កើតនៅភូមិសំបួរ ឃុំត្បូងក្រពើ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ឪពុករបស់ ភាព ឈ្មោះ គូ ជា ធ្វើស្រែ និងម្តាយឈ្មោះ ភឿក (ស្លាប់) ។ ភាព មានបងប្អូនចំនួន៥នាក់ ប្រុស៤នាក់ និងស្រី១នាក់ ។ ក្នុងរបបខ្មែរក្រហម ភាព បម្រើការងារនៅមន្ទីរពិសោធធ្វើថ្នាំពេទ្យព-៣១ និងត្រូវខ្មែរក្រហមចាប់ខ្លួនពីបទបម្រើសកម្មភាពឲ្យខ្មាំង ក្បត់នឹងបដិវត្តន៍ និងបានបញ្ជូនមកមន្ទីរស-២១ ដើម្បីសួរចម្លើយ ។ ចម្លើយសារភាពរបស់ ភាព មានចំនួន៣២ទំព័រ សួរដោយឈ្មោះ សុង និងចម្លងចេញពីខ្សែអាត់ដោយឈ្មោះ ស៊ីន ។ តាមរយៈចម្លើយសារភាពបានបញ្ជាក់ឲ្យដឹងថា ភាព គឺជានារីដែលមានអត្តចរិកបុគ្គលក្រាស់ ម៉ិកម៉ក់ ចូលចិត្តសប្បាយភ្លើតភ្លើន និងចចេសរឹងរូស ។ ខាងក្រោមនេះ ជាប្រវត្តិរឿងរ៉ាវផ្សេងៗដែលកើតមានឡើងនៅក្នុងខ្សែជីវិតរបស់ ភាព ចាប់តាំងពីចូលបម្រើការងារក្នុងជួរបដិវត្តន៍ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន៖

ភាព បានចូលបម្រើបដិវត្តន៍នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៣ ។ ខណៈពេលធ្វើការនៅក្នុងអង្គភាពមន្ទីរពិសោធធ្វើថ្នាំពេទ្យព-៣១ ត្រូវបានឈ្មោះ អ៊ុំ ម៉ុល ហៅ ថន ធ្វើការអូសទាញឲ្យចូលបម្រើក្នុងសកម្មភាពក្បត់បដិវត្តន៍ដោយប្រើមនោសញ្ចេតនាភាពស្និទ្ធស្នាល ការរាប់អានជិតស្និទ្ធ ។ ពាក្យសំដី និងអាកប្បកិរិយាទន់ភ្លន់ ផ្អែមល្ហែមទាំងប៉ុន្មានខាងលើបានធ្វើឲ្យ ភាព ស្រឡាញ់ទុកចិត្ត



ពេទ្យបដិវត្តន៍របស់អង្គការកំពុងផលិតថ្នាំពេទ្យបុរាណសម្រាប់ព្យាបាលអ្នកជំងឺ

ជឿជាក់ទាំងស្រុងទៅលើ ថន ដែលជាមេដឹកនាំក្បត់នៅក្នុងមន្ទីរពេទ្យព-៣១ ។ ដោយយល់ថា ភាព ជឿជាក់មកលើខ្លួនទាំងស្រុង ហើយ ថន ក៏បានប្រគល់នារី ភាព ឲ្យទៅឈ្មោះ ណាង ដែលជាបក្ខពួករបស់ខ្លួនគ្រប់គ្រងដោយផ្ទាល់ ។ ជាបន្តបន្ទាប់ ថន តែងផ្តល់ជារបស់របរសម្ភារមកឲ្យ ភាព តាមរយៈឈ្មោះ ណាង មានដូចជា សាប៊ូ សារុងពុម្ព ក្រណាត់គេតារុងពណ៌ខ្មៅ និងអាវក្នុងជាដើម ។ ពេលយកសម្ភារមកឲ្យ ភាព ណាង បាននិយាយថា «នេះជាសម្ភារដែលអង្គការផ្តល់ឲ្យមិត្ត ក្នុងគុណបំណាច់ដែលមិត្តបានលះបង់អ្វីៗទាំងអស់ដោយប្តេជ្ញាខ្ពស់ចំពោះអង្គការ ។ ឥឡូវនេះ មិត្តនៅក្រោមការដឹកនាំរបស់ខ្ញុំ មិត្តត្រូវគោរពតាមបទបញ្ជារបស់ខ្ញុំ ហើយនិងគោរពបង ថន ផង» ។

ជាបន្តបន្ទាប់ ក្នុងការស្នងថ្នាំពេទ្យ ណាង បានយក ភាព ធ្វើការជាមួយខ្លួនជាប់តែពីរនាក់ ទាំងការលាយថ្នាំ និងធ្វើការផ្សារផ្សេងៗទៀត ។ ថ្ងៃមួយ ពេលធ្វើការលាយសេរ៉ូមស្ងាត់តែពីរនាក់ ណាង បាននិយាយប្រាប់ ភាព ថា «អង្គការបានប្រគល់ភារកិច្ចធំមួយមកឲ្យខ្ញុំទទួលខុសត្រូវ តែមុននឹងប្រគល់ការងារឲ្យធ្វើ ខ្ញុំត្រូវលែងប្រពន្ធឈ្មោះ ណាត សិន ព្រោះ ណាត ជាកូនចិនមកពីកំពង់ចាម» ។ ភាព បានសួរ ណាង វិញថា «បើបងលែងប្រពន្ធ តើបងយកនរណាវិញ?» ។ ណាង បានឆ្លើយប្រាប់ ភាព វិញថា ខ្លួនយកអ្នកដែលនៅជិតៗនេះ ព្រោះបានស្នើអង្គការរួចហើយ ។ ចាប់តាំងពីពេលនោះមក ភាព មិនសូវហ៊ានមើលមុខ ណាង ចំទេ ព្រោះមានចិត្តអៀននឹង ណាង តែចូលចិត្តនិយាយលេងជាមួយគ្នាស្និទ្ធស្នាល ។ ក្រោយមក ពេលចូលធ្វើការលាយសេរ៉ូម ណាង បានហៅ ភាព ឲ្យមកធ្វើការជាមួយ ហើយបានបិទទ្វារដោយចងខ្សែលួសពីខាងក្នុងផង ។ បន្ទាប់មក ណាង ចាក់ស្រាផឹក ហើយបានហុចសៀវភៅរឿងមួយក្បាលឲ្យទៅ ភាព ដោយបាននិយាយថា ជាឯកសាររបស់បង ថន ផ្ញើឲ្យហើយបានស្នើឲ្យ ភាព អានឲ្យខ្លួនស្តាប់ ។ ភាព ក៏បានទទួលសៀវភៅប្រលោមលោករឿង «បងស្រឡាញ់តែអូនមួយនាក់» មកអាន តែអានរដិបរដុបព្រោះមិនសូវចេះអក្សរ ។ ពេលនោះ ណាង បានហុចកែវស្រាឲ្យទៅនារី ភាព ដោយបាននិយាយថា មិត្តហូបថ្នាំនេះសិនទៅទើបមើលអក្សរដាច់ ។ ភាព បានផឹកស្រាដែល ណាង ឲ្យអស់កន្លះកែវ រួចហើយក៏អានបន្តទៀត ។ ពេលស្រាចូលក្នុងខ្លួនភ្លាមបានធ្វើឲ្យ ភាព ទន់ដៃទន់ជើង និងបើកភ្នែកលែងរួច ។ ភ្លាមនោះ ណាង ក៏បានចាប់រំលោភលើរាងកាយរបស់ ភាព រហូតបានសម្រេចតាមបំណង ។ បន្ទាប់មក ណាង បានឲ្យថ្នាំពីរគ្រាប់ទៅនារី ភាព លេប ហើយបាននិយាយថា «មិត្តត្រូវលាក់ការណ៍ឲ្យមែនទែន ព្រោះនេះជាបទបញ្ជារបស់អង្គការ បើសិនជាបែកការណ៍ គឺមិត្តត្រូវស្លាប់ ព្រោះកងពលបញ្ជាមកដាច់ខាត» ។ នៅថ្ងៃដដែលនោះដែរ នៅវេលាយប់ ថន បានមកជួប ណាង ប្រហែលមួយម៉ោង រួចបានហៅនារី ភាព មកធ្វើការអប់រំថា «មិត្តមានជំហរលះបង់ខ្ពស់ណាស់ តទៅមុខទៀត មិត្តត្រូវលះបង់ឲ្យរឹតតែដាច់ខាតតទៅទៀត ហើយបើមិត្តដឹងរឿងអី ស្នើមិត្តស្ងាត់បំផុត (រក្សាការសម្ងាត់) បើមិត្តធ្វើតាមការណែនាំនេះ មិត្តនឹងមានអនាគតភ្លឺស្វាង ត្រចេះត្រចង់ ។ នារី ភាព បានសួរទៅ ថន ថា «តើបងឲ្យខ្ញុំលះបង់យ៉ាងម៉េច?» ថន បានតបវិញថា «គឺដូចមិត្តបានអនុវត្តហើយ ។ ថន និយាយបានត្រឹមនេះក៏សើចដាក់នារី ភាព នារី ភាព ក៏រត់គេចចេញទៅ» ។

ចាប់តាំងពីពេលនោះមក នារី ភាព បានលង់ខ្លួនតាមឈ្មោះ ណាង ។ ក្រោយមក ប្រពន្ធរបស់ ណាង ឈឺ ពេលនោះ ណាង ក៏បានណែនាំឲ្យនារី ភាព លាយសេរ៉ូមយកទៅចាក់ឲ្យប្រពន្ធរបស់ខ្លួន ។ ពេលព្យួរសេរ៉ូមបានតែប្រាំនាទី ណាត ក៏ប្រកាច់ ។ នារី ភាព បានរត់មកប្រាប់ ណាង ហើយ ណាង បានប្រាប់ថា «សេរ៉ូមហ្នឹង ពេលព្យួរទៅប្រកាច់អ៊ីចឹងទើបបានជា» ។ នារី ភាព បានវិលមកកន្លែងអ្នកជំងឺវិញ ពេលនោះ ភាព បានឃើញឈ្មោះ ឡយ កំពុងតែដោះសេរ៉ូមចេញពី ណាត ហើយបាននិយាយមកកាន់ ភាព ថា «សេរ៉ូមនេះទុកសម្រាប់ចាក់តែកម្មាភិបាលពិសេសៗទេ ដូចមិត្ត ណាត មិនត្រូវចាក់សេរ៉ូមនេះឲ្យទេ» ។ បន្ទាប់មក ឡយ បានយកថ្នាំមកចាក់ឲ្យមិត្ត ណាត ទើប ណាត ក៏លែងប្រកាច់ ហើយអ្នកទាំងពីរក៏បែកគ្នាទៅ ។

រៀងរាល់ថ្ងៃ ណាង តែងអប់រំនារី ភាព ឲ្យរក្សាការណ៍សម្ងាត់ និងលាក់ការណ៍ឲ្យជាប់ បើបែកការណ៍សម្ងាត់គឺត្រូវស្លាប់ ។ ចាប់តាំងពីនារី ភាព បានខូចសីលធម៌ជាមួយ ណាង មក ភាព ស្រឡាញ់ ណាង កាន់តែខ្លាំងឡើងៗ រហូតដល់លួចលបមើល ណាង ធ្វើគ្រប់សកម្មភាព រហូតដល់មានគំនិតចង់សម្លាប់ប្រពន្ធរបស់ ណាង ទៀត



មន្ទីរពេទ្យនៅក្នុងអំឡុងរបបខ្មែរក្រហម

តែមិនទាន់បានធ្វើសកម្មភាពនៅឡើយទេ ។ ក្រោយមក ណាង បានទាក់ទងជាមួយនារី ស្រុីម និងបានខូចសីលធម៌ជាមួយគ្នាទៀត ដោយនារី ភាព បានឃើញផ្ទាល់នឹងភ្នែក ។ ចាប់តាំងពីពេលនោះមក នារី ភាព ខឹងនឹង ណាង យ៉ាងខ្លាំងដោយ ណាង ក្បត់នឹងពាក្យសន្យារបស់ខ្លួន ។ នារី ភាព ហាក់មានការអស់សង្ឃឹមចំពោះ ណាង ហើយក៏បានរាយការណ៍ពីសកម្មភាពរបស់ ណាង ដែលបាននាំមនុស្សចម្លែកចូលក្នុងមន្ទីរពិសោធជូនអង្គការ ។ ពេលបន្ទាប់មក ថន បានហៅនារី ភាព ទៅសម្ភុតនៅផ្ទះស្ថិតនៅជិតផ្លូវប្រជាធិបតេយ្យ ហើយបានធ្វើការអប់រំនារី ភាព បន្ថែមទៀត ។ ចាប់ពីពេលនោះមក នារី ភាព ក៏លែងរាយការណ៍ពីរឿងអ្វីទាំងអស់ជូនអង្គការ និងបានអនុវត្តសកម្មភាពក្បត់តាមបញ្ជារបស់ ថន តទៅទៀត ។

ខែតុលា ឆ្នាំ១៩៧៦ ថន បានមកជួបនារី ភាព នៅម៉ោង៤ល្ងាច និងបានឲ្យនារី ភាព បំពេញភារកិច្ចសំខាន់នៅក្នុងយប់នេះ ។ ពេលហូបបាយល្ងាចរួច នៅវេលាម៉ោង៦យប់ ណាង បានហៅនារី ភាព និងអ្នកឯទៀតមានឈ្មោះ ថុន, ស្រុីម, រីម រួមនឹងយុវជនមួយចំនួនមានយុវជនឈ្មោះ ទុង, ឡយ, ចិត្ត, ដែន, គ្រាច, គុន មកប្រជុំដោយបាននិយាយថា យប់នេះបង ថន ធ្វើការងារពិសេសដោយយកមន្ទីរពិសោធធ្វើជាកន្លែងប្រជុំ ដូច្នេះយើងត្រូវចែកភារកិច្ចគ្នាអនុវត្ត ដើម្បីការពារអង្គការពេលមកប្រជុំនៅកន្លែងយើងឲ្យមានសុវត្ថិភាព ។ ណាង និង គុន ចូលរួមប្រជុំជាមួយអង្គការ ឯអ្នកទទួលខុសត្រូវរួមខាងក្រៅគឺឈ្មោះ ដែន (មកពីខាងតេអូកងពល) ។ ទុង និង ឡយ ត្រូវយកខ្សែភ្លើងព័ទ្ធជុំវិញមន្ទីរពិសោធ ហើយខ្សែភ្លើងត្រូវតដាក់ជាប់នឹងរបងលួសនៅជុំវិញមន្ទីរពិសោធ បើមានមនុស្សចង់ចូល ក៏ចូលមិនរួចដែរ ។ ចិត្ត និង គ្រាច ត្រូវនៅយាមចាំមើលក្រែងមានសភាពប្លែកនៅមន្ទីរពេទ្យ ឬមានមិត្តយើងមករកបង ថន ត្រូវប្រាប់មកបង ដែន ភ្លាម ។ នារី រីម និងនារី ថុន ទទួលភារកិច្ចនៅក្នុងកន្លែងប្រជុំ ។ ចំណែកនារី ស្រុីម ទទួលនាទីខាងផ្នែកដាំបាយសម្រាប់មនុស្សចំនួន១០នាក់ ដោយឈ្មោះ គ្រាច ជាអ្នកផ្តល់អង្ករឲ្យ និងបន្លែសាច់ឈ្មោះ ហេង ជាអ្នកផ្តល់ឲ្យ ។ ឯនារី ភាព និងនារី ខាវ ជាអ្នកយាមនៅទ្វារខាងមុខចាំទទួលភ្ញៀវ និងអង្គការមកប្រជុំ ។ បន្ទាប់ពី ណាង មានមតិចប់ ទាំងអស់គ្នាក៏បានបំបែកគ្នាទៅធ្វើការងាររៀងៗខ្លួន ។

ម៉ោងប្រហែលជា១១យប់ ឈ្មោះ ថន, ដេន, នីន បានមកដល់មន្ទីរពិសោធមុនគេ បន្ទាប់មកមានឈ្មោះ ជាតិ ឈ្មោះ ធិន ពេទ្យស្រុកព្រៃឈរ គីម គណៈស្រុកព្រៃឈរ ភីន (ធ្វើពេទ្យនៅជាមួយឈ្មោះ ធិន) ហឿន នៅពាណិជ្ជកម្មក្បែរផ្សារថ្មី ។ លុះម៉ោងប្រហែលជា១២យប់ ដែន បានយកម៉ូតូមកឲ្យ ថន ហើយ ធិន ក៏យកម៉ូតូនោះជិះទៅបាត់ កន្លះម៉ោងក្រោយមក ទើបឃើញត្រឡប់មកវិញដោយមានឌុបមនុស្សម្នាក់ពាក់វ៉ែនតាខ្មៅ សក់ស្កូវតិចៗ សម្បុរខ្មៅ ស្គមខ្ពស់ ស្លៀកពាក់ខោអាវខ្មៅមកជាមួយផង ។ នារី ភាព នារី ខាវ និង ថន បានឱនក្បាល និងចាប់ដៃ ហើយក៏អញ្ជើញមនុស្សចំណូលថ្មីនេះទៅទីកន្លែងប្រជុំបាត់ទៅ ។ ប្រហែលជាម៉ោងពាកន្លះរំលងអាធ្រាត្រ មនុស្សចម្លែកនេះ បានចេញមកវិញ ដោយមាន ធិន, គីម, ថន, ណាង ជូនដំណើរផង ហើយក៏បានចាប់ដៃលាគ្នាទៅវិញដោយឈ្មោះ ថន ជាអ្នកឌុបម៉ូតូជូនបុរសនេះទៅវិញ ។ ក្រោយពេលភ្ញៀវចេញអស់ ណាង បានឲ្យនារី ភាព នារី ខាវ ទៅប្រមូលចានយកទៅលាងសម្អាត ។ នារី ភាព បានសួរ ណាង ថា «បងពាក់វ៉ែនតាខ្មៅឈ្មោះអី?» ណាង បាននិយាយថា «មិត្តកុំអាលចង់ដឹង នេះគឺជាអង្គការរបស់យើង» ។

ខែវិច្ឆិកា ឆ្នាំ១៩៧៦ ណាង បានហៅនារី ភាព ថុន នារី ស្រុីម និងយុវជនឈ្មោះ ទុង, ដែន, ឡយ, ចិត្ត, គ្រាច, គុន មកប្រជុំដោយ ថន ជាប្រធាននៃអង្គប្រជុំ ។ អង្គប្រជុំបានដាក់ផែនការក្បត់ និងចែកភារកិច្ចឲ្យសមាជិកអនុវត្តដូចខាងក្រោម ៖

១) ផ្នែកនារីមាន ភាព, ស្រុីម, ខាវ, រីម ជាអ្នកចលនាអូសទាញកម្មាភិបាលខាងផ្នែកសីលធម៌ ដោយម្នាក់ៗត្រូវលះបង់ឲ្យខ្ពស់ ។

២) ផេន ជាអ្នកចលនាកសាងកម្លាំងពីខាងក្រៅ

៣) ទុង ជាអ្នកក្តាប់សភាពការណ៍ក្នុងមន្ទីរពេទ្យ

៤) ចិត្ត និង ត្រាច ជាអ្នកប្រមូលខាងសេដ្ឋកិច្ច

៥) គាន ជាអ្នកបំផុសយុវជន និងយុវនារីក្នុងមន្ទីរពេទ្យ

៦) ឡយ អ្នកលាយថ្នាំពេទ្យដោយទឹកដុងកៅស៊ូសម្រាប់លាយថ្នាំ ដើម្បីចាក់ទៅមានប្រតិកម្មធ្វើឲ្យខូចដៃជើងកម្មាភិបាល និងយុទ្ធជន បង្កើនការស្អុកស្អាញក្នុងមន្ទីរពេទ្យ ។ ពេលប្រជុំទទួលផែនការហើយក៏បែកគ្នាទៅ ។ ឈ្មោះ ថន បានទាក់ទងទៅខាងខុត្តរជាញឹកញាប់ តែមិនដឹងជាទាក់ទងទៅកន្លែងណាទេ ឯខាងខុត្តរមានឈ្មោះ ឆិន, គីម, ភិន វិញ ក៏តែងមកទាក់ទងជាមួយ ថន ញឹកញាប់ដែរ ដោយពេលខ្លះប្រជុំនៅផ្ទះរបស់ ថន ហើយពេលត្រឡប់ទៅវិញ ថន បានឲ្យមេថ្នាំពេទ្យ និងសម្ភារមួយចំនួនធំដោយលួចលាក់ទៅជាមួយផង ។ ថន បានបំផុសបុគ្គលិកពេទ្យឲ្យធ្វើសកម្មភាពក្បត់ជាមួយខ្លួនបានមួយចំនួនទៀត តែនារី ភាព មិនអាចក្តាប់បាន ។

បន្ទាប់មក ណាង បានទៅវាលវិញជាមួយ ផេង, ទុង, ចិត្ត, សាក់ និងកុមារពីរនាក់ទៀត ។ ណាង បានយកអង្ករពីរបាវ ត្រីងៀតមួយចំនួន ស្រា៥ដប ថ្នាំពេទ្យ និងមេថ្នាំពេទ្យមួយចំនួនធំ និងទឹកកកមួយធុងយកទៅឲ្យឈ្មោះ ហេង មានភារកិច្ចក្តាប់សភាពការណ៍ និងធ្វើសកម្មភាពនៅទល់ដែនខាងសមុទ្រ ។ ណាង ទៅវាលវិញលើកនេះអស់រយៈពេលយូរថ្ងៃទើបត្រឡប់មកវិញ ។ មកដល់ភ្នំពេញ ណាង បានកាន់របស់ចម្លែកមកជាមួយរួចបោះចូលទៅក្នុងបន្ទប់របស់ខ្លួន ។ បន្តិចក្រោយមក ផេន បានមកជួបនឹង ណាង និងបានសំណេះសំណាលគ្នាយ៉ាងយូរ បន្ទាប់មក ផេន បាននិយាយថា «ទៅវាលវិញសប្បាយណាស់ សប្បាយដូចបានចាប់ជាតិជាថ្មី ព្រោះដើរលេងតាមចិត្ត គ្មានអ្នកណាឆែកឆេរទេ» ។ នៅវាលវិញ មានមិត្តមក ពីប្រទេសក្រៅច្រើនណាស់ សុទ្ធតែជាអ្នកចេះដឹងជ្រៅជ្រះ ហើយរាក់ទាក់ដូចបងប្អូនបង្កើតអ៊ីចឹង ។ ចាប់តាំងពីត្រឡប់មកពីវាលវិញវិញ ណាង បានធ្វើសកម្មភាពក្បត់ខ្លាំងឡើងៗ ទាក់ទងពីកន្លែងមួយទៅកន្លែងមួយទៀត រហូតដល់អង្គការចាប់ខ្លួនតែម្តង ។

ក្រោយពេលអង្គការបានចាប់ខ្លួនឈ្មោះ ថន និង ណាង មក ចេវ បានមកដេកពេទ្យ ហើយបានមកសួរនាំនារី ភាព បញ្ជាក់ពីហេតុការណ៍ដែលបណ្តាលឲ្យអង្គការចាប់ខ្លួន ថន និង ណាង រួចហើយ ចេវ ក៏បានណែនាំឲ្យនារី ភាព សរសេរជាលិខិតក្លែងក្លាយមួយដាក់នៅកន្លែងរបស់ខ្លួនការពារខ្លាចអង្គការចាប់ខ្លួន ។ នារី ភាព បានបញ្ជាក់ថា នារី រីម ជាមនុស្សដែលមានកម្មសិទ្ធិក្រាស់ មុខមាត់បុណ្យស័ក្តិ បានខឹងពីរឿងអង្គការដកការងារចុះឡើងៗ ព្រោះធ្លាប់ទទួលនាទីកងធំ តែក្រោយមកត្រូវអង្គការដកចេញវិញ ហើយមិនទាន់ចាត់តាំងច្បាស់លាស់ឲ្យទទួលនាទីវិញនៅឡើយ តែក្រោយមកត្រូវបាន ថនអូសទាញបានដោយបានចាត់តាំងឲ្យទទួលភារកិច្ចបម្រើសកម្មភាពក្បត់គ្រប់ផ្នែក តែដោយឡែកឲ្យទទួលខាងចលនាបំផុសបុរស-នារីឲ្យទាក់ទងគ្នាខាងសីលធម៌ ហើយក្រៅពីនេះ ទទួលភារកិច្ចរៀបចំបាយទឹកពេលមានភ្ញៀវមកជាសម្ងាត់នៅផ្ទះ ថន ពិសេសនៅពេល ឆិន, គីម និង ភីន មក ។ នារី រីម ត្រូវទទួលភារកិច្ចដឹកនាំបក្ខពួកធ្វើសកម្មភាពក្បត់ប្រឆាំងអង្គការបន្ត ក្រោយពី ថន និង ណាង ត្រូវអង្គការចាប់ខ្លួន ។

នៅចុងខែធ្នូឆ្នាំ១៩៧៦ និងដើមខែមករា ឆ្នាំ១៩៧៧ នារី រីម បានណែនាំនារី ភាព ឲ្យបោះខិតបណ្ណប្រឆាំងនឹងអង្គការចំនួនពីរលើកដែលសរសេរដោយនារី ភាព ផ្ទាល់ មានអត្ថន័យថា «ប្តេជ្ញាសម្លាប់ពួកហេងឯងឲ្យទាល់តែបាន» ។ ការធ្វើត្រាក់នេះក្នុងន័យបង្វែងដានចំពោះសកម្មភាពក្បត់របស់ក្រុមខ្លួនកុំឲ្យអង្គការចាប់អារម្មណ៍ ។ នារី រីម បានណែនាំនារី ភាព បន្ថែមថា «មិត្តត្រូវលាក់ការណ៍ឲ្យជិត បើបែកការណ៍គឺត្រូវស្លាប់ តែបើមិត្តហ៊ានរាយការណ៍ឲ្យមិត្ត វន ហើយអង្គការចាប់ខ្ញុំ មិត្តក៏មិនរស់ដែរ ព្រោះបក្ខពួកយើងមានច្រើនណាស់ គេនឹងតាមសម្លាប់មិត្តទាល់តែបាន» ។ ការបោះត្រាក់ នារី រីម ទទួលការណែនាំពី ផេន ដែលត្រូវជាប្តីរបស់ខ្លួនទាំងអស់ ព្រោះ ផេន ក៏មានទំនាស់ជាមួយអង្គការពីរឿងមុខមាត់និងបុណ្យស័ក្តិដែរ ។

នៅក្នុងចម្លើយសារភាពរបស់ ភាព មិនមានសរសេរបញ្ជាក់ពីកាលបរិច្ឆេទនៃការចាប់ខ្លួន ភាព ទេ តែអ្នកចម្លងឯកសារឈ្មោះ ស៊ុន បានសេរសេរថា «ចម្លើយលើកទី១ លើកទី២ របស់ គីម យន ហៅ ភាព (នារី) មន្ទីរពិសោធធ្វើថ្នាំពេទ្យព-៣១ សួរនៅថ្ងៃ២-១-៧៧ និង ថ្ងៃ៤-១-៧៧» ។ តាមការសរសេររបស់ ស៊ុន អាចបញ្ជាក់ថា ឈ្មោះ គីម យន ហៅ ភាព អាចត្រូវបានអង្គការចាប់ខ្លួននៅចុងខែធ្នូឆ្នាំ១៩៧៦ ។ **ឆេង ម៉េង**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ិន សុធីតា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthsothida.s@dccam.org* ។





















# កាលវិភាគបញ្ចាំងខ្សែភាពយន្ត ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា
















*រៀងរាល់ថ្ងៃសុក្រ វេលាម៉ោង ១០ ៖ ០០ ព្រឹក*

*ទីតាំង៖ អគារ H នៃវិទ្យាស្ថានជាតិអប់រំ (មហាវិថីព្រះសីហនុ ភ្នំពេញ)*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖ ស៊ាង ចិន្តា ទូរសព្ទលេខ ៖ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល ៖ truthchenda.s@dccam.org*

# ចម្លើយសារភាពរបស់ចារនារី ង្វៀន ធីសាង ទាក់ទង ប្រវត្តិរូប និងសកម្មភាពឈ្លានពាន

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D០៧១៤៦*



ង្វៀន ធីសាង

ង្វៀន ធីសាង ភេទស្រីមានអាយុ២០ឆ្នាំ មុនឆ្នាំ១៩៧៥ រស់នៅជាមួយឪពុកម្តាយនៅក្នុងទូកមានមុខរបររកស៊ីនេសាទត្រីនៅបឹងទន្លេសាប ក្នុងខេត្តពោធិ៍សាត់ ។ លុះក្រោយឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង ធីសាង និងឪពុកម្តាយបានធ្វើដំណើរទៅប្រទេសវៀតណាមវិញ ដោយរស់នៅក្នុងភូមិកៅឡាញ់ ឃុំភូមី ស្រុកព្រែកថាំងជាង ។ នៅឆ្នាំ១៩៧៨ ធីសាង បានចូលមកក្នុងទឹកដីកម្ពុជាក្នុងនាមជាចារនារីយួនដើម្បីមកយកការណ៍ ក៏ត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៨ នៅស្រុកពាមជរ ខេត្តព្រៃវែង ។ បន្ទាប់មកក៏បានបញ្ជូនខ្លួនមកមន្ទីរ ស-២១ ដើម្បីសួរចម្លើយ ។ ខាងក្រោមនេះជាសេចក្តីរាយការណ៍របស់ ធីសាង ដែលបានសារភាព និងរាយការណ៍ជូនបក្សកុម្មុយនីស្តកម្ពុជា ៖

១) កាលនៅកម្ពុជាឆ្នាំ១៩៧២ ឪពុករបស់ ធីសាង បានធ្វើការជាមួយកងទ័ពរបស់យៀកកុង ការខាងផ្នែកសេដ្ឋកិច្ច ។ កាលណោះ ឪពុក ធីសាង បានប្រាប់ ធីសាង ថា លោក ទី ហាយ បញ្ជាការវរសេនាតូច បានចាត់តាំងខ្លួនឲ្យធ្វើជាភ្នាក់ងារសម្ងាត់ ហើយក្តាប់សភាពការណ៍របស់បដិវត្តន៍កម្ពុជា ។ ការងារជាចំហររបស់ឪពុក ធីសាងគឺធ្វើជាសមាជិកក្រុមសេដ្ឋកិច្ចក្នុងកងទ័ពយៀកកុង ។ ឪពុក ធីសាង បាននិយាយថា សភាពការណ៍បដិវត្តន៍កម្ពុជាបច្ចុប្បន្នអំណោយផលដល់វៀតណាមយើងល្អណាស់ កូនក៏ត្រូវមានភារកិច្ចបម្រើប្រទេសជាតិដែរ ។ សព្វថ្ងៃកងទ័ពវៀតណាមយើងកំពុងចូលមកកាន់កាប់កម្ពុជាជាបណ្តើរៗ ហើយ ក្នុងពេលដែលកម្ពុជាត្រូវចក្រពត្តិអាមេរិកចូលមករាតត្បាតឈ្លានពាននេះ ។ កងទ័ពវៀតណាមយើង ក៏ត្រូវឆកឱកាសយកលេសនេះដើម្បីចូលក្តាប់កម្ពុជាដែរ ។ យើងនៅខាងក្នុងមានភារកិច្ចចាំបាច់រួមកម្លាំងឲ្យមានប្រសិទ្ធភាព គឺត្រូវក្តាប់សភាពការណ៍យោធា និងនយោបាយឲ្យជាប់ ជាពិសេសមាគ៌ាបក្សកុម្មុយនីស្តកម្ពុជា ដើម្បីយើងងាយរំលំបក្សកុម្មុយនីស្តកម្ពុជា ក្នុងពេលដែលយើងវាយឈ្នះចក្រពត្តិអាមេរិកនៅវៀតណាមខាងត្បូង ។ ទន្ទឹមនឹងនេះដែរ យើងត្រូវឈានទៅក្តាប់កម្ពុជាឲ្យបានជាបណ្តើរៗ ព្រោះអនាគតរបស់វៀតណាមយើង ត្រូវយកកម្ពុជាឲ្យចូលក្នុងសហព័ន្ធឥណ្ឌូចិន ដែលមានវៀតណាមយើងជាអ្នកដឹកនាំ ជាអ្នកចាត់តាំងរដ្ឋអំណាច ។ ប៉ុន្តែតែកាលណោះ ធីសាង មិនទាន់យល់ជ្រាបពីមាគ៌ានយោបាយបក្សកុម្មុយនីស្តឥណ្ឌូចិន និងគោលគំនិតសហព័ន្ធឥណ្ឌូចិនក៏ដោយ ក៏ ធីសាង ខិតខំក្តាប់សភាពការណ៍បដិវត្តន៍កម្ពុជាបានសកម្មគួរសមដែរ ។ ប៉ុន្តែពេលនោះ ធីសាង យល់ត្រឹមតែស្រឡាញ់ជាតិសាសន៍យួនដូចគ្នា និងចង់ឲ្យជាតិសាសន៍របស់ខ្លួនទៅអនាគតឡើងជាម្ចាស់កម្ពុជា ម្ចាស់ឥណ្ឌូចិនក៏ដោយ ក៏ ធីសាង មានការរំភើបរីករាយ ស្ម័គ្រចិត្តបំពេញភារកិច្ចនេះដោយឥតរួញរាអ្វីបន្តិចសោះឡើយ ។

ប្រហែលជាខែតុលា ឆ្នាំ១៩៧២ ឪពុក ធីសាង បានខទ្មេសនាមឲ្យ ធីសាង ទាក់ទងផ្ទាល់ជាមួយគណៈបញ្ជាការវរសេនាតូច

ទីហាយ តែម្តង ។ ទីហាយ បានប្រាប់ ធីសាង ថា អ្នកឯងត្រូវខិតខំធ្វើការងារឲ្យបានល្អ អនាគតដ៏ខ្លីខាងមុខនេះ វៀតណាមយើងនឹងចូលមកក្តាប់កម្ពុជាទាំងស្រុងហើយ ។ បច្ចុប្បន្ន កងទ័ពយើងបានចូលមកជាហូរហែហើយ ។ យើងក៏ក្តាប់បានជាបណ្តើរៗហើយដែរ ។ អ្នកឯងត្រូវខិតខំបន្តការងារនេះតទៅទៀត ។ ថ្ងៃក្រោយ ខ្ញុំនឹងខទេ្សនាមអ្នកឯងឲ្យចូលបក្សវៀតណាម ភ្ជាប់ខ្សែគ្នាទាំងអស់ទាំងនៅកម្ពុជា ទាំងអ្នកនៅវៀតណាម យើងនឹងចាត់តាំងឲ្យឡើងជាកម្មាភិបាលម្នាក់នៅតំបន់នេះដើម្បីគ្រប់គ្រងប្រជាជនកម្ពុជា ។

ឆ្នាំ១៩៧៥ ក្រោយរំដោះ ធីសាង ក៏នៅតែពុំទាន់បានឡើងជាកម្មាភិបាលតាមពាក្យសន្យារបស់ ទីហាយ ។ ឪពុក ធីសាង ក៏អន្ទោកអន្ទោលស្នើសុំរដ្ឋាភិបាលកម្ពុជាទៅនៅវៀតណាមវិញដើម្បីស្រាវជ្រាវរកខ្សែនេះ ។

២) ដើមឆ្នាំ១៩៧៦ ធីសាង បានទៅដល់វៀតណាមបានមួយអាទិត្យ ធីសាង និងឪពុកបានស្រាវជ្រាវភ្ជាប់ខ្សែនេះតាមបណ្តាំរបស់ ទីហាយ តែពេលនោះ ធីសាង រកខ្សែរយៈមិនឃើញសោះ ។ មួយខែបាត់ ពីរខែបាត់ ។ ខណៈពេលនោះ គ្រួសាររបស់ ធីសាង ក៏មានការលំបាកទៅៗ ផ្ទះក៏គ្មានអង្ករស៊ីក៏អត់ ឯលុយក៏រកមិនបានទៀត ធីសាង គិតមិនចេញទៅរាយការណ៍ឲ្យមូលដ្ឋានភូមិឃុំ គេមិនទទួលស្គាល់ ។ ក្រោយមក ប្រហែលជាខែកញ្ញា ឆ្នាំ១៩៧៦ ធីសាង ក៏សម្រេចចិត្តធ្វើជាស្រីពេស្យា ដើម្បីដោះស្រាយជីវភាពផ្ទាល់ខ្លួន និងគ្រួសារ ។ ធីសាង ប្រកបមុខរបរនេះនៅកៅឡាញ់ រហូតដល់ឆ្នាំ១៩៧៨ ទើបឈប់ ។

ខែមករា ឆ្នាំ១៩៧៨ ធីសាង បាននឹកឃើញដល់រឿងចាស់ឡើងវិញ ដោយពេលនោះ លោកអនុសេនីយ៍ផ្កាយមួយ ង្វៀង បិញឡុង នៅក្នុងវរសេនាធំលេខ៣០ កងពលលេខ៧ បានទៅលេងសើចជាមួយខ្លួនជាញឹកញាប់ ហើយ ធីសាង ក៏បានស្គាល់លោកនោះរហូតមក ។ ធីសាង បាននិយាយប្រវត្តិដើមរបស់ខ្លួនកាលរស់នៅកម្ពុជាប្រាប់ទៅ ង្វៀង បិញឡុង ឲ្យបានដឹង ។ ខែមីនា ឆ្នាំ១៩៧៨ ង្វៀង បិញឡុង បាននាំ ធីសាង ទៅជួបលោកអនុសេនីយ៍ផ្កាយ៤ ឈ្មោះ ហ៊ុង១ ក៏បានទទួលស្គាល់ ធីសាង ហើយ



អ្នកទោសជនវៀតណាមជាកុមារដែលខ្មែរក្រហមចាប់មកឃុំឃាំង និងសួរចម្លើយនៅមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង)

បានណែនាំ ធីសាង ថា ការរកស៊ីរបៀបនេះជាការដោះស្រាយជីវភាពបានមួយបែបហើយ តែបច្ចុប្បន្ននេះ បក្សយើងកំពុងតែត្រូវការមនុស្សចូលទៅយកការណ៍នៅប្រទេសកម្ពុជាច្រើនណាស់ ព្រោះមួយរយៈកាលដែលយើងចូលទៅវាយកម្ពុជា យើងក្តាប់សភាពការណ៍នៅកម្ពុជាមិនបានសោះ ការវាយលុកពេលណាក៏ចេះតែចាញ់ទ័ពមួយកង១ងាប់ស្ទើរអស់រលីង ។ បន្ទាប់មក លោក ហ៊ិង ក៏បាននិយាយប្រាប់ ធីសាង ថា ខ្លួននឹងយកប្រវត្តិរបស់ ធីសាង ទៅរាយការណ៍ជូនថ្នាក់លើ ។ មួយអាទិត្យក្រោយមក ធីសាង បានទទួលដំណឹងល្អដោយលោក ហ៊ិង បាននាំ ធីសាង ឲ្យទៅជួបវរសេនីយ៍ផ្កាយ២ ត្រាន់ ហ៊ីវៀក ។ លោកវរសេនីយ៍ផ្កាយ២ ត្រាន់ ហ៊ីវៀក បាននិយាយថា ធីសាង ឯងឈប់រកស៊ីមុខរបរធ្វើស្រីពេស្យាទៅ មកធ្វើជាចារនារីវិញ មានប្រាក់ខែ និងមានមុខមាត់ ។ ដូច្នេះ លោកវរសេនីយ៍ផ្កាយ២ បានកំណត់ឲ្យ ធីសាង ចូលទៅយកការណ៍នៅកម្ពុជានៅក្នុងខែនេះ ។ ការផ្តល់ព័ត៌មាន ត្រូវឲ្យបានមុនថ្ងៃ១៥ មេសា ឆ្នាំ១៩៧៨នេះ ព្រោះបក្សយើងមានផែនការធំគឺវាយកម្ពុជានៅខែមេសា នេះហើយ ។

ទិសដៅនៃការងាររួមគឺ៖

១) ត្រូវទៅក្តាប់សភាពការណ៍នៅកម្ពុជា ឲ្យបានមួយចំនួនសិន

២) ពិនិត្យសភាពការណ៍ទ័ព តើមានអ្វីខ្លះ? កាំភ្លើងធុនស្អីខ្លះ? មានការរៀបចំយ៉ាងម៉េច?

៣) ជ្រើសភាពការណ៍មួយចំនួនមកមុខឲ្យបានសិន

៤) ត្រូវទៅស្រាវជ្រាវរកខ្សែរយៈរបស់ខ្លួន ដែលបង្កប់នៅកម្ពុជាដើម្បីងាយក្តាប់ងាយបន្ទុំខ្លួន ។ ពេលទាក់ទងគ្នាបានត្រូវក្លែងភេទធ្វើជាប្រជាជនរស់នៅជាមួយប្រជាជនកម្ពុជា ។ មុននឹងចេញទៅ ត្រូវយល់ហើយជ្រួតជ្រាបឲ្យបានច្បាស់ថា “វៀតណាមយើងជារៀមច្បងនៅលើអាស៊ីអាគ្នេយ៍នេះ” ឥឡូវយើងត្រូវទៅវាយយកកម្ពុជា ។ កម្ពុជាតូចប៉ុណ្ណេះ វាយឲ្យខ្ទេច វាយឲ្យទាល់តែចុះញ៉ម ។ បើយើងមិនវាយកម្ពុជាទេ មាគ៌ាជាយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តឥណ្ឌូចិនយើងមិនបានសម្រេចទេ លុះត្រាតែយើងយកកម្ពុជាឲ្យចូលក្នុងសហព័ន្ធឥណ្ឌូចិន ទើបយើងសម្រេចបាន ។ ជាយុទ្ធសាស្ត្ររបស់យើងគឺវាយកម្ពុជាឲ្យទាល់តែបានចាត់តាំងរដ្ឋអំណាចថ្មីឲ្យទាល់តែបាន ហើយឲ្យនៅក្រោមការគ្រប់គ្រងដាច់ខាតរបស់បក្សវៀតណាមយើង ។ យើងយកកម្លាំងទាំងធំ ទាំងតូច ទាំងចំហរ ទាំងសម្ងាត់ ទៅវាយកម្ពុជាឲ្យទាល់តែបាក់ ព្រមចូលក្នុងសហព័ន្ធឥណ្ឌូចិនទើបឈប់វាយ ។ ជាផែនការធំរបស់មជ្ឈិមបក្សវៀតណាមយើងសម្រេចថា ត្រូវវាយកម្ពុជាឲ្យបានដាច់ខាត មុនរដូវភ្លៀងធ្លាក់ឆ្នាំ១៩៧៨នេះ ។ ដូច្នេះយុទ្ធវិធីរបស់យើងមានច្រើនណាស់ ខាងចារកម្មក៏មាន ខាងស៊ើបការណ៍យោធាក៏មាន រហូតដល់ទៅលើនយោបាយបរទេស បក្សយើងបានផ្សាយជាសកលអំពីបញ្ហាចរចាសន្តិភាព និងប្រកាសថា គោរពបូរណភាពដែនដីកម្ពុជាថាគ្មានសហព័ន្ធឥណ្ឌូចិនទៀត យើងធ្វើយ៉ាងនេះដើម្បីឲ្យកម្ពុជាស្រពិចស្រពិល ភ្លេចខ្លួន ភ័ន្តប្រឡំតាមឧបាយកលរបស់យើង ហើយប្រជាជនលើសកលលោក ក៏ព្រិលស្រវាំងថា វៀតណាមយើងជាប្រទេសមួយល្អ ចេះស្វែងរកសន្តិភាព មិត្តភាព មិនមានបំណងឈ្លានពានកម្ពុជាទេ ប្រទេសវៀតណាមយើងធំ កម្ពុជាតូច ប្រជាជនតិច ។

យើងត្រូវចាំឲ្យច្បាស់ ហើយកុំភ្លេចឲ្យសោះថា បក្សយើងកំណត់យកកម្ពុជាឲ្យបាន តាមផ្លូវយោធា ។ បក្សយើងប្រើឧបាយកលផង ប្រើយោធាផង ទើបយើងយកកម្ពុជាបាន ។ ដូចជាក្រោយប្រកាសចរចា បក្សយើងបានបញ្ជាកងទ័ពយើងឲ្យវាយលុកកម្ពុជាជាច្រើនលើកមកហើយ ។ បច្ចុប្បន្ននេះ ក្រោយពីប្រកាសថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៨ ថាគ្មានសហព័ន្ធឥណ្ឌូចិនទេ ថាគោរពព្រំដែនកម្ពុជា និងគោរពបូរណភាពទឹកដីកម្ពុជា បក្សយើងបានឲ្យកងទ័ពយើងវាយលុកកម្ពុជាជាច្រើនមុខសញ្ញា មានមុខសញ្ញាស្រុកកំពង់ត្របែករបស់កម្ពុជាជាដើម ។ ពេលយកកម្ពុជាឲ្យចូលក្នុងសហព័ន្ធឥណ្ឌូចិនបានហើយ វៀតណាមយើងនឹងមានឥទ្ធិពលសម្បើមណាស់នៅអាស៊ីអាគ្នេយ៍នេះ ទាំងខាងនយោបាយ ទាំងខាងយោធា ។ លោកវរសេនីយ៍ផ្កាយ២ ត្រាន់ ហ៊ីវៀក ក៏បានចាត់តាំង ធីសាង ឲ្យចូលមកកម្ពុជានៅថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៨ ដោយប្រគល់ប្រាក់២៥ដុង សម្រាប់ធ្វើសោហ៊ុយ និងទុកឲ្យឪពុកម្តាយខ្លះ ។ ធីសាង បានចូលមកជិតដល់ភូមិទួលកណ្តាល ស្រុកពាមជរ ខេត្តព្រៃវែង ក៏ត្រូវកងទ័ពបដិវត្តន៍កម្ពុជាចាប់ខ្លួនបានតែម្តង ។

**ឆេង ម៉េង**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាល័យទួលប្រាសាទ សែន សុខ

នៅរសៀលថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំជាវេទិកាថ្នាក់រៀនមួយស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវិទ្យាល័យទួលប្រាសាទ សែនសុខ ដែលមានទីតាំងស្ថិតនៅភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន ១៦០នាក់ ។ ការរៀបចំបង្កើតឲ្យមានវេទិកាថ្នាក់រៀននេះឡើង ក្នុងគោលបំណងដើម្បីបង្កើនចំណេះដឹងប្រវត្តិសាស្ត្រ ជួយជំរុញឲ្យមានការចងចាំ ការពារកុំឲ្យមានអំពើប្រល័យពូជសាសន៍កើតមានឡើងម្តងទៀត និងបណ្តុះឲ្យមានការគិតពិចារណាទៅលើប្រវត្តិសាស្ត្រ និងដើម្បីឲ្យសិស្សានុសិស្សពិភាក្សាគ្នាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលខ្លួនបានដឹង និងបានរៀនសូត្រកន្លងមក ។

នៅក្នុងវេទិកាថ្នាក់រៀននេះដែរលោក ដេង ពង្សរ៉ាស៊ី នាយកនៃកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើបទបង្ហាញដល់សិស្សានុសិស្សទាំងអស់ដែលបានចូលរួមវេទិកាថ្នាក់រៀននេះ ស្តីពីការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ការធ្វើទារុណកម្មរបស់ខ្មែរក្រហមទៅលើអ្នក



លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើបទបង្ហាញដល់សិស្សានុសិស្សវិទ្យាល័យទួលប្រាសាទ សែន សុខ ស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ។

ទោស ការបាត់បង់ជីវិតរបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកលោក ដេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារខ្លីមួយដែល “មានចំណងជើងថាកុមារកម្ពុជា” ដោយបានបង្ហាញពីក្មេងកំព្រាក្រោយរបបខ្មែរក្រហម និងបានចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) ដល់សិស្សទាំងអស់ដែលបានចូលរួមក្នុងកម្មវិធីវេទិកាថ្នាក់រៀននេះ ។

គី លក្ខិណា ជាសិស្សរៀននៅថ្នាក់ទី១២A១ នៃវិទ្យាល័យទួលប្រាសាទ សែនសុខ បានប្រាប់ឲ្យដឹងថា នៅពេលដែលគាត់បានឃើញក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាមកបង្រៀនសិស្សនៅវិទ្យាល័យទួលប្រាសាទ សែន សុខ គាត់មានអារម្មណ៍សប្បាយរីករាយ និងគាំទ្រវេទិកានេះ ។ លក្ខិណា បានបន្តថា “វេទិកានេះពិតជាល្អដែលធ្វើឲ្យគាត់យល់ដឹងកាន់តែច្បាស់ពីអំពើប្រល័យពូជសាសន៍” ។ លក្ខិណា ធ្លាប់ឮលោកគ្រូអ្នកគ្រូ និងឪពុកម្តាយរបស់គាត់ប្រាប់ដែរ តែមិនបានបកស្រាយឲ្យបានក្បោះក្បាយទេ ដូចជាការធ្វើទារុណកម្មនៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង ។ លក្ខិណា មិនបានដឹងថាខ្មែរក្រហមបានធ្វើទារុណកម្មដោយវិធីណាទៅលើអ្នកទោសទេ ប៉ុន្តែបន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀននេះ គាត់បានដឹងពីការធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅនៅទួលស្លែង ។ លក្ខិណា មានអារម្មណ៍អាណិតចំពោះជនរងគ្រោះទាំងនោះ ហើយមិនចង់ឲ្យរបបឃោរឃៅនេះត្រឡប់មកវិញទេ ។ លក្ខិណា បាននិយាយទាំងទឹកភ្នែករលីងរលោងថា គាត់ពិតជាជឿថាមានរឿងរ៉ាវព្រៃផ្សៃបែបនេះកើតឡើងមែន ព្រោះគាត់បានឮឪពុកម្តាយនិយាយប្រាប់អំពីប្រវត្តិយាយ តា និង អ៊ំ របស់គាត់ដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ យាយតារបស់ លក្ខិណា បានឈឺហើម និងស្លាប់ដោយសារការអត់អាហារបរិភោគ ។

ថៃ គុងអៀវ ជាសិស្សរៀននៅថ្នាក់ទី១១A១ នៃវិទ្យាល័យទួលប្រាសាទ សែន សុខ ។ គុងអៀវ បាននិយាយថា ការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនេះពិតជាល្អ ព្រោះបានបង្រៀនឲ្យក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ គុងអៀវ ទទួលបានចំណេះដឹងច្រើនពីវេទិកាថ្នាក់រៀនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឡើង ដែលពីមុនគាត់មិនបាន



សិស្សវិទ្យាល័យទួលប្រាសាទ សែន សុខ ចូលរួមវេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ។

រៀនពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យច្រើនទេ ហើយក៏មិនបានដឹងច្រើនដែរ ។ គុង អៀវ បានបន្តថា លោកគ្រូ អ្នកគ្រូ បង្រៀនតែទៅតាមកាលវិភាគដែលក្រសួងអប់រំបានដាក់ឲ្យ តែម៉ោងមិនគ្រប់គ្រាន់ ហើយជួនកាលគ្រូបង្រៀនទាក់ទងរបបខ្មែរក្រហម ក៏បានលើកពីរបបខ្មែរក្រហមមកពន្យល់ខ្លះដែរ ។ គុង អៀវ បានបង្ហាញពីអារម្មណ៍អាណិតប្រជាជននៅសម័យខ្មែរក្រហម ដែលគ្មានអាហារបរិភោគគ្រប់គ្រាន់ និងទទួលរងទារុណកម្មជាដើម ។ គុង អៀវ ធ្លាប់ឮរបបខ្មែរក្រហមពីឪពុកម្ដាយរបស់គាត់ប្រាប់ ដែលកាលនោះឪពុកម្ដាយគាត់ធ្វើការនៅក្នុងកងកុមារ ។ គុង អៀវ ជឿថាពិតជាមានរបបខ្មែរក្រហមកើតឡើងពិតមែនតាមរយៈការរៀបរាប់របស់ឪពុកម្ដាយគាត់ តាមរយៈឯកសារ និងការអានសៀវភៅ ។ ប៉ុន្តែនៅពេលអនាគត គុង អៀវ មិនប្រាកដថាក្មេងជំនាន់ក្រោយជឿថាមានរបបខ្មែរក្រហមកើតឡើងនោះទេ ព្រោះថាមានគម្លាតឆ្ងាយគ្នានៃព្រឹត្តិការណ៍ដែលបានកើតឡើងរវាងសម័យបច្ចុប្បន្ន និងសម័យខ្មែរក្រហម ម្យ៉ាងទៀតគឺអាស្រ័យលើការគិតរបស់បុគ្គលខ្លួនឯងផ្ទាល់ ។ គុង អៀវ បានបន្តទៀតថា យើងមិនអាចបង្ខំឲ្យក្មេងជំនាន់ក្រោយជឿទេ គឺមានតែផ្អែកលើឯកសារ និងភស្តុតាងដែលនៅសល់ដល់បច្ចុប្បន្ន ។ គុង អៀវ មានការចាប់អារម្មណ៍ទៅលើប្រវត្តិសាស្ត្រខ្មែរ ដូចជា សម័យអង្គរបានធ្វើឲ្យប្រទេសរុងរឿង សម័យលង្វែកមានការកសាងបន្ទាយរឹងមាំ និងរបបកម្ពុជាប្រជាធិបតេយ្យ បានសម្លាប់ពូជសាសន៍ខ្លួនឯង ។

លោកគ្រូឈ្មោះ អាន សុភា ជាគ្រូបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋ ថ្នាក់ទី១២A១ និង១២A២ នៃវិទ្យាល័យទួលប្រាសាទ សែន សុខ ដែលទើបតែផ្លាស់មកពីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំវេទិកាថ្នាក់រៀននេះពិតជាល្អ ព្រោះពេលបង្រៀនមានស្លាយមេរៀន និងមានខ្សែភាពយន្តឯកសារខ្លីៗបញ្ចាំងឲ្យសិស្សានុសិស្សទស្សនា ។ ការបង្រៀននេះធ្វើឲ្យសិស្សឆាប់ចាប់បាន ងាយយល់ និងបានបង្កើនចំណេះដឹងដល់សិស្សថែមទៀត ។ ពេលខ្លះលោកគ្រូ សុភា ក៏បានជួយបង្រៀនមុខវិជ្ជាប្រវត្តិសាស្ត្រដែរនៅពេលដែលគ្រូឯកទេសអវត្តមាន ។ សិស្សពិតជាមានការចាប់អារម្មណ៍ទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយបានលើកជាសំណួរនៅពេលគាត់បង្រៀន ដូចជា ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ? ហេតុអ្វីមិនឲ្យប្រជាជនហូបឆ្អែត? លោកគ្រូ សុភា បានបន្តថា ទោះបីយ៉ាងណា នៅពេលដែលបង្រៀនសិស្ស ក៏មានសិស្សមួយចំនួនតូចមិនជឿដែរ ។ សិស្សខ្លះបានដឹងរឿងរ៉ាវក្នុងរបបខ្មែរក្រហមតាមរយៈឪពុកម្ដាយនិយាយប្រាប់ ។

លោកនាយកអនុវិទ្យាល័យទួលប្រាសាទ សែន សុខ ឈ្មោះ អ៊ុំ សុកំ ដែលត្រូវបានតែងតាំងជានាយកវិទ្យាល័យនេះនៅឆ្នាំ២០១៦ បានគាំទ្រឲ្យមានវេទិកាអប់រំពីរបបខ្មែរក្រហមដើម្បីឲ្យសិស្សមានការចងចាំពីរបបឃោរឃៅ និងយង់ឃ្នងនេះ ។ លោក សុកំ ក៏បានរំឭកផងដែរពីការបាត់បង់ឪពុកម្ដាយរបស់គាត់ដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់តាំងពីឆ្នាំ១៩៧២ ដោយចោទថាជាគិញ ។ លោក សុកំ ក៏បានរំឭកពីកុមារភាពរបស់គាត់ដែលឆ្លងកាត់ភាពជូរចត់ បាត់បង់គ្រួសារ និងការតស៊ូក្នុងជីវិតក្រោយពេលដែលរបបខ្មែរក្រហមបានដួលរលំ ។ បន្ទាប់មកលោក សុកំ ក៏បាននិយាយរៀបរាប់ដោយសង្ខេបពីប្រវត្តិសាលាថា សាលានេះបានកើតឡើងនៅពេលដែលឯកឧត្តម ជា សុផារ៉ា មានតួនាទីជាអភិបាលក្រុង ។ ការបង្កើតសាលានេះក្នុងគោលបំណងឲ្យប្រជាជនដែលផ្លាស់មកពីតំបន់បឹងកក់ អគារប៊ូឌីញ និងប្រជាជននៅសង្កាត់ខ្មួញ ខណ្ឌ សែន សុខ នេះ ចូលរៀន ។ សិស្សានុសិស្សទាំងនេះមិនពិបាកធ្វើដំណើរទៅរកសាលាដែលមានចម្ងាយឆ្ងាយ ។ កាលពីមុនភូមិសំរោង សង្កាត់ឃ្មួញ ជាវាលស្រែ ចំណែកទីតាំងវិទ្យាល័យទួលប្រាសាទ ជាកន្លែងធ្វើកសិកម្ម និងធារាសាស្ត្រ ដើម្បីពិសោធការដាំដុះស្រូវ ។ លោក សុកំ បានបន្តទៀតថា សាលានេះបង្កើតឡើងនៅក្នុងឆ្នាំ២០០២ ហើយពេលបង្កើតឡើងដំបូងមានតែអនុវិទ្យាល័យ និងមានតែមួយអគារប៉ុណ្ណោះ ។ នៅពេលនោះមានសិស្សចូលរៀនប្រមាណជា១៥០នាក់ ក្នុងនោះសិស្សនារីមានចំនួន៨៧នាក់ និងមានបុគ្គលិកចំនួន១២នាក់ ក្នុងនោះស្ត្រីមាន៥នាក់ ។ នៅឆ្នាំ២០០៥ សាលានេះបានបង្កើតទៅជាវិទ្យាល័យ និងមានសិស្ស៩៨១នាក់ ក្នុងនោះសិស្សនារី៤០៦នាក់ ចូលរៀន ។ រហូតមកដល់បច្ចុប្បន្ននេះមានសិស្សចំនួន១.៨២៥ ក្នុងនោះមានស្រី៧៤១នាក់ ហើយមានបុគ្គលិក ៨៣នាក់ និងស្រី២២នាក់ ។

**ដារ៉ារត្ន មេត្តា**

# វេទិកាថ្នាក់រៀនស្តីពីសារសំខាន់នៃការសិក្សាប្រវត្តិសា
# ទួលប្រាសាទ សែន សុខ ស្ថិតនៅភូមិសំរោង










# ស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅវិទ្យាល័យ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ










PB







# ជីវិតតស៊ូក្នុងសម័យខ្មែរក្រហម

អន្លង់វែងជាតំបន់ដែលកាន់កាប់ដ៏រឹងមាំ និងចុងក្រោយរបស់ខ្មែរក្រហម ។ នៅពេលដែលខ្ញុំបានដឹងឮពីតំបន់អន្លង់វែងដំបូង ខ្ញុំមានអារម្មណ៍ថា ខ្លាចរអាចំពោះតំបន់នេះណាស់ ព្រោះអន្លង់វែងពោរពេញទៅដោយអតីតយោធាខ្មែរក្រហមរស់នៅ ។ ប៉ុន្តែនៅពេលដែលខ្ញុំបានមកដល់អន្លង់វែងភ្លាម អ្វីៗទាំងអស់ហាក់ដូចជាមិនដូចអ្វីដែលខ្ញុំបានគិតនោះទេ ។ អន្លង់វែងពោរពេញដោយទេសភាពធម្មជាតិព្រៃភ្នំស្រស់បំព្រង ចំណែកប្រជាជនមានភាពរួសរាយរាក់ទាក់គួរឲ្យស្រឡាញ់រាប់អាន ។

ខ្ញុំបានធ្វើដំណើរមកភូមិទួលសាលា ដែលស្ថិតនៅក្នុងឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ពេលនោះខ្ញុំបានជួបអ៊ំប្រុសម្នាក់ឈ្មោះ ជុំ ខេន ។ ខេន មានអាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ប៉ុន្តែ ខេន មានស្រុកកំណើតនៅភូមិឈើទាល ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុករបស់ ខេន ឈ្មោះ ជុំ ឃិន និងម្តាយឈ្មោះ ជួប សួន អ្នកទាំងពីរបានស្លាប់អស់ហើយ ។ កាលដើមឡើយ ខេន រៀនបានត្រឹមថ្នាក់ទី៧ចាស់ នៅសាលាក្នុងភូមិ ដោយអាចអាន និងសរសេរបាន ។ ក្រោយមក ដោយប្រទេសជាតិកើតមានសង្គ្រាម ខេន ក៏បានឈប់រៀន ហើយមករស់នៅជាមួយឪពុកម្តាយវិញ ប្រកបរបរធ្វើស្រែចម្ការជាធម្មតា ។ លុះដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៣ ខេន ត្រូវបានខ្មែរក្រហម កៀរឲ្យទៅរស់នៅស្រុកស្អាង ខេត្តកណ្តាល ។ បន្ទាប់មក ខេន ត្រូវបានអង្គការឲ្យចូលធ្វើការក្នុងកងចល័ត ។ លុះធ្វើការនៅក្នុងកងចល័តបានប្រហែល៤ទៅ៥ខែ អង្គការក៏បានចាត់តាំងគាត់ឲ្យទៅអង្គភាពយោធាវិញ ដោយធ្វើជាអ្នកដឹកជញ្ជូនសម្ភារ ស្បៀងអាហារ គ្រឿងសញ្ញុរុធ និងគ្រាប់រំសេវ យកទៅឲ្យកងទ័ពនៅសមរភូមិមុខ ។ ជាញឹកញាប់ ក្រុមដឹកជញ្ជូនរបស់គាត់តែងបានជួបប្រទះជាមួយនឹងកងទ័ពវៀតណាម (កងទ័ពធីវគី) ។ ប៉ុន្តែ ក្រុមដឹកជញ្ជូនរបស់គាត់មិនបានធ្វើការតតាំងជាមួយកងទ័ពធីវគីទេ ពេលខ្លះត្រូវលាក់ខ្លួន


ទេសភាពស្រុកអន្លង់វែងមើលពីលើកំពូលភ្នំដងរែក ។

ក្នុងព្រៃដើម្បីគេចឲ្យផុតពីកងទ័ពធីវគី ហើយពេលខ្លះទៀតត្រូវធ្វើដំណើរតាមផ្លូវផ្សេង ដើម្បីដឹកជញ្ជូនស្បៀងយកទៅដាក់នៅគោលដៅដែលមានយោធាខ្មែរក្រហមឈរជើង ។

នៅឆ្នាំ១៩៧៥ ខេន បានចូលធ្វើជាយោធាពេញសិទ្ធិនៅក្នុងកងពលលេខ១១ ប៉ុន្តែកងពលលេខ១១នេះ ក៏ត្រូវបានរំលាយចោលបន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពរបស់ ខេន បានឈរជើងនៅភ្នំពេញម្តុំស្ពានជ្រោយចង្វារ ។ ក្រោយមក នៅចន្លោះឆ្នាំ១៩៧៧-ឆ្នាំ១៩៧៨ អង្គការបានបញ្ជូន ខេន ឲ្យទៅឈរជើងនៅព្រំដែនកម្ពុជា-វៀតណាម ដោយសារពេលនោះកងទ័ពវៀតណាមបានវាយឆ្មក់តាមបណ្តោយព្រំដែន ។ បន្ទាប់មកទៀត ខេន ត្រូវបានអង្គការបញ្ជូនឲ្យទៅខេត្តរតនគិរីធ្វើការផ្នែកសេដ្ឋកិច្ច និងធ្វើជាអ្នកដាំបាយឲ្យកងទ័ពនៅក្នុងកងពល៨០១ ដែលគ្រប់គ្រងដោយ តាសារឿន ។

ឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ តាម៉ុក បានប្រមូលយោធាខ្មែរក្រហមមួយចំនួនឲ្យឡើងលើភ្នំដងរែក ហើយបានបែងចែកជាអង្គភាព និងបែងចែកមុខព្រួញមួយៗឲ្យការពារ និងទទួលខុសត្រូវរៀងៗខ្លួន ។ ពេលនោះ អង្គភាពរបស់ ខេន មានភារកិច្ចការពារមុខព្រួញខ្វាវ និងអូរត្រាវ (នៅជាប់ព្រំដែនថៃ) ដែលទីកន្លែងទាំងពីរនេះជាជំរំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ ក្រោយពីបានឈរជើងនៅទីនោះបានមួយរយៈ ខេន ក៏ត្រូវបានប្តូរឲ្យចុះមកធ្វើការនៅខេត្តស្ទឹងត្រែងវិញ ។ ការធ្វើដំណើរមកខេត្តស្ទឹងត្រែង ពិតជាមានគ្រោះថ្នាក់ និងជួបការលំបាកខ្លាំងណាស់ ជួនកាលត្រូវឡើងភ្នំ ជួនណាត្រូវហែលឆ្លងទឹក ជួនកាលដើរកាត់គ្រាប់មីន ដើរកាត់រណ្តៅចម្រូង ព្រមទាំងមានការវាយឆ្មក់ពីកងទ័ពវៀតណាមទៀតផង ។ កាលណោះ ខ្មែរក្រហមបានទទួលជំនួយមកពីប្រទេសចិន មានគ្រឿងសព្វាវុធ ចំណែកគ្រឿងឧបភោគបរិភោគ មានអង្ករ ត្រីខកំប៉ុង មីកញ្ចប់ អំបិល ស្ករ ប៊ីចេង ជាដើម បានទទួលជំនួយមកពីកាកបាទក្រហមអន្តរជាតិ ។ ប្រសិនបើមិនមានជំនួយឧបត្ថម្ភទាំងនេះទេ ខ្មែរក្រហមពិតជាជួបការលំបាកជាមិនខានឡើយ ។ ខេន បានប្រាប់បន្តឲ្យដឹងថា ប្រជាជនដែលរស់នៅក្នុងតំបន់អន្លង់វែង ក្រោមការគ្រប់គ្រងរបស់ តាម៉ុក ទទួលបានការផ្គត់ផ្គង់គ្រប់បែបយ៉ាង ដូចជាសម្ភារប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ ។ ពេលទៅដល់ខេត្តស្ទឹងត្រែង ខេន បានទៅរស់នៅក្នុងភូមិជាមួយប្រជាជនដោយបានចុះជួយធ្វើស្រែចម្ការប្រជាជនតាមភូមិ ។ បើប្រជាជនណាមានជីវភាពក្រខ្សត់ អង្គភាពរបស់ ខេន នឹងមានវត្ថុជូនដល់គាត់មានដូចជា សារ៉ុង ខោអាវ ជាដើម ។ បើអ្នកភូមិមានគ្រឿងឧបភោគដូចជា ត្រី សាច់ បន្លែ ហើយមានបំណងចង់លក់ អង្គភាពរបស់ ខេន នឹងទិញយកទាំងអស់ ដែលទង្វើទាំងអស់នេះបានធ្វើឲ្យប្រជាជនយល់ថា យោធានៅក្នុងអង្គភាពរបស់ ខេន សុទ្ធតែជាមនុស្សល្អ ហើយប្រជាជនកាន់តែមានទឹកចិត្តស្រឡាញ់រាប់អានកាន់តែខ្លាំងឡើងៗ ។ រាល់ទង្វើទាំងឡាយដែលអង្គភាពយោធារបស់ ខេន បានប្រព្រឹត្តមកលើប្រជាជន ក្នុងអំឡុងពេលរស់នៅជាមួយប្រជាជននោះ បានធ្វើឲ្យអ្នកភូមិកាន់តែមានចិត្តអាណិតស្រឡាញ់រាប់អានដូចកូនចៅរបស់ខ្លួន ហើយក៏បានផ្តល់ជាស្រូវអង្ករដល់អង្គភាពយោធារបស់ ខេន ដូចកូនចៅបង្កើតរបស់ខ្លួនអ៊ីចឹងដែរ ។ ខាងលើនេះ គឺជាគោលនយោបាយរបស់ខ្មែរក្រហមដាក់ឲ្យកងទ័ពរបស់ខ្លួនអនុវត្តដើម្បីយកចិត្តប្រជាជននៅអំឡុងពេលធ្វើសង្គ្រាមជាមួយកងទ័ពវៀតណាមក្រោយឆ្នាំ១៩៧៩ ។

បន្ទាប់ពីមានការវាយប្រហារខ្លាំងក្លាពីកងទ័ពវៀតណាម តាម៉ុក បានដឹកនាំប្រជាជន និងកងទ័ពរត់ភៀសខ្លួនទៅរស់នៅក្នុងជំរំភូណយ ដែលស្ថិតនៅក្នុងខេត្តស៊ីសាកេត ប្រទេសថៃ ។ ក្នុងរយៈពេលដែលបានស្នាក់នៅក្នុងជំរំភូណយ តាម៉ុក បានប្រមូលកម្លាំងកងទ័ពឲ្យនៅផ្តុំគ្នាជានិច្ច ។ ចំណែក ខេន បានឈរជើងការពារនៅតាមច្រកព្រំដែននៃជំរំភូណយ ដោយកាលណោះមានការឧបត្ថម្ភពីកាកបាទក្រហមអន្តរជាតិមានដូចជា កន្លែងស្នាក់នៅ ម្ហូបអាហារ មន្ទីរពេទ្យ សាលារៀន ហើយប្រជាជនបានរៀនសូត្រ និងមានការងាររធ្វើគ្រប់ៗគ្នា ។

ក្រោយពីប្រទេសជាតិមានសុខសន្តិភាព ខេន បានវិលត្រឡប់មករស់នៅក្នុងស្រុកអន្លង់វែងវិញ និងបានរៀបការនៅក្នុងឆ្នាំ១៩៨៩ ជាមួយប្រពន្ធឈ្មោះ គង់ ភា និងមានកូនស្រីម្នាក់ប្រុសម្នាក់ ដោយប្រកបរបរធ្វើស្រែចម្ការចិញ្ចឹមជីវិតរហូតដល់សព្វថ្ងៃ ។

**កែវ សុភី**

# សារី សយ ត្រូវចាប់ខ្លួនបន្ទាប់ពីជម្លោះរវាង ប៉ុល ពត និង តាម៉ុក នៅឆ្នាំ១៩៩៧

*សារី សយ អាយុ៦៦ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាស្រុកត្រពាំងប្រាសាទ បានរៀបរាប់ថា បន្ទាប់ពីជម្លោះរវាងក្រុម ប៉ុល ពត និង តាម៉ុក បានបញ្ចប់នៅឆ្នាំ១៩៩៧ មេបញ្ជាការជាន់ខ្ពស់នៅតំបន់ត្រពាំងប្រាសាទដែលស្មោះត្រង់ជាមួយ ប៉ុល ពត ដូចជា សូរ សារឿន (០៥), មៀច សាន (០៦) និងបក្ខពួកមួយចំនួនទៀត ត្រូវបាន តាម៉ុក ចាប់ខ្លួន និងសម្លាប់ចោល ។ ចំណែកឯមេបញ្ជាការបន្ទាប់មួយចំនួនទៀតដូចជា ជុំ ជាតិ, ជា កែវ, ប៊ុន ពិន និង រ៉ាយ ត្រូវបាន តាម៉ុក ចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរ១៩ នៅដើមឆ្នាំ១៩៩៨ ។ មន្ទីរ១៩ មានទីតាំងនៅអន្លង់វែង ដែលមាន ខឹម ង៉ុន ជាប្រធានមន្ទីរ ។*



*សារី សយ នៅសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ*

*សព្វថ្ងៃ សារី សយ រស់នៅភូមិទួលតាសេក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ សយ មានប្រពន្ធឈ្មោះ អ៊ុន សព្វថ្ងៃមានកូនចំនួន៧នាក់ក្នុងនោះមានស្រីម្នាក់ ។ សយ មានឪពុកឈ្មោះ រស់ ស៊ុម ម្ដាយឈ្មោះ ជាម ចែម ។ សយ មានបងប្អូន៨នាក់ប្រុស៦ស្រី២ និងមានស្រុកកំណើតនៅភូមិតាអោក ឃុំឈ្មោង ស្រុកពញាឮ ខេត្តកណ្ដាល ។ សយ ជាកូនទីពីរ ធ្លាប់បានរៀនសូត្រនៅសាលាបឋមសិក្សាវត្តអង្គជុំត្រឹមថ្នាក់ទី១០ "ចាស់" ។ សយ ឈប់រៀនដោយសារមានជីវភាពខ្វះខាតមកជួយធ្វើស្រែចម្ការឪពុកម្ដាយ ។*

*នៅខែវិច្ឆិកា ឆ្នាំ១៩៧០ សយ បានស្ម័គ្រចិត្តចូលបដិវត្តន៍តាមការអំពាវនាវរបស់សម្ដេច សីហនុ ឲ្យកូនចៅចូលព្រៃម៉ាគីដើម្បីរំដោះជាតិ ព្រោះលោកសេនាប្រមុខ លន់ នល់ បានក្បត់ព្រះអង្គ ហើយបានងាកចូលទៅរកលោកសេរីសហរដ្ឋអាមេរិក ។ សយ យល់ឃើញថា មិនចង់ឲ្យប្រទេសជាតិស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេសដូចជនទាន់បារាំងក៏បានសម្រេចចិត្តចាកចេញពីផ្ទះ រួមជាមួយមិត្តភក្តិនៅក្នុងភូមិជាច្រើនទៀត ។ ចាកចេញពីផ្ទះដំបូង សយ បានចូលទៅក្នុងព្រៃបារាំង ខេត្តកំពង់ស្ពឺ ។ ពេលនោះ សយ មិនទាន់ចូលជាយោធាភ្លាមទេ ធ្វើជាឈ្លបភូមិឃុំសិន និងបានដើរចលនាយុវជនយុវនារីឲ្យចូលបម្រើបដិវត្តន៍ ។*

*នៅឆ្នាំ១៩៧១ សយ បានចូលយោធាតំបន់១៥ ដឹកនាំដោយឈ្មោះ ចេង អន មានទីតាំងនៅវត្តអង្គព្រលឹង ម្ដុំពងទឹក ហាត់ក្បួនយោធា និងចូលសមរភូមិវាយជាមួយទាហាន លន់ នល់ ។ មុនដំបូងខាងខ្មែរក្រហមគ្មានអាវុធគ្រប់គ្រាន់ទេ ត្រូវធ្វើសង្គ្រាមជារបៀបវាយឈ្លប វាយចល័តម្ដងត្រង់នេះម្ដងត្រង់នោះ មិនទាន់មានទ្រង់ទ្រាយធំទេដូចជាវាយនៅម្ដុំបាសិតជាដើម ។*

*នៅឆ្នាំ១៩៧៣ សយ បានចូលប្រយុទ្ធនៅក្នុងសមរភូមិដែលមានប្រធានកងពលឈ្មោះ សូរ សារឿន ។ កាលនោះ សយ*

នៅក្នុងយោធាភូមិភាគពិសេសវរសេនាតូច២១៤ ដឹកនាំដោយឈ្មោះ អ៊ី អង់អាច វាយប្រយុទ្ធគ្នាជាមួយទាហាន លន់ នល់ នៅម្តុំអគ្គស្នួល កប់ស្រូវ ពោធិ៍ចិនតុងសំដៅចូលទីក្រុងភ្នំពេញ ។ កម្លាំងខ្មែរក្រហមជាច្រើនកងពលបានវាយចូលទីក្រុងភ្នំពេញ នៅម៉ោង ៩ព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សយ និងកម្លាំងភូមិភាគពិសេសបានចូលដល់ភ្នំពេញ ឃើញប្រជាជនខ្លះនាំគ្នាចេញដំណើរជាបណ្តើរៗ ប៉ុន្តែមានអ្នកខ្លះនៅអង្គុយហូបគុយទាវធម្មតា និងនៅមានអ្នកខ្លះនៅលក់ដូរនៅឡើយ ។ លុះដល់ថ្ងៃត្រង់បន្តិច អ្នករស់នៅក្នុងទីក្រុងភ្នំពេញ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារអង្គការបង្ខំឲ្យចេញពីទីក្រុង ។ ពេលនោះមានច្រើនកងពលដែលចូលមក ហើយបានដើរប្រាប់ឲ្យប្រជាជនចាកចេញពីផ្ទះសម្បែងតាមបញ្ជារបស់ថ្នាក់លើប្រាប់ឲ្យប្រជាជនចេញក្នុងរយៈពេលខ្លី ដើម្បីបោសសម្អាតទីក្រុងក្រែងមានខ្មាំងលាក់ខ្លួន ។ សយ មានឋានន្តរស័ក្តិជាអនុវរសេនាធំគ្រប់គ្រងយោធា១២០នាក់ ។

នៅឆ្នាំ១៩៧៦ សយ ត្រូវអង្គការចាត់តាំងឲ្យទៅនៅស្រុកវឺនសៃ ខេត្តរតនគិរី ។ កាលនោះមានយោធាចំនួន៥.០០០នាក់ការពារព្រំដែន ដែលមានប្រធានកងពលឈ្មោះ សូរ សារឿន ឈ្មោះ អ៊ុង វ៉ែន ឈ្មោះ សុន ចេញដំណើរពីភ្នំពេញកាត់តាមខេត្តក្រចេះ ។ ពេលទៅដល់ដំបូង យោធាខ្មែរក្រហមជាច្រើនបានស្លាប់ដោយសារតែជំងឺគ្រុនចាញ់ ។ កងពល៨០១ មានបែងចែកជាអង្គភាពតូចៗបន្តទៀត ដូចជា អង្គភាព៨០៤ ជានារីសុទ្ធចំនួន៤០០នាក់ អង្គភាព៨០៥ ជាអង្គភាពពេទ្យ ប្រធានឈ្មោះ ឡាយ សារឹម អង្គភាព៨០៦ អង្គភាពដឹកជញ្ជូន ប្រធានឈ្មោះ ម៉ុនៗ សយ នៅអង្គភាព៨០៣ ខាងកាំភ្លើងធំ ។ សយ មាននាទីជាអនុសេនាធំ ។ នៅឆ្នាំ១៩៧៧-៧៨ គណៈភូមិភាគឦសានត្រូវអង្គការចាប់ខ្លួន ។ ពេលនោះឈ្មោះ សូរ សារឿន ឡើងជាគណៈភូមិភាគគ្រប់គ្រងប្រជាជនផង និងគ្រប់គ្រងយោធាផង ។

នៅឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមបានវាយចូលប្រទេសកម្ពុជា កងពល៨០១នៅតាមព្រំដែនមិនបានរត់ទៅរកស្រុកកំណើតវិញទេ នាំគ្នាធ្វើដំណើរកាត់ព្រៃរហូតដល់ព្រំដែនថៃ ។


ផ្លូវឡើងទៅប្រកដប់រុន ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ក្រោយឆ្នាំ១៩៧៩ សង្គ្រាមបានចាប់ផ្ដើមឡើងជាថ្មីម្ដងទៀត ដើម្បីប្រឆាំងនឹងវត្តមានកងទ័ពវៀតណាម និងប្រឆាំងជាមួយរដ្ឋាភិបាលភ្នំពេញ ។

នៅឆ្នាំ១៩៨០ សយ បានឡើងមកលើភ្នំប្រក១០០១ គ្រប់គ្រងដោយ សុន សេន កាលនោះកងពល៨០១ សូរ សារឿន គ្រប់គ្រងដដែល ។ ចំណែកកងពល៤១៧ ប្រធានកងពលឈ្មោះ កែ ពក ។ សយ ប្រធានវរសេនាធំដឹកនាំកម្លាំងយោធាមកខាងខេត្តព្រះវិហារ ខេត្តកំពង់ធំ ចល័តដល់ព្រៃកក្ដាម ។ កាលនោះមានជំនួយអាវុធពីប្រទេសចិន និងសម្ភារជាច្រើនទៀត ។ កម្លាំងយោធាខ្មែរក្រហមបានចុះមកដល់ព្រៃកក្ដាម ពញាក្រូ ជិតភ្នំពេញ ចំណែកកាំភ្លើងបានយកមកពីលើភ្នំ ហើយស្បៀងអាហារទាក់ទងទិញពីប្រជាជននៅតាមភូមិដ្ឋាន ហើយបានឆ្លៀតឱកាសអូសទាញប្រជាជនថែមទៀត ។

នៅឆ្នាំ១៩៨៨ សយ ដើរជាន់មីនដាច់ជើងម្ខាង ។ ក្រោយមក តាម៉ុក ចាត់តាំង សយ ឲ្យនៅសមរភូមិក្រោយដឹកនាំប្រជាជននៅប្រកជាំស្វា ជប់រុន មានទីតាំងនៅក្នុងទឹកដីថៃ ។ ប្រជាជននៅសមរភូមិក្រោយត្រូវបានផ្ទាក់លើចាត់ឲ្យជួយបិតចម្រូងដើម្បីទុកដាក់ការពារកុំឲ្យកម្លាំងខាងរដ្ឋាភិបាលចូលមក ។ ចម្រូងភាគច្រើនយកដើមឫស្សីមកពុះ ហើយកាត់ជាកង់ៗប្រវែងបីតឹក បិតចុងឲ្យស្រួច និងបិតកណ្ដាលឲ្យមានគន្លាក់ដើម្បីដោតចុះទៅក្នុងដី ពេលកងទ័ពខាងរដ្ឋាភិបាលដើរចូលមកមុតស្លាប់ ជួនកាលដើរទៅមុខលែងរួច ។

នៅឆ្នាំ១៩៨៩ នៅពេលកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជា សង្គ្រាមហាក់ធូរស្បើយបន្តិច ។ នៅឆ្នាំ១៩៩០ តាម៉ុក បានហៅយោធាស្ទើរតែទាំងអស់ឲ្យមករស់នៅជុំគ្នានៅលើភ្នំដងរែកវិញ ហើយ តាម៉ុក បានធ្វើផ្លូវចុះមកក្រោយតាមប្រកជាំ ដើម្បីនាំប្រជាជនពីដីរំទឹកដីថៃឲ្យមករស់នៅខាងក្រោម តាមជើងភ្នំ និងកន្លែងផ្សេងៗក្នុងស្រុកអន្លង់វែង ។ នៅក្នុងឆ្នាំ១៩៩០ ប្រទេសចិនបានផ្ដាច់ជំនួយឲ្យខាងយោធាខ្មែរក្រហមស្ទើរតែទាំងស្រុង នៅទីបញ្ចប់ តាម៉ុក សម្រេចចិត្តធ្វើរោងអារឈើ និងកាប់ឈើដោយយកដើមណាធំៗទៅលក់ឲ្យប្រទេសថៃដើម្បីយកលុយចិញ្ចឹមកងទ័ព និងប្រជាជន ។


ទីតាំងកងអនុសេនាធំការពារព្រំដែនលេខ៤ នៅប្រកជប់រុន ក្នុងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

នៅឆ្នាំ១៩៩៣ មានការបោះឆ្នោតដែលរៀបចំដោយអង្គការសហប្រជាជាតិ “ហៅកាត់ថា អ៊ុនតាក់” ប៉ុន្តែកម្លាំងខ្មែរក្រហមមិនបានចូលរួមបោះឆ្នោតទេ ដោយសារមិនមានការទុកចិត្តពីខាងរដ្ឋាភិបាល ។ ក្រោយពីបោះឆ្នោតចប់សព្វគ្រប់នៅឆ្នាំ១៩៩៥ កម្លាំងយោធាខាងរដ្ឋាភិបាលបានសហការជាមួយកម្លាំងកងទ័ពខាងគណបក្សហ៊្វុនស៊ិនប៉ិចមកវាយប្រយុទ្ធជាមួយយោធាខ្មែរក្រហមដឹកនាំដោយ តាម៉ុក រត់ឡើងភ្នំទាំងប្រជាជនទាំងយោធា ប៉ុន្តែខាងយោធាខ្មែរក្រហមមុននឹងរត់បានដុតឈើធំៗដែលមានតម្លៃរាប់សែនរាប់លានដុល្លាចោលទាំងអស់ ។ បន្ទាប់មកទៀតកម្លាំងយោធាខ្មែរក្រហម និងប្រជាជនចុះមករស់នៅតាមតំបន់ជើងភ្នំ និងបែកចែកភូមិជាច្រើនកន្លែងក្រោមការគ្រប់គ្រងរបស់តាម៉ុក ។ នៅពេលប្រជាជនចុះមកពីលើភ្នំក៏ចេះប្រកបមុខរបររកស៊ី ធ្វើស្រែចម្ការដោយខ្លួនឯង និងខ្វះខាតខ្លះ តាម៉ុក ជួយ ។

នៅឆ្នាំ១៩៩៧ ក្រុមខ្មែរក្រហមនៅស្រុកអន្លង់វែង លែងទុកចិត្តគ្នា ហើយមានទំនាស់ផ្ទៃក្នុងជាបន្តបន្ទាប់រហូតដល់ ប៉ុល ពត ចេញបញ្ជាឲ្យប្រធានកងពលឈ្មោះ សូរ សារឿន ទៅសម្លាប់គ្រួសារ សុន សេន ទាំងមូល ។ បន្ទាប់មកទៀត តាម៉ុក បានចាប់ សូរ សារឿន ចាប់ តាសាន និងបក្ខពួកមួយចំនួនទៀតយកទៅសម្លាប់ចោល ។ ក្រោយមកទៀត តាម៉ុក បានចាប់ ប៉ុល ពត កាត់ទោស ដោយហៅប្រជាជនមួយចំនួនធំឲ្យមកមើលការកាត់ទោស និងបានបកអាក្រាតរឿងរ៉ាវដែលសម្លាប់ប្រជាជននៅក្នុងជំនាន់ខ្មែរក្រហម ។

នៅឆ្នាំ១៩៩៨ តាម៉ុក មិនទុកចិត្តថ្នាក់ដឹកនាំមួយចំនួនដែលបានទាក់ទងជាមួយរដ្ឋាភិបាលខាងក្នុងមានឈ្មោះ ជុំ ជាតិ ឈ្មោះ សយ ឈ្មោះ រ៉ាយ ពីន ឈ្មោះ កែវ ជាដើម ។ តាម៉ុក បានហៅអ្នកទាំងអស់នេះមករៀនសូត្រផ្នែកនយោបាយនៅមន្ទីរ១៩ ដោយមានប្រធានមន្ទីរឈ្មោះ ខឹម ង៉ុន ហើយដោយសារតែប្រធានមន្ទីរជាខ្មែរក្រហមដូចគ្នា ធ្លាប់ចូលរួមចលនាដើម្បីប្រទេសជាតិដូចគ្នា ទើបធ្វើឲ្យប្រធានកងពលទាំងនេះមានភាពកក់ក្តៅបានមួយកម្រិត ។

មានថ្ងៃមួយ ខឹម ង៉ុន បានប្រើ ជុំ ជាតិ, កែវ, សយ, ពីន ឲ្យទៅប្រូតស្បូវដើម្បីយកមកទុកប្រក់រោង ឆ្លៀតពេលនោះអ្នកទាំងបួននាំគ្នាពិចារណាថា បើយើងមិនរត់នៅពេលនេះទេ យើងពិតជាត្រូវ តាម៉ុក សម្លាប់ក្នុងថ្ងៃណាមួយមិនខាន ដូចនេះមិនបង្អង់យូរទាំងអស់គ្នាបានទៅរកប្រពន្ធកូន និងប្រជាជនមួយចំនួននៅផ្ទះជិតគ្នារត់ចេញពីតំបន់ខ្មែរក្រហមទៅស្កាត់ជួបអភិបាលរងខេត្តព្រះវិហារឈ្មោះ ឃួយ ឃុនហួរ ។ លោកអភិបាលរងបានយកចិត្តទុកដាក់ ហើយ សយ និងអ្នកផ្សេងទៀតក៏សប្បាយចិត្តណាស់ដែរ ។ លុះស្អែកឡើងមានយន្តហោះមកពីភ្នំពេញ មកទទួលអ្នកទាំងបួនយកទៅភ្នំពេញ ។ ពេលទៅដល់ភ្នំពេញ សយ បានជួបជាមួយលោកឧត្តមសេនីយ៍ ជុំ ហាក់ លោកឧត្តមសេនីយ៍ ម៉ុល រឿម កាលនោះសម្រាកនៅផ្ទះសំណាក់ ហេង ឡាយ និងបានដើរលេងសប្បាយជាច្រើនថ្ងៃ ។

ក្រោយមក ខាងរដ្ឋាភិបាលមានគំនិតចង់បញ្ចប់សង្គ្រាមមិនចង់ឲ្យខ្មែរបង្ហូរឈាមគ្នាបន្តទៀត ក៏ចាត់តាំងឲ្យអ្នកទាំងបួននាក់សរសេរពាក្យមួយចំនួនក្នុងន័យថា បើបងប្អូនចុះចូលជាមួយរដ្ឋាភិបាល ខាងរដ្ឋាភិបាលមិនយកទោសពៃរ៍ទេ ដើម្បីអូសទាញប្រជាជននៅតំបន់ខ្មែរក្រហមឲ្យចូលមករស់នៅជាមួយរដ្ឋាភិបាល ។ ពេលនោះអ្នកទាំងបួននាក់ បានជិះយន្តហោះទៅបោះត្រាក់ក្នុងតំបន់ខ្មែរក្រហមរស់នៅ ។

នៅក្នុងឆ្នាំ១៩៩៨ ខាងស្រុកត្រពាំងប្រាសាទមានគំនិតធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលមុនខាងស្រុកអន្លង់វែង ។ ក្រោយមកខាងស្រុកអន្លង់វែង មាន យឹម ផាន់ណា, យឹម ពឹម, យឹម សាន ក៏បានធ្វើសមាហរណកម្មចុះចូលជាមួយរដ្ឋាភិបាលដែរ ។ នៅឆ្នាំ១៩៩៨-១៩៩៩ តំបន់ចុងក្រោយខ្មែរក្រហមនៅស្រុកអន្លង់វែង នៅស្រុកត្រពាំងប្រាសាទ បានធ្វើសមហរណកម្មចុះចូលជាមួយរដ្ឋាភិបាល ទើបប្រទេសជាតិលែងមានសង្គ្រាមមកដល់សព្វថ្ងៃ ។ សព្វថ្ងៃ ប្រជាជនរស់នៅស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទបានផ្លាស់ប្តូរមុខមាត់ថ្មី លែងភ័យព្រួយពីរឿងសង្គ្រាម ។ ប្រជាជនណាចង់ទៅរស់នៅ រកស៊ីកន្លែងណាក៏បាន មិនមាននរណាមកហាមឃាត់ទេ ។ ស្រុកអន្លង់វែងសព្វថ្ងៃ មានស្ពាន ថ្នល់ មានសាលារៀនគ្រប់កន្លែង មានមន្ទីរពេទ្យ មានផ្សារ មានសណ្ឋាគារ និងមានកន្លែងទេសចរណ៍ជាច្រើនកន្លែងទៀតកំពុងតែធ្វើការអភិវឌ្ឍជាបណ្តើរៗ ។

**សុខ ខណ្ណៈ**

# អតីតកម្មាភិបាលភូមិភាគកណ្តាលបានមករស់នៅអន្លង់វែង ដោយសារគេចពីកងទ័ពវៀតណាម

ស្ថិតក្នុងសម្លៀកបំពាក់អាវយឺតស្រអាប់ពណ៌ ស្លៀកក្រមាពណ៌លឿងឆ្នូតក្រហមអង្គុយនៅក្នុងខ្ទមប្រក់ស្លឹកត្នោត និងមានអង្រឹងឫស្សីនៅខាងក្រោយ អ៊ំប្រុសបានប្រាប់ខ្ញុំឲ្យដឹងថា គាត់មានឈ្មោះ កែ សោម អាយុ៧៧ឆ្នាំ កើតនៅភូមិទឹកឃ្លាំង ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ បច្ចុប្បន្ន សោម រស់នៅភូមិអូររុនឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ សោម បានរៀបរាប់បន្តថា គាត់បានឃ្លាតឆ្ងាយពីស្រុកកំណើត និងមករស់នៅក្នុងស្រុកអន្លង់វែងរហូតមកដល់សព្វថ្ងៃនេះ គឺដោយសារគាត់រត់ភៀសខ្លួនពីកងទ័ពវៀតណាម មកព្រំដែនកម្ពុជា-ថៃ នៅឆ្នាំ១៩៧៩ ។ សោម បានចូលធ្វើយោធាខ្មែរក្រហមប្រចាំនៅតាមព្រំដែនភាគខាងលិច និងបានផ្លាស់មករស់នៅតំបន់១០០៣ (តំបន់អន្លង់វែង) ដែលគ្រប់គ្រងដោយ តាម៉ុក រហូតដល់មានការធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៩៨ ។



កែ សោម នៅផ្ទះរបស់គាត់ នៅក្នុងភូមិអូររុន ស្រុកអន្លង់វែង ។

កាលពីក្មេង សោម បានបួសរៀននៅវត្តទឹកឃ្លាំងបានរយៈពេលបីវស្សា ។ លុះដល់ឆ្នាំ១៩៧០ ក៏បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរបដិវត្តន៍តាមការដឹកនាំរបស់ឈ្មោះ រាជ ដែលជាមេភូមិ ។ កាលនោះ ប្រជាជនភាគច្រើនមានការស្រឡាញ់ពេញចិត្តចំពោះការដឹកនាំរបស់សម្តេចព្រះ នរោត្តម សីហនុ តែមិនបានពេញចិត្តនឹងការធ្វើរដ្ឋប្រហាររបស់លោកសេនាប្រមុខ លន់ នល់ ឡើយ ។ នៅពេលចូលបម្រើក្នុងជួរបដិវត្តន៍ សោម បានចូលទៅព្រៃម៉ាគីដែលមានទីតាំងនៅក្នុងស្រុកសណ្តាន់ (ខាងក្បាលដំរី ជិតភ្នំដី) ។ នៅពេលដែលបំពេញការងារនៅទីនោះ សោម តែងបានឃើញវត្តមានរបស់មេដឹកនាំមួយចំនួនដូចជា ខៀវ សំផន, អៀង សារី, ហ៊ូ នឹម និង ហ៊ូ យន់ ។

ក្រោយពេលដែលខ្មែរក្រហមបានទទួលជ័យជម្នះទាំងស្រុងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ សោម ត្រូវបានអង្គការជម្លៀសឲ្យទៅរស់នៅភូមិផ្សេង ។ ចំណែក សោម ស្ថិតនៅក្នុងអង្គភាពពាណិជ្ជកម្ម ផ្នែកដឹកជញ្ជូនស្រូវ ដោយក្នុងមួយក្រុមមានសមាជិកចំនួន១២នាក់ និងមានរថយន្តចំនួន១២គ្រឿង ។ រថយន្តដឹកស្រូវទាំងនោះ ជារថយន្តនាំមកពីប្រទេសចិន ។ សោម នៅចាំថា រថយន្តមួយៗ ដឹកស្រូវបានចំនួនតែ១០បាវ យកទៅដាក់នៅរោងម៉ាស៊ីនកិនស្រូវនៅខេត្តកំពង់ចាម ។ បន្ទាប់ពីកិនបានជាអង្កររួចរាល់ហើយ ត្រូវដឹកអង្ករទាំងនោះមកឲ្យអង្គភាពយោធា ។

ក្នុងឆ្នាំ១៩៧៦ បន្ទាប់ពីធ្វើការនៅក្នុងអង្គភាពពាណិជ្ជកម្មផ្នែកខាងដឹកជញ្ជូនស្រូវបានមួយរយៈមក ដោយសារ សោម ពូកែហែលទឹក និងមានជំនាញខាងចែវទូកផងនោះ កែ ពក ដែលជាលេខាភូមិភាគកណ្តាលបានចាត់តាំង សោម ឲ្យមកធ្វើការខាងនេសាទត្រីនៅកំពង់ឆ្នាំងវិញ ក្រោមការដឹកនាំរបស់ឈ្មោះ នាង មកពីតំបន់៤១ ។ នៅពេលដែលអង្គភាពនេសាទផលិតបានជាត្រីងៀត ប្រហុក សោម ក៏បានដឹកជញ្ជូនត្រីងៀត ប្រហុកទាំងអស់

នោះតាមកាណូត យកមកដាក់នៅតាមឃ្លាំងមុំជ្រោយចង្វារក្រុងភ្នំពេញ ។

មួយរយៈកាលក្រោយមក កែ ពក បានចាត់តាំង សោម ឲ្យទៅនៅខាងទន្លេសាបជាមួយ តាយ៉ាន នៅក្នុងអង្គភាពនេសាទត្រីដដែល ។ ពេលនោះ សោម បានទទួលនាទីជាអនុប្រធានមើលការខុសត្រូវប្រជាជនធ្វើត្រីប្រហុក និងផ្អក ។ សោម បានបន្តឲ្យដឹងថា គាត់ធ្លាប់បានចូលរួមប្រជុំជាមួយ កែ ពក និងសមាជិកមួយចំនួនមកពីគណៈតំបន់៤១ និងតំបន់៤២ ។ នៅពេលប្រជុំ សោម បានរាយការណ៍ជូនថ្នាក់លើអំពីកិច្ចការនានាដែលអង្គភាពរបស់គាត់បានអនុវត្តកន្លងមក និងបន្ទាប់មកថ្នាក់លើក៏បានដាក់ផែនការថ្មីៗទៀត ដើម្បីយកទៅអនុវត្តបន្ត ។ ក្រោយមកទៀត សោម បានទទួលសំបុត្រពីពាណិជ្ជកម្មភូមិភាគ ដោយបានដាក់បទបញ្ជាឲ្យចាត់ចែងធ្វើត្រី ប្រហុកឲ្យបានសម្រេចតាមផែនការរបស់អង្គការដើម្បីចែកចាយត្រីប្រហុកទៅតាមភូមិភាគនានា តាមរយៈនីរសារឈ្មោះ ហេង និងឈ្មោះ ងួន ។ លុះពេលអង្គភាពរបស់ សោម ធ្វើត្រីប្រហុកបានសម្រេចតាមផែនការដែលបានកំណត់រួចហើយ សោម បានចាត់ចែងដឹកតាមរថយន្ត និងកាណូតមកចែកជូនតាមភូមិភាគ និងតំបន់នានាតាមការស្នើសុំ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ សោម បានសម្រេចចិត្តរត់គេចខ្លួនទៅប៉ៃលិនជាមួយយោធាខ្មែរក្រហមផ្សេងៗទៀត ហើយបានធ្វើដំណើររហូតទៅដល់ជំរំខាងអ៊ីដាវប្រទេសថៃ ដោយបានចំណាយពេលប្រហែលជាងកន្លះខែ ។ នៅអំឡុងឆ្នាំ១៩៨១-១៩៨២ សោម ត្រូវបានផ្លាស់ទៅនៅខាងយោធាការពារព្រំដែននៅបន្ទាយឆ្មារ និងនៅខេត្តបន្ទាយមានជ័យតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ក្រោយមក សោម មាននាទីដឹកជញ្ជូនគ្រាប់កាំភ្លើងយកមកឲ្យអង្គភាពយោធារបស់ តាម៉ុក នៅអន្លង់វែងដោយបានធ្វើដំណើរកាត់តាមស្រុកវ៉ារិន សៀមរាប និងស្រែណូយ ។ លុះដល់ឆ្នាំ១៩៨៥ សោម បានសម្រេចចិត្តឈប់ធ្វើការដឹកជញ្ជូនគ្រាប់ ហើយបានមករស់នៅជាមួយកងមីងៗនៅតំបន់អន្លង់វែង ។ មួយរយៈក្រោយមក សោម ក៏បានរៀបការប្រពន្ធនៅលើភ្នំ ១០០៣ ដែលពិធីរៀបមង្គលការនេះថ្នាក់លើជាអ្នករៀបចំឲ្យ ។ លុះក្រោយមកទៀតក្នុងឆ្នាំ១៩៩៨ នៅពេលដែលខ្មែរក្រហមបានធ្វើសមាហរកម្មចុះចូលជាមួយរាជរដ្ឋាភិបាល សោម បានសម្រេចចិត្តវិលត្រឡប់មករស់នៅក្នុងភូមិអូររុនជាមួយក្រុមគ្រួសារកសាងជីវិតសារជាថ្មីរហូតមកដល់សព្វថ្ងៃនេះ ។

**ស៊ិន សុធីតា**



កងនេសាទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ។

# ភូមិទួលសាលាដែល ហែម ឃិន មករស់នៅដំបូង

“ភូមិទួលសាលា” មានន័យថាមានដីទួលខ្ពស់មួយកន្លែងនៅចុងភូមិខាងលិច ជាប់នឹងភូមិឯកភាពបច្ចុប្បន្ន ហើយនៅលើទួលនោះមានសាលារៀនមួយខ្នងធ្វើពីឈើតាំងពីសម័យខ្មែរក្រហម ។ សាលានេះបានសាងសង់ឡើងដោយអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ ។ ដោយមូលហេតុនេះហើយ ទើបគណៈគ្រប់គ្រងនៅអន្លង់វែង បានជួបប្រជុំគ្នាហើយបានសម្រេចចិត្តដាក់ឈ្មោះភូមិនេះថា “ភូមិទួលសាលា” ។

កាលដើមឡើយភូមិទួលសាលានេះ ត្រូវបានហៅថា ភូមិ ៨០០ ព្រោះកងពល៨០០ បានមកគ្រប់គ្រងនៅទីនេះ ។ ចុងឆ្នាំ ១៩៩០ ដោយសភាពការណ៍ក្នុងប្រទេសនៅមិនទាន់មានសន្តិភាពនៅឡើយ ដូច្នេះពេលណាស្រុកភូមិមានសភាពការណ៍អសន្តិសុខ (កងកម្លាំងរបស់រដ្ឋាភិបាលវាយប្រហារយោធាខ្មែរក្រហម) ប្រជាជនក៏នាំគ្នារត់ទៅជំរំអូរត្រាវ (ទឹកដីថៃ) ក្រោមការគ្រប់គ្រងរបស់ឈ្មោះ ធិន ជាជនជាតិទំពួន ។ លុះដល់ឆ្នាំ១៩៩៩ ប្រជាជនបាននាំគ្នាចាកចេញពីជំរំអូរត្រាវ មកតាំងទីលំនៅនៅទីនេះ ដោយសារភូមិសាស្ត្រនៅទីនេះមានសភាពស្ងប់ស្ងាត់ ។ បន្ទាប់មក អ្នកភូមិបានពិភាក្សាគ្នា ហើយបានមូលមតិគ្នាដាក់ឈ្មោះឲ្យភូមិនេះថា “ភូមិត្រពាំងប្រិយ៍” ។ ប៉ុន្តែការដាក់ឈ្មោះឲ្យភូមិមួយនេះថាជាភូមិត្រពាំងប្រិយ៍ មិនបានសម្រេចដូចការគិតនោះទេ ព្រោះឈ្មោះត្រពាំងប្រិយ៍នេះ ត្រូវបានយកមកប្រើសម្រាប់ដាក់ឲ្យឈ្មោះរបស់ឃុំវិញ គឺឃុំត្រពាំងប្រិយ៍សព្វថ្ងៃ ។ មកដល់ឆ្នាំ២០០០ ដោយមានការបែងចែកភូមិឃុំសារជាថ្មី រាជរដ្ឋាភិបាលក៏បានសម្រេចរៀបចំបង្កើតភូមិមួយនេះដោយបានដាក់ឈ្មោះថា “ភូមិទួលសាលា” នេះបើយោងតាមបទសម្ភាសជាមួយលោកអ៊ំ ហែម ឃិន ជាប្រធានភូមិទួលសាលាបច្ចុប្បន្ន ។

ភូមិទួលសាលា ជាភូមិមួយក្នុងចំណោមភូមិទាំង៦៨ របស់



ហែម ឃិន នៅផ្ទះរបស់គាត់ស្ថិតនៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ស្រុកអន្លង់វែង ។ ភូមិនេះមានព្រំប្រទល់ខាងលិចជាប់នឹងភូមិឯកភាព ខាងកើតជាប់នឹងផ្លូវជាតិលេខ៦៧ ខាងជើងជាប់នឹងភូមិជើងភ្នំ និងខាងត្បូងជាប់នឹងភូមិឃ្លាំងកណ្ដាល ហើយនៅខាងជើងឆៀងខាងលិចចុងភូមិ មានស្រះអូរជីកមួយយ៉ាងធំ និងនៅចំកណ្ដាលភូមិទួលសាលានេះ ក៏មានស្រះឈូកធំមួយដែរ ។

ក្រោយមក ដោយមានជំនួយឧបត្ថម្ភពីមូលនិធិសហភាពអឺរ៉ុប ខាងអាជ្ញាធរបានយកគ្រឿងចក្រមកកាយបាតស្រះឲ្យមានជម្រៅជ្រៅជាងមុន និងមានទំហំធំជាងមុន ។ បន្ទាប់ពីខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលមក ហេដ្ឋារចនាសម្ព័ន្ធនានារបស់ភូមិទួលសាលា ហាក់មានការអភិវឌ្ឍគួរឲ្យកត់សម្គាល់ ដូចជា ការកសាងសាលារៀនថ្នាក់បឋម ថ្នាក់អនុវិទ្យាល័យ ការកសាងផ្លូវជាតិធំជាងមុនទៅកាន់ខេត្តព្រះវិហារ ត្រពាំងប្រាសាទ ការកសាងមន្ទីរពេទ្យ និងវត្តអារាមជាច្រើនដែលក្នុងសម័យសង្គ្រាមមិនដែលមានការអភិវឌ្ឍដូច្នេះទេ ។

ខ្ញុំបានធ្វើដំណើរចេញពីទីរួមស្រុកអន្លង់វែងតាមផ្លូវជាតិលេខ៦៧ ហើយបត់ស្ដាំចូលតាមផ្លូវដីក្រហមធំមួយទៅកាន់ភូមិទួលសាលា ។ ភូមិនេះមានចម្ងាយជាង២០គីឡូម៉ែត្រពីទីរួមស្រុកអន្លង់វែង ។ ផ្លូវចូលភូមិមានសភាពលំបាកដោយអន្ទើ ព្រោះមានការដ្ឋានដែលកំពុងធ្វើការសាងសង់ស្ពានច្រើនកន្លែងតាមបណ្ដោយផ្លូវ ។ ពេលខ្ញុំមកដល់ភូមិទួលសាលា ខ្ញុំចាប់អារម្មណ៍ថា នៅក្នុងភូមិទាំងមូលហាក់មានសភាពស្ងប់ស្ងាត់ ។ បន្តិចក្រោយមកទើបខ្ញុំដឹងថា អ្នកភូមិមួយចំនួនធំបានចេញទៅប្រមូលផលដំឡូង ព្រោះជារដូវប្រមូលផល ។ ចំណែកអ្នកខ្លះទៀត ចេញទៅធ្វើចម្ការដាំពោតដំឡូង និងស្រូវ ។

បន្ទាប់មក ខ្ញុំក៏បានជួបជាមួយអ៊ុំប្រុសម្នាក់ដែលសព្វថ្ងៃគាត់ធ្វើជាប្រធានភូមិទួលសាលានេះ និងបានសួរនាំគាត់ពីរឿងរ៉ាវដែលបានកើតឡើងក្នុងជីវិតរបស់គាត់ពីដើមរៀងមក ។ អ៊ុំប្រុសបាននិយាយប្រាប់ខ្ញុំថា គាត់មានឈ្មោះ ហែម ឃិន បានធ្វើជាមេភូមិទួលសាលានេះតាំងពីឆ្នាំ២០០៦មកម្ល៉េះ ។ ឃិន មានអាយុ៧១ឆ្នាំ (កើតក្នុងឆ្នាំ១៩៤៧) នៅភូមិទួលទ្រា ឃុំជប់ ក្រុងសួង ខេត្តកំពង់ចាម ។ ឃិន មានឪពុកឈ្មោះ ហែម សែន (ស្លាប់) ម្ដាយឈ្មោះ កុល ម៉ៅ (ស្លាប់) និងមានបងប្អូនចំនួនប្រាំមួយនាក់ ស្រីបីនាក់ប្រុសបីនាក់ ។ គាត់បានរៀបការនៅក្នុងឆ្នាំ១៩៦៨ ជាមួយប្រពន្ធឈ្មោះ អែង អ៊ី បច្ចុប្បន្នមានកូនចំនួនប្រាំមួយនាក់


ផ្លូវទៅភូមិទួលសាលា ស្ថិតនៅក្នុងឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ប្រុសបីនាក់ និងស្រីបីនាក់ ។

ឆ្នាំ១៩៦៥ ឃិន បានចូលរៀននៅសាលាមេមត់ត្រឹមថ្នាក់ទី៧ចាស់ ។ លុះក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ គាត់ក៏ឈប់រៀន ហើយមករស់នៅជាមួយបងប្រុសធ្វើជាកម្មករចៀរជ័រកៅស៊ូនៅមេមត់ ។ ឃិន បានរៀបរាប់ថា នៅចុងឆ្នាំ១៩៧០ ការវាយប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងកងទ័ពវៀតណាមនៅឯបានលុងក្នុងខេត្តរតនគិរីបានផ្ទុះឡើង ។ ស្របពេលនោះដែរ សម្តេចព្រះនរោត្តម សីហនុ ក៏បានអំពាវនាវឲ្យកូនចៅចូលព្រៃម៉ាគីនៅខេត្តរតនគិរី ដើម្បីតស៊ូវាយរំដោះយកទឹកដីមកវិញ ។ ឃិន បានបន្តថា សភាពការណ៍នៅពេលនោះ មានភាពច្របូកច្របល់ ព្រោះម្យ៉ាងប្រជាជនខ្លាចវៀតណាមកៀរយកទៅ ហើយម្យ៉ាងទៀតខ្លាចកងទ័ព លន់ នល់ ចាប់ខ្លួន ។ ក្រោយមក ស្រុកបានលុងក៏ត្រូវបានរំដោះមកវិញ ។ ក្រោយព្រឹត្តិការណ៍បានស្ងប់ស្ងាត់ ឃិន ក៏ត្រូវបានបញ្ជូនឲ្យមករស់នៅ និងធ្វើស្រែនៅក្នុងភូមិកំពង់សង្គម ស្រុកបានលុង ខេត្តរតនគិរី ។

មកដល់ឆ្នាំ១៩៧៥ ឃិន បានរស់នៅក្នុងសហករណ៍ភូមិត្រពាំងក្រហម ដោយពេលនោះខ្មែរក្រហមបានប្រើឲ្យគាត់ធ្វើស្រែរួម និងហូបចុកជាសមូហភាព ។ ខ្មែរក្រហមបានប្រើឲ្យប្រជាជនធ្វើការងារចាប់ពីម៉ោង៥ព្រឹក ដល់ម៉ោង១១ថ្ងៃ ទើបសម្រាកដើម្បីហូបបាយថ្ងៃត្រង់ និងចុះធ្វើការបន្តទៀតនៅម៉ោង១រសៀល រហូតដល់ម៉ោង៥ល្ងាច ។ នៅពេលយប់ តាមក្រុមនីមួយៗមានការប្រជុំនិយាយពីការងារបង្កបង្កើនផល ធ្វើស្រែចម្ការ ដែលបានធ្វើនាពេលកន្លងមក ។ ឃិន បានបន្តថា នៅក្នុងសហករណ៍របស់គាត់ ប្រជាជនមិនត្រូវបានខ្មែរក្រហមបង្ខិតបង្ខំឲ្យធ្វើការងារធ្ងន់ ឬធ្វើបាបទេ ប៉ុន្តែស្របពេលនោះដែរ នៅកន្លែងផ្សេងៗតែងមានលេចព្ញព័ត៌មានថា ខ្មែរក្រហមបានធ្វើបាបប្រជាជនដោយបង្ខំឲ្យធ្វើការងារធ្ងន់ និងផ្តល់របបហូបចុកមិនគ្រប់គ្រាន់ជាដើម ។

ឆ្នាំ១៩៧៦ ឈ្មោះ ខាត គណៈតំបន់គ្រប់គ្រងសហករណ៍ក្នុងស្រុកបានលុង ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូនមកភ្នំពេញ ។ ចំណែក ឃិន ដែលជាប្រជាជនធម្មតាត្រូវនៅធ្វើស្រែតាមសហករណ៍ និងហូបបាយជាសមូហភាពដដែល ។ លុះដល់ចុងឆ្នាំ១៩៧៨ ទើបគាត់នាំគ្នារត់ចេញពីសហករណ៍ទៅរស់នៅក្នុងព្រៃនៃខេត្តរតនគិរី ។ ការរស់នៅទីនោះមិនមានលក្ខខណ្ឌល្អប្រសើរប៉ុន្មានទេ ព្រោះគាត់ត្រូវរស់នៅក្នុងខ្ទមតូចៗ ដើររុករកជីកមើមក្តួចនៅក្នុងព្រៃយកមកហូប ហើយក៏គ្មានអំបិលសម្រាប់ហូបគ្រប់គ្រាន់ដែរ ។ ទោះជាយ៉ាងនេះក្តី ឃិន និងអ្នកផ្សេងៗទៀតដែលមានគ្នាពី៥០០ ទៅ ១.០០០នាក់ ត្រូវបង្ខំចិត្តបន្តរស់នៅក្នុងព្រៃរហូតដល់ឆ្នាំ១៩៨៧-១៩៨៨ ទើបបានបន្តដំណើរដោយថ្មើរជើងដែលត្រូវប្រើរយៈពេលបីខែទើបទៅដល់ជំរំប្រេងខ្យល់ និងជំរំអូរត្រាវក្នុងទឹកដីថៃ ។

ពេលទៅដល់ជំរំ ឃិន និងអ្នកដទៃទៀតបានទទួលរបបប្រចាំខែដោយក្នុងម្នាក់ៗទទួលបានអង្ករ១២គីឡូក្រាម ត្រីកាម៉ុង ត្រីខកំប៉ុង ចំណែកទីកន្លែងស្នាក់នៅត្រូវធ្វើផ្ទះតូចៗដោយខ្លួនឯង ។ នៅក្នុងជំរំ ប៉ូលីសថៃតែងចូលមកមើលការខុសត្រូវលើប្រជាជនជាប្រចាំ ។ ឆ្នាំ១៩៨៩ ឃិន បានចេញពីដីថៃ ហើយបានមករស់នៅក្នុងតំបន់៨០០ (ជាជំរំរបស់កងពល៨០០ ហើយដែលសព្វថ្ងៃក្លាយជាភូមិទួលសាលា) ។ ឃិន បានវាតយកដីដើម្បីសាងសង់លំនៅដ្ឋាន និងធ្វើស្រែ ធ្វើចម្ការ ដាំដំណាំដើម្បីចិញ្ចឹមជីវិត ។ ពេលនោះ សភាពការណ៍ក្នុងប្រទេសនៅមិនទាន់មានសន្តិភាពនៅឡើយទេ ពេលណាស្រុកភូមិមានសភាពការណ៍មិនស្រួល (កងកម្លាំងរបស់រដ្ឋាភិបាលវាយប្រហារយោធាខ្មែរក្រហម) ឃិន ក៏នាំគ្នារត់ទៅជំរំអូរត្រាវវិញ ស្របពេលនោះខ្មែរក្រហមក៏បានឃោសនាប្រាប់ប្រជាជនថា បើមិនរត់ប្រយ័ត្នគេសម្លាប់ ។ ហេតុនេះ ប្រជាជនតែងតែនាំគ្នារត់តាមយោធាខ្មែរក្រហម ។ លុះក្រោយពេលសភាពការណ៍មានភាពស្ងប់ស្ងាត់ ប្រជាជនក៏បាននាំគ្នាចុះមកតំបន់៨០០វិញ ។

នៅឆ្នាំ១៩៩៨ ខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ពេលនោះប្រទេសជាតិ និងប្រជាជននៅទូទាំងប្រទេសក៏បានទទួលនូវសុខសន្តិភាពពេញបរិបូរណ៍ ។ ដោយឡែក ឃិន ក៏បានវិលត្រឡប់មករស់នៅក្នុងតំបន់៨០០វិញ ហើយតំបន់៨០០ បានប្រែក្លាយទៅជាភូមិទួលសាលា ស្ថិតនៅក្នុងឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងបានប្រកបរបររកស៊ីធ្វើស្រែចម្ការរហូតដល់សព្វថ្ងៃ ។

**ចៅ ព្រហស្បតិ៍**

# អតីតកម្មកររោងចក្រកាត់ដេរក្លាយជាប្រធានភូមិថ្នល់កែង


ប៊ូ ចាន់ណា មេភូមិថ្នល់កែង

ប៊ូ ចាន់ណា ភេទស្រី ជាជនជាតិលាវ មានស្រុកកំណើតនៅភូមិដីមៀត ឃុំណងឃីលិក ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។ ចាន់ណា មានឪពុកឈ្មោះ ប៊ូ និងម្ដាយឈ្មោះ ម៉ុន ហើយមានបងប្អូនស្រីបង្កើត២នាក់ និងមានប្ដីឈ្មោះ កុយ ធួន (ជាប្រធានសហគមន៍ព្រៃឈើនៅភូមិថ្នល់កែង ក្នុងស្រុកត្រពាំងប្រាសាទ) ព្រមទាំងមានកូន៤នាក់ ។

សព្វថ្ងៃ ចាន់ណា និងគ្រួសាររស់នៅក្នុងភូមិថ្នល់កែង ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។ កាលពីឆ្នាំ១៩៦៩ ចាន់ណា បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅខេត្តមណ្ឌលគិរី ដោយមានការអប់រំពីឈ្មោះ តាឡាំង មាននាទីជាកម្មាភិបាលតំបន់ ។ ពេលនោះ ចាន់ណា បានរត់ចូលព្រៃដើម្បីជួយដឹកជញ្ជូនចម្រូង និងស្បៀងផ្សេងៗដល់យោធាខ្មែរក្រហម ។ រីឯការហូបចុកនៅក្នុងព្រៃ ចាន់ណា ទទួលបានត្រឹមតែបាយលាយជាមួយដំឡូង និងអង្ករមួយគ្រាប់ៗប៉ុណ្ណោះ ។

នៅឆ្នាំ១៩៧២ ចាន់ណា បានចេញពីខេត្តមណ្ឌលគិរី ទៅរស់នៅខេត្តកំពង់ចាម រៀនខាងកាត់ដេរ ។ ចាន់ណា រស់នៅទីនោះរហូតដល់កងទ័ពខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥ ។ ក្រោយមក ចាន់ណា ត្រូវបានអង្គការបញ្ជូនមកទីក្រុងភ្នំពេញ ហើយចាត់តាំងឲ្យធ្វើជាកម្មកររោងចក្រកាត់ដេរនៅក្បែរផ្សាររុស្សី (មិនចាំឈ្មោះរោងចក្រ) ។ កាលនោះ ប្រធានគ្រប់គ្រងរោងចក្រឈ្មោះយាយ ស៊ូ ។ កាលដែលធ្វើនៅរោងចក្រកាត់ដេរ ចាន់ណា មិនដែលមានពេលទំនេរដើរហើរទៅកន្លែងណាផ្សេងឡើយ ព្រោះការងារធ្វើពីព្រលឹមទល់ព្រលប់ ស្ទើរតែគ្មានពេលសម្រាកក្នុងមួយថ្ងៃៗ ។

នៅចុងឆ្នាំ១៩៧៥ ចាន់ណា ត្រូវបានអង្គការផ្លាស់មកខាងមូលដ្ឋានស្ទឹងត្រែង និងក្រចេះ មាននាទីបង្ហាត់បង្រៀនប្រជាជននៅក្នុងកងឲ្យចេះដេរខោអាវ ។ ក្រៅពីការងារទាំងនេះ ចាន់ណា ត្រូវបានអង្គការចាត់តាំងឲ្យចូលផ្នែកសិល្បៈ ដែលមានសមាជិកក្រុម១៥០នាក់ ។ កាលនោះ ចាន់ណា រៀនច្រៀងបទបដិវត្តន៍ខ្មែរក្រហម មានដូចជា ចម្រៀងចាក់ចម្រូង បូតស្រូវ កាន់កាំភ្លើង ឬចម្រៀងបាញ់ខ្មាំងជាដើម ។

នៅឆ្នាំ១៩៧៧ ចាន់ណា ត្រូវបានអង្គការជម្លៀសទៅស្រុកបានលុង ក្នុងខេត្តរតនគិរី ហើយឲ្យគាត់ចូលជាកងចល័តវិញ ។ ពេលនោះ ចាន់ណា មាននាទីដឹកប្រឡាយលើកទំនប់ ។ ចាន់ណា បន្តថា កាលដែលធ្វើការលើកទំនប់មានការលំបាកខ្លាំងជាងការងារមុនៗ ដោយសារវាជារដូវប្រាំងការកាប់ដីលើកទំនប់ជួបបញ្ហាជាច្រើនដូចជា អាកាសធាតុក្ដៅ ដីរឹង និងគ្មានទឹកផឹកគ្រប់គ្រាន់ទៀតផង ។ មិនត្រឹមតែប៉ុណ្ណោះ ចាន់ណា ត្រូវក្រោកពីព្រលឹមធ្វើការរហូតទល់យប់ ។ ចាន់ណា បញ្ជាក់ថា ក្រៅពីការងារលើកទំនប់នេះ អង្គការតែងហៅប្រជាជនទាំងអស់មកប្រជុំក្នុងមួយថ្ងៃបួនដង ដោយពិភាក្សាគ្នាអំពីការងារលើកទំនប់ ។

ចាន់ណា រស់នៅខេត្តរតនគិរី រហូតដល់កងទ័ពវៀតណាម

វាយទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៩ ។ បន្ទាប់មក ចាន់ណា បានរត់ភៀសខ្លួនមករស់នៅក្នុងជំរំភូណយ (ក្នុងខេត្តស៊ីសាកេត ប្រទេសថៃ) ។

រហូតដល់ឆ្នាំ១៩៩០ ចាន់ណា ចុះមករស់នៅក្នុងភូមិ១០៥វិញ ។ ចាន់ណា បានបន្តថា កាលដែលមកដល់ភូមិ១០៥ដំបូង វាពិតជាពិបាករស់នៅខ្លាំងណាស់ដោយសារខ្វះទឹកប្រើប្រាស់ ហើយគាត់ក៏មិនអាចបង្កបង្កើនផលបានដែរ ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ក៏ការរស់នៅភូមិ១០៥ នៅតែល្អប្រសើរជាងរបបខ្មែរក្រហមដែរ (១៩៧៥-៧៩) ពីព្រោះមាន តាម៉ុក ជាអ្នកផ្គត់ផ្គង់របបអាហារ សម្លៀកបំពាក់ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃទៅដល់ប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់គាត់ ។

នៅឆ្នាំ១៩៩៨ ខ្មែរក្រហមបានធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល ចាន់ណា ពិតជាមានអារម្មណ៍រំភើបយ៉ាងខ្លាំង ដោយគាត់យល់ថា ស្រុកទេសមានការបង្រួបបង្រួមមានសុខសន្តិភាព ប្រជាជនអាចប្រកបរបររកស៊ី អាចដើរហើរពីតំបន់មួយទៅតំបន់មួយដោយគ្មានការព្រួយបារម្ភអ្វីឡើយ ។

នៅឆ្នាំ២០០៧ ចាន់ណា បានក្លាយជាមេភូមិថ្មល់កែង ហើយក៏ជាពេលដែលគាត់ត្រូវខំប្រឹងរៀនអក្សរឡើងវិញដែរ រហូតដល់គាត់អាចអានបាន និងសរសេរបានមកដល់សព្វថ្ងៃនេះ ។ មកដល់ឆ្នាំ២០១០ ទើប ចាន់ណា បានទៅលេងស្រុកកំណើតរបស់គាត់ ហើយគាត់ក៏មិនអាចចាំអំពីមុខមាត់សាច់ញាតិរបស់គាត់បានសូម្បីតែម្នាក់ ពីព្រោះគាត់បានបែកពីគ្រួសារតាំងតែពីអាយុ១២ឆ្នាំ ។ ប៉ុន្តែឪពុកម្តាយ និងសាច់ញាតិបងប្អូនរបស់គាត់នៅតែចំណាំមុខមាត់របស់គាត់បាន ។

ក្រោយពេល ចាន់ណា បានទៅដល់ស្រុកកំណើតគាត់ សាច់ញាតិបងប្អូនពិតជាត្រេកអរណាស់ ពីព្រោះពួកគាត់មិននឹកស្មានថា ចាន់ណា នៅមានជីវិតរស់នៅឡើយ ដោយសារ ចាន់ណា ដាច់ការទាក់ទងតាំងតែពីរបបខ្មែរក្រហមកាន់កាប់អំណាចម្ល៉េះ ។ ចាន់ណា ទៅលេងស្រុកកំណើតអស់មួយរយៈពេលខ្លី រួចហើយក៏បានវិលត្រឡប់មកជួបជុំគ្រួសាររបស់គាត់នាពេលបច្ចុប្បន្នវិញ នៅស្រុកត្រពាំងប្រាសាទ ក្នុងខេត្តឧត្តរមានជ័យ ។

**ហួ ផុនា**



អតីតផ្ទះរបស់ តាម៉ុក នៅក្នុងបឹងអន្លង់វែង បច្ចុប្បន្នសារមន្ទីរតាម៉ុក ឬអន្លង់វែង ។

# អំណះអំណាងមេធាវីការពារក្តីរបស់ នួន ជា ក្នុងការមិនបញ្ចប់សវនាការសួរដេញដោលនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

***(តពីលេខមុខ)***

ដំណើរដើម និងចុងរឿងរបស់សត្វក្រពើ គឺមិនត្រឹមតែជាការរកកាយប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយនោះទេ ប៉ុន្តែវាជាផ្នែកសំខាន់ដែលតុលាការត្រូវពិចារណាដោយហ្មត់ចត់ ព្រោះវាអាចជម្រះនូវបទឧក្រិដ្ឋដែលតុលាការបានចោទប្រកាន់ទៅលើ នួន ជា ហើយវាក៏អាចបកស្រាយបំភ្លឺនូវចំណុចសំខាន់ដែលជាប់ទាក់ទងទៅនឹងបញ្ហាទំនួលខុសចំពោះសហឧក្រិដ្ឋកម្មរួមជាមូលដ្ឋាន ។ ចំពោះការចោទប្រកាន់ នួន ជា គឺមិនទាន់បានបញ្ជាក់ច្បាស់នោះទេ ព្រោះភ័ស្តុតាងនានានៅមានភាពទន់ខ្សោយ និងមិនមានភាពច្បាស់លាស់នៅឡើយ ។ ខណៈណាដែលគេមិនទាន់មានភ័ស្តុតាងជាក់លាក់ដើម្បីចោទប្រកាន់ទៅលើ នួន ជា នោះ នួន ជា នឹងមិនទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលគេបានចោទប្រកាន់នោះទេ ។

មេធាវី កុប៉េ បានលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិ បានតវ៉ាថា នេះគឺជាសហឧក្រិដ្ឋកម្មរួម ព្រោះ ប៉ុល ពត, នួន ជា រួមទាំង ខៀវ សំផន ធ្លាប់រួមគុបាយជាមួយគ្នា ។ បើទោះបីជាសហព្រះរាជអាជ្ញាធ្លាប់តវ៉ាថា វាមិនមែនជារឿងត្រឹមត្រូវក្នុង



រូបពាក់វ៉ែនតាខ្មៅ នួន ជា នៅបន្ទប់សវនាការ (រូបថត៖អ.វ.ត.ក) ។

ការដាក់គុកមនុស្សដែលធ្លាប់តែមានទំនាក់ទំនងគ្នាជាទូទៅ ក៏ប៉ុន្តែពេលនេះគេបែរជាបង្វែរវិញថា ការរួមគុបាយជាមួយគ្នាអាចបង្ហាញនូវគោលបំណងក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មរួមគ្នា ហើយក៏ជាសកម្មភាពនៃការបង្កបង្កើតសហឧក្រិដ្ឋកម្មរួមផងដែរ ។ ពិតណាស់ ការតវ៉ាមួយនេះគឺ មានភាពផ្ទុយគ្នាទាំងស្រុង ហើយភស្តុតាងទៀតសោតគឺមានលក្ខណៈផ្ទុយ និងមិនសូវមានទម្ងន់នោះទេ ។

ជាចុងបញ្ចប់ មេធាវី កុប៉េ បានលើកឡើងអំពីសារសំខាន់ផ្លូវច្បាប់ចំពោះរឿងសត្វក្រពើ ។ ជាពិសេសជាងនេះទៅទៀត រឿងសត្វក្រពើដែលទាក់ទងនឹងការកាត់ទោសមួយនេះមិនបានបង្ហាញអំពីគោលបំណងរួមនោះទេ ។ ជាការពិត សមាជិករាយរងរបស់ក្រុមសហឧក្រិដ្ឋកម្មរួម ធ្លាប់មានគំនិតប៉ុនប៉ងបង្កភាពអន្តរាយ ទៅដល់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលជារដ្ឋាភិបាលស្របច្បាប់នាសម័យនោះ ។ ទោះបីជាគោលបំណងរួមនៃការធ្វើបដិវត្តន៍សង្គមនិយម និងការការពារត្រូវបានគេរកឃើញពេលអនុវត្ត ប៉ុន្តែយើងមិនអាចចាត់ទុកថា គោលការណ៍នេះមានភាពទាក់ទងនឹងសហឧក្រិដ្ឋកម្មរួមនោះទេ ។ ការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវតែកំណត់បទឧក្រិដ្ឋមួយនេះដោយ យោងទៅតាមច្បាប់ជាគោល ហើយ នៅទីនេះទៀតសោត មិនមែនជាកន្លែងដែលតុលាការសម្រេចក្តីដោយផ្អែកតែទៅតាមមនោគមវិជ្ជានយោបាយនោះទេ ។

ការធ្វើរដ្ឋប្រហារបានបញ្ជាក់ថា វាមិនមែនជាល្បោនដែលត្រូវបានគេសម្តែងនោះទេ ។ សកម្មភាពទាំងនោះបានធ្វើឡើងដោយរនុកក្នុងរបស់វៀតណាម បន្ថែមពីនេះទៀត ប៉ុល ពត, នួន ជា និងមេដឹកនាំផ្សេងៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនបានទទួលដំណឹង ឬបានបញ្ជាឲ្យក្រុមនោះធ្វើសកម្មភាពខាងលើទេ ។ យើងមានភស្តុតាងដែលអាចបញ្ជាក់ថា សហឧក្រិដ្ឋកម្មរួមរបស់ក្រុមនោះ គឺធ្វើឡើងដោយក្រុមផ្សេងទៀតដែលមានបំណងទម្លាក់កំហុសមកលើរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារភាពមិនស្កប់ស្កល់របស់ពួកគេ ។ រឿងក្រពើនេះ បានបង្ហាញពីកង្វះខាតនូវអំណាចក្នុងការគ្រប់គ្រងរបស់ នួន ជា ក៏ដូចជាទំនាក់ទំនងរវាងមេដឹកនាំ និងបុគ្គលថ្នាក់ក្រោមដែលមានចិត្តមើលស្រាលរបបនេះ ។ យោងទៅតាមហេតុផលនេះ យើងអាចបកស្រាយថា នួន ជា មិនមែនជាជននៅពីក្រោយទេ ហើយគាត់ក៏មិនមែនជាថ្នាក់លើអ្វីនោះដែរ ។

មេធាវី កុប៉េ បាននិយាយថា ក្រុមការងាររបស់គាត់នឹងបកស្រាយអំពី ហេតុអ្វីបានជាការចាប់ខ្លួន និងឃុំខ្លួននៅមណ្ឌលឃុំឃាំងមានភាពស្របច្បាប់? បន្ទាប់មក មេធាវី កុប៉េ បានស្នើឲ្យមេធាវី លីវ សុវណ្ណា ធ្វើការបកស្រាយបន្ត ។

## ការការពារជាតិ និងនយោបាយសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា

មេធាវី លីវ សុវណ្ណា បានធ្វើបទបង្ហាញអំពីការការពារជាតិ រួមជាមួយនយោបាយសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ។ មេធាវី លីវ សុវណ្ណា បាននិយាយថា គាត់នឹងលើកឡើងពីការកាត់ទោសដែលបានពិភាក្សាកាលពីដើមសប្តាហ៍នេះ រួមជាមួយគោលនយោបាយដែលសត្រូវបានប្រើប្រាស់ ។

មេធាវី លីវ សុវណ្ណា និយាយថា ជាការពិតគោលនយោបាយរបស់សត្រូវដែលគេបានលើកឡើងគឺមិនពិតនោះទេ ។ ដោយឡែក អ្វីដែលបក្សកុម្មុយនីសបានណែនាំគឺ គោលនយោបាយការពារជាតិ និងសន្តិសុខជាតិ ដែលត្រូវបានគេប្រើប្រាស់ទូទៅជុំវិញសកលលោកមកទល់សព្វថ្ងៃ ហើយជាពិសេសយើងនឹងបង្ហាញថា វាមានលក្ខណៈត្រឹមត្រូវ និងស្របច្បាប់ផងដែរ ។

មេធាវី លីវ សុវណ្ណា បានថ្លែងបន្តថា ការកាត់ទោសនេះគឺវាយតម្លៃគោលការណ៍សន្តិសុខជាតិរបស់ខ្មែរក្រហមដោយផ្អែកតែទៅតាមរឿងនិទានកុហកទាំងស្រុង ។ គេបានបកស្រាយថា បក្សកុម្មុយនីស្តកម្ពុជា គឺពោរពេញទៅដោយភាពឃោរឃៅ ឈាមរាវ និងជាក្រុមមានជំងឺសរសៃប្រសាទយ៉ាងធ្ងន់ធ្ងរ ដែលចូលចិត្តសម្លាប់ប្រជាជនខ្មែរ ។ ទោះបីជាយ៉ាងណា រឿងនេះត្រូវបានគេនិយាយតៗគ្នាពីបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែមិនមានភស្តុតាងណាអាចបញ្ជាក់ថា ការលើកឡើងមួយនេះគឺជារឿងពិត និងត្រឹមត្រូវនោះទេ ។ យើងយល់ថា ហេតុផលនេះគឺធ្វើឡើងដើម្បីឲ្យស័ក្តិសមតែជាមួយការចោទប្រកាន់របស់គេតែប៉ុណ្ណោះ ។ មេធាវី លីវ សុវណ្ណា បន្ថែមថា ការកាត់ទោសធ្វើឡើងបែបនេះ ព្រោះគេចង់បន្ថែមអត្ថន័យទៅកាន់ពាក្យ "សត្រូវ" ដែលបានប្រើប្រាស់ដោយបុគ្គលមកពីបក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងនោះ គេចង់បន្ថែមថា ប្រជាជនដែលរស់រានមានជីវិតពីកម្ពុជាប្រជាធិបតេយ្យ

ត្រូវបានបក្សរាប់បញ្ចូលថា ជាសត្រូវ ក៏ប៉ុន្តែ វាមិនបានកើតឡើងទេបើយោងទៅតាមស្ថានភាពជាក់ស្តែង ។ ការកាត់ទោសនៅតែបន្តចោទប្រកាន់ថា សត្រូវទាំងអស់ត្រូវគេបានសម្លាប់នៅពេលនោះ ។

មេធាវីដើមចោទយល់ថា ការអនុវត្តរបស់ នួន ជា ទៅលើគោលនយោបាយមួយនេះ អាចបង្ហាញថាជាអ្នកបញ្ជាពីក្រោយការស្វែងរកខ្មាំងក្នុង ក៏ដូចជាបញ្ជាកម្មាភិបាលឲ្យសម្លាប់បុគ្គលនានា ។ ប៉ុន្តែយើងជាមេធាវីចុងចោទ យល់ថា នេះគឺជាការចោទប្រកាន់មួយដែលគ្មានភស្តុតាងជាក់លាក់ពិតប្រាកដ និងមិនអាចយកជាការបាននោះទេ ។ ភស្តុតាងបានបង្ហាញថា នួន ជា ត្រឹមតែក្រើនរំឭកកម្មាភិបាលអំពីសត្រូវដែលគេនឹងត្រូវជួបប្រទះនៅថ្ងៃមុខតែប៉ុណ្ណោះ តែមិនមានភស្តុតាងបង្ហាញថា គាត់បានបង្រៀនពីវិធីសាស្ត្រក្នុងការសម្លាប់ ឬត្រួតត្រាក្នុងការស្វែងរកសត្រូវក្នុងបក្សនោះទេ ។ មេធាវី លីវ សុវណ្ណា បាននិយាយថា ក្នុងបក្សកុម្មុយនីស្តកម្ពុជា នួន ជា មានតួនាទីលើការឃោសនា និងការអប់រំតែប៉ុណ្ណោះ ។ គាត់បានអប់រំផ្នែកនយោបាយ ស្តីអំពីប្រវត្តិសាស្ត្ររួមជាមួយគោលបំណងនៃការធ្វើបដិវត្តន៍សង្គមនិយម ទៅកាន់កម្មាភិបាលទាំងឡាយ ។ ការអប់រំនេះ ភាគច្រើននិយាយទាក់ទងតែសេដ្ឋកិច្ច និងកសិកម្មប៉ុណ្ណោះ ។ បន្ថែមពីនេះ ឯកសារដែលបានកត់ត្រានៅសម័យខ្មែរក្រហមបានបកស្រាយអំពីការគំរាមកំហែងផ្ទៃក្នុង និងការគំរាមកំហែងពីសំណាក់ខាងក្រៅដោយក្នុងនោះ នួន ជា បានផ្តែផ្តាំឲ្យកម្មាភិបាលប្រុងប្រយ័ត្នប្រសិនជាមានរឿងហេតុកើតឡើង ។ ហេតុផលទាំងនេះអាចលុបចោលនូវការចោទប្រកាន់ដែលបានលើកឡើងថា នួន ជា បានសម្លាប់ ឬធ្វើបាបនរណាម្នាក់ ហើយក៏គ្មានភស្តុតាងពាក់ព័ន្ធណាអាចបញ្ជាក់បានចំពោះការចោទប្រកាន់នេះទេ ។ បន្ថែមលើនេះ យើងត្រូវចាំថា រដ្ឋាភិបាលបានប្រកាសប្រទេសកម្ពុជាជារដ្ឋស្ថិតក្នុងសភាពអាសន្ន និងមានជម្លោះប្រដាប់អាវុធជាមួយវៀតណាមកាលពីសម័យនោះ ។ អស្ថិរភាពរបស់ប្រទេស គឺស្ថិតនៅក្រោមការគំរាមកំហែង ហើយវាពិតជាវិធីសាស្ត្រដ៏ត្រឹមត្រូវមួយក្នុងការប្រុងប្រយ័ត្នអំពីវិធានការការពារ



មន្ទីរសន្តិសុខស-២១ ឬ គុកទួលស្លែង

សន្តិសុខរបស់ប្រទេស ។ ការចោទប្រកាន់របស់ព្រះរាជអាជ្ញាលើគោលនយោបាយ សត្រូវគឺពឹងផ្អែកទាំងស្រុងលើការផ្តល់ចម្លើយរបស់ ឌុច ។ បន្តិចទៀត គាត់នឹងបង្ហាញថា ការផ្តល់ចម្លើយគឺមិនអាចទុកចិត្តបាននោះទេ ។

មេធាវី លីវ សុវណ្ណា បានបន្ថែមថា ករណីដែលសហព្រះរាជអាជ្ញាបានលើកឡើងគឺពឹងផ្អែកលើសេចក្តីថ្លែងការណ៍របស់បុគ្គលនានាដែលមិនបានឆ្លងកាត់ការផ្តល់ចម្លើយឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយចម្លើយទាំងនោះមិនបានឆ្លងកាត់ការធ្វើតេស្តនោះទេ ។ ពួកគេប្រើប្រាស់ឯកសារដែលប្រមូលផ្តុំក្រៅប្រព័ន្ធតុលាការ និងឯកសារប្រភពទីពីរ រួមជាមួយឯកសារដែលមិនត្រូវបានផ្ទៀងផ្ទាត់ច្បាស់លាស់ ។ សហព្រះរាជអាជ្ញាគួរតែយល់ច្បាស់ថា ភ័ស្តុតាងមួយនេះគឺមិនសមក្នុងការប្រើប្រាស់នោះទេ ដូចដែលអង្គជំនុំជម្រះតុលាការកំពូលបានរកឃើញនៅក្នុងករណី ០០១ ។ ចម្លើយដែលយកមកប្រើប្រាស់គឺមិនសូវមានតម្លៃក្នុងតុលាការនោះទេ ប្រសិនបើយោងទៅតាមច្បាប់ ជាពិសេសនៅពេលដែលគ្មានភ័ស្តុតាងដាក់បន្ទុក និងមិនត្រូវបានដាក់ឲ្យសួរដេញដោលនៅក្នុងតុលាការ ។ ទីបំផុត ករណីដែលព្រះរាជអាជ្ញាបានលើកឡើង គឺសុទ្ធសឹងតែជាការប៉ាន់ស្មានទាំងស្រុង ។ ការលើកឡើងមិនត្រូវបានគាំទ្រដោយភ័ស្តុតាងដែលអាចយកជាការបាន ហើយវាក៏មិនអាចសម្រេចនូវគោលបំណងដែលគេបានគ្រោងទុក ព្រោះការសង្ស័យមានលក្ខណៈមិនសមហេតុផល ។

មេធាវី លីវ សុវណ្ណា បានស្នើសុំឲ្យអង្គជំនុំជម្រះបើកចិត្តឲ្យទូលាយក្នុងការស្តាប់រឿងហេតុមួយនេះ ។ អង្គជំនុំជម្រះនឹងយល់ឃើញថា គោលនយោបាយដែលបក្សកុម្មុយនីស្តបានប្រើប្រាស់នាសម័យនោះ គឺមានលក្ខណៈស្រដៀងទៅនឹងគោលការណ៍ដែលប្រទេសនានាក្នុងសកលលោកបានប្រើប្រាស់ដើម្បីការពារប្រទេសឲ្យរួចផុតពីការគំរាមកំហែងពីប្រទេសផ្សេងៗ ។ សាក្សី រួមទាំងឯកសារស្របច្បាប់នានាបានបកស្រាយថា គោលនយោបាយដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រើប្រាស់ គឺមានភាពត្រឹមត្រូវ និងស្របច្បាប់ ។ ដើម្បីយល់ដឹងចំពោះគោលការណ៍ដែលបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ឲ្យបានច្បាស់ យើងគួរតែយកចិត្តទុកដាក់អំពីជម្លោះផ្នែកសព្វាវុធដែលបានគំរាមកំហែងប្រទេសកម្ពុជាជាមុនសិន ។ បក្សកុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងប្រទេសកាលពីខែមេសា ឆ្នាំ១៩៧៥ នាពេលនោះកម្ពុជាគឺស្ថិតនៅត្រង់ចំណុចសូន្យ ដែលជាហេតុទាមទារឲ្យមានការកសាងប្រទេសឡើងវិញ ។ ប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាមបង្ហូរឈាមដែលមានរយៈពេល ៥ឆ្នាំជាមួយសាធារណរដ្ឋខ្មែរ ដែលពេលនោះប្រទេសកម្ពុជាត្រូវបានសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែក ដែលនាំមកនូវការខូចខាតជាទម្ងន់ ។ រដ្ឋាភិបាលកាលពីសម័យនោះបានបិទចោលស្ថាប័នរដ្ឋទាំងអស់រួមជាមួយនឹងស្ថាប័នតុលាការផងដែរ ។

មេធាវី លីវ សុវណ្ណា បានបន្ថែមថា ការចោទប្រកាន់បក្សកុម្មុយនីស្តកម្ពុជាបានបំផ្លាញស្ថាប័នច្បាប់ និងតុលាការ ពិតជាមិនត្រឹមត្រូវនោះទេ ។ សហព្រះរាជអាជ្ញាមិនបានបង្ហាញភ័ស្តុតាងដើម្បីគាំទ្រក្នុងការសន្មតរបស់ពួកគេ បន្ថែមពីលើនេះ របបសាធារណរដ្ឋខ្មែរក៏មិនបានបន្សល់ទុករចនាសម្ព័ន្ធនានាដើម្បីឲ្យបក្សកុម្មុយនីស្តកម្ពុជាបំផ្លាញដែរ ។ បក្សកុម្មុយនីស្តកម្ពុជាក៏បានព្យាយាមទប់ស្កាត់មហិច្ឆតាអធិរាជវៀតណាម រួមទាំងការគំរាមកំហែងនានាខណៈពេលដែលបក្សបានកាន់អំណាច ។ ការគំរាមកំហែងនេះកើតឡើងទាំងផ្ទៃក្នុង និងក្រៅបក្សផងដែរ ។ ការគំរាមកំហែងផ្ទៃក្នុងគឺធ្វើឡើងដោយវៀតណាមដែលពេលនោះគេបានបង្កឲ្យមានរដ្ឋប្រហារ ឯការគំរាមកំហែងផ្នែកខាងក្រៅ គឺទង្វើឈ្លានពានដោយឥតលាក់លៀមដែលបង្កទៅជាជម្លោះប្រដាប់អាវុធយ៉ាងធ្ងន់ធ្ងរ ។ កត្តាទាំងនេះបានធ្វើឲ្យរបបកម្ពុជាប្រជាធិបតេយ្យ ប្រកាសថាជារដ្ឋដែលស្ថិតនៅក្នុងសភាពប្រកាសអាសន្ន ។ បក្សកុម្មុយនីស្តកម្ពុជាយល់ថា ដើម្បីបង្វែរចេញពីស្ថានការណ៍មួយនេះ ខ្លួនត្រូវតែពង្រឹងសន្តិសុខនយោបាយ ដោយប្រើប្រាស់គោលការណ៍ដែលរដ្ឋាភិបាលនាសម័យនោះបានណែនាំក្នុងគោលបំណងពង្រឹង និងការពារប្រទេសកម្ពុជាពីការឈ្លានពានទាំងផ្ទៃក្នុងនិងក្រៅបក្ស ។ នៅក្នុងសភាពបែបនេះ ការពង្រឹងសន្តិសុខជាតិ និងការពង្រឹងគោលនយោបាយគឺជាកត្តាដ៏ចាំបាច់បំផុតដែលត្រូវបានគេប្រើប្រាស់ទូទាំងសកលលោក ។

មេធាវី លីវ សុវណ្ណា បានបន្ថែមថា វាពិតជាមានសារសំខាន់ណាស់ក្នុងការក្រឡេកទៅមើលប្រទេសដទៃដែលបានជួបបញ្ហាស្រដៀងទៅនឹងប្រទេសកម្ពុជា ។ យើងគិតថា គេនឹងប្រើប្រាស់វិធី

សាស្ត្រស្រដៀងទៅនឹងប្រទេសកម្ពុជា ប្រសិនបើគេបានជួបប្រទះនូវបញ្ហាមួយនេះ ។ ដូច្នេះតើវាមានភាពខុសអ្វីក្នុងការប្រើប្រាស់វិធីសាស្ត្រមួយនេះ? យើងគិតថា ភាពខុសគ្នាគឺកើតឡើងដោយសាររឿងនិទានកុហកនេះឯង ។ រឿងនិទានមួយនេះបានធ្វើឲ្យអ្នកដឹងយល់ឃើញថា រាល់ទង្វើរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជាសកម្មភាពអាក្រក់សុទ្ធសាធ ។ ទាំងនេះសុទ្ធសឹងតែជាការចោទប្រកាន់មកកាន់បក្សកុម្មុយនីស្តកម្ពុជា ។ មេធាវី លីវ សុវណ្ណា បានបន្តថា សកម្មភាពខាងលើពិតជាមិនសមស្របក្នុងការប្រើប្រាស់ក្នុងតុលាការនោះទេ ។ ដើម្បីគាំទ្រទៅលើសកម្មភាពដែលគេបានប្រព្រឹត្ត បក្សកុម្មុយនីស្តកម្ពុជាបាននិយាយបកថា យើងត្រូវតែសម្លាប់សត្រូវទាំងអស់ដែលស្ថិតនៅនឹងមុខ ។ ព្រះរាជអាជ្ញាបានជំទាស់ថា រាល់ការចុះផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានដូចជា របាយការណ៍ ទូរលេខ សុទ្ធសឹងតែបានបង្គាប់ឲ្យកម្មាភិបាលសម្លាប់ ឬក៏កម្ទេចសត្រូវទាំងអស់ចោល ។ បក្សកុម្មុយនីស្តកម្ពុជាបានប្រើពាក្យជាច្រើនផ្សេងៗទៀត ដើម្បីពណ៌នាអំពីគោលការណ៍នយោបាយរបស់គេ ។ ពួកគេបានប្រើពាក្យន័យធៀបជាច្រើនដែលមានដូចជា ការកម្ចាត់ ការកម្ទេច ការវាយ ការបោសសម្អាតសមរភូមិ ឬការទទួលជ័យជម្នះទៅកាន់ការងារប្រចាំថ្ងៃរបស់គេដែលមានដូចជា ការធ្វើស្រែ ឬទៅកាន់គម្រោងសាងសង់នានា ។ ភាសាទាំងនេះត្រូវបានរាប់បញ្ចូលប្រើប្រាស់សម្រាប់គោលនយោបាយប្រចាំថ្ងៃរបស់គេ ដូចនេះការចោទប្រកាន់មិនអាចធ្វើឡើងបាននោះទេ ហើយវាក៏មិនអាចបង្ហាញនូវចេតនាឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជាបានដែរ ។ ការប្រើប្រាស់នូវភាសាបែបនេះ គឺជារឿងធម្មតាពីព្រោះវាត្រូវបានប្រើប្រាស់ទូទៅក្នុងវិស័យនយោបាយក្នុងសកលលោក ។ ឧទាហរណ៍ ការប៉ុនប៉ងធ្វើរដ្ឋប្រហារក្នុងខែកក្កដា ឆ្នាំ២០១៦ ប្រធានាធិបតីតួគី ឈ្មោះ អឺដូហ្គាន បានប្រៀបធៀបអ្នកវាយប្រហារទៅកាន់រដ្ឋាភិបាលថា ជាពួកមេរោគ និងជាមហារីកដែលរីកសាយភាយនៅក្នុងប្រទេស ។ ដូចគ្នានេះដែរ ប្រធានាធិបតីបារាំង និងអតីតប្រធានាធិបតីអាមេរិក តែងតែប្រើប្រាស់ពាក្យទាក់ទងនឹងសង្គ្រាមទៅកាន់ភេរវជនផងដែរ ជាពិសេសជាងនេះទៅទៀត អតីតតុលាការព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសយូហ្គោស្លាវី បានបញ្ជាក់ថា យើងមិនអាចរកឃើញនូវចេតនាក្នុងការរើសអើងដោយគ្រាន់តែសម្លឹងមើលការប្រើប្រាស់ពាក្យប្រមាថមាក់ងាយនោះទេ ។ ការប្រើប្រាស់ពាក្យថា សត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា មិនអាចបញ្ជាក់ពីចេតនាឧក្រិដ្ឋកម្មរបស់គេទៅកាន់ក្រុមមនុស្សមួយចំនួនតូចនោះទេ ។

មេធាវី លីវ សុវណ្ណា បានថ្លែងបន្ថែមថា នៅខែមិថុនា ឆ្នាំ១៩៧៨ បក្សកុម្មុយនីស្តកម្ពុជាបានអំពាវនាវឲ្យមានការអប់រំមនុស្សជាថ្មី ដែលវាមានលក្ខណៈផ្ទុយពីគោលការណ៍របស់រដ្ឋាភិបាលកាលពីដំបូង ។ ទាំងនេះគឺជាសកម្មភាពដែលមនុស្សចូលចិត្តបំភាន់យកមកប្រើប្រាស់ ហើយសកម្មភាពនេះមានភាពផ្ទុយស្រឡះទៅនឹងការមានចិត្តចង់សម្លាប់ ។ សហព្រះរាជអាជ្ញាបានឲ្យនិយមន័យ៣១និយមន័យ ទៅកាន់ពាក្យថាសត្រូវ ហើយនៅក្នុងនិយមន័យទាំង៣១នោះ បានក្តោបថា ប្រជាជនទាំងអស់ដែលរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាសត្រូវ ។ ហេតុផលដែលព្រះរាជអាជ្ញាលើកឡើង គឺចង់បង្ហាញថា ប្រជាជនកម្ពុជានៅសម័យនោះគឺសុទ្ធតែជាសត្រូវ ដូចនេះគេត្រូវតែសម្លាប់អ្នកទាំងអស់នោះចោល ក៏ប៉ុន្តែការលើកឡើងមួយនេះ មិនមានភស្តុតាងសមស្របសម្រាប់គាំទ្រនោះទេ ។ ការលើកឡើងមួយនេះពិតជាមិនត្រឹមត្រូវទេ ព្រោះនៅមានមនុស្សដែលរស់រានមានជីវិតបន្ទាប់ពីរបបមួយនេះ ។ រដ្ឋធម្មនុញ្ញមាត្រា១០ នៃរបបកម្ពុជាប្រជាធិបតេយ្យបានឲ្យនិយមន័យទៅលើពាក្យសត្រូវ ថាជាមនុស្សដែលបានធ្វើសកម្មភាពគ្រោះថ្នាក់ដែលផ្ទុយពីការចង់បានរបស់រដ្ឋ ។ ក្រុមនោះបានល្មើសទៅនឹងច្បាប់ ហើយបង្កការគំរាមកំហែងទៅកាន់អធិបតេយ្យភាព និងសន្តិសុខរបស់ប្រទេស ។ ហេតុផលនេះគឺត្រូវបានប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេសក្នុងសកលលោក ។

ព្រះរាជអាជ្ញាបានអះអាងថា បុគ្គលណាជាសត្រូវ និងត្រូវបានគេវាយកម្ទេចចោល ឬអាចនិយាយបានថា សម្លាប់ចោល ។ នៅពេលដែលអ្នកអានឯកសាររបស់ខ្មែរក្រហម និងព្យាយាមស្វែងយល់ចំពោះអត្ថន័យមួយៗ អ្នកនឹងយល់ពីអត្ថន័យពីក្រោយវា ។ ពាក្យថា កម្ទេចនៅក្នុងភាសាខ្មែរ និងអង់គ្លេស មានន័យខុសគ្នាប្រសិនបើធ្វើការប្រៀបធៀប ។ ដូចនេះយើងត្រូវតែស្វែងយល់ពាក្យទាំងនេះទៅតាមបរិបទរៀងៗខ្លួន ។ លេខាស្រុក

ម្នាក់បានផ្តល់សក្ខីកម្មថា ពាក្យកម្ទេចនោះមិនសំដៅទៅលើការសម្លាប់ទេ ក៏ប៉ុន្តែវាសំដៅទៅលើការជម្រុះចោល ឬម្យ៉ាងទៀតអាចនិយាយបានថា ជម្រុះចោល ឬលុបបំបាត់នៅឋានៈមួយដែលបានកេងប្រវ័ញ្ចជនដទៃដើម្បីកុំឲ្យអ្នកដទៃផ្សេងទៀតយកគំរូតាម ។

ឧទាហរណ៍ មិនដែលមាននរណាគិតថា បេក្ខភាពប្រធានាធិបតីកុម្មុយនីស្តបារាំង នឹងនិយាយអំពីការតស៊ូប្រឆាំងនឹងនិយោជកនោះទេ ។ នៅក្នុងនោះដែរនាងបានប្រាប់ក្រុមពលករឲ្យសម្លាប់មេរបស់ខ្លួន ដូចនេះភាសាដែលបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់គួរតែត្រូវបានយោគយល់ដោយគ្មានភាពសង្ស័យដូចសកម្មភាពខាងលើនេះដែរ ។

មេធាវី លីវ សុវណ្ណា បានបន្ថែមថា ខ្ញុំនឹងលើកឡើងនូវគោលនយោបាយការពារជាតិ និងគោលនយោបាយសន្តិសុខជាតិ ដោយយោងទៅតាមរឿងខាងលើ ។ ដូចដែលខ្ញុំបានប្រាប់ហើយថា រឿងនេះគឺជាការពិត ដោយយើងអាចធ្វើការប្រៀបធៀបគោលនយោបាយទាំងនោះជាមួយគោលនយោបាយដែលបានប្រើប្រាស់នៅតាមបណ្តាប្រទេសនានា ដែលមានដូចជា លោកខាងលិច និងប្រទេសដែលប្រើប្រាស់នូវលទ្ធិប្រជាធិបតេយ្យ ។ វាពិតជាត្រឹមត្រូវណាស់ដែលប្រទេសបានថែរក្សានូវបន្ទាត់ព្រំដែនរបស់ខ្លួនទោះក្នុងពេលដែលប្រទេសមានស្ថិរភាព សភាពអាសន្ន ឬសង្គ្រាម ដើម្បីធានាឲ្យបាននូវសន្តិភាព និងស្ថិរភាពនៅក្នុងប្រទេស ។ ទង្វើទាំងនេះពិតជាវិធានការដ៏ចាំបាច់ណាស់នៅក្នុងការថែរក្សារដ្ឋដែលមានអធិតេយ្យភាពមួយ ។ មេធាវី លីវ សុវណ្ណា បានបន្តថា បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលនយោបាយយ៉ាងច្បាស់លាស់ចំពោះការចាប់ខ្លួន ដែលបានធ្វើតាមរដ្ឋធម្មនុញ្ញនាសម័យកម្ពុជាប្រជាធិបតេយ្យ ។ ដូចដែលខ្ញុំបានលើកឡើងខាងលើ រដ្ឋធម្មនុញ្ញបានចែងថា រាល់សកម្មភាព ឬទង្វើដែលនាំឲ្យប្រទេសធ្លាក់នៅក្នុងសភាពគ្រោះថ្នាក់ត្រូវតែថ្កោលទោស រដ្ឋធម្មនុញ្ញក៏បានបន្ថែមថា អ្នកទាំងនោះត្រូវតែអប់រំឡើងវិញ ។ ទាំងនេះបញ្ជាក់ថា សត្រូវពិតប្រាកដ គឺសកម្មភាពតស៊ូប្រឆាំងបដិវត្តន៍ ។ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានចែងយ៉ាងច្បាស់ថា ការអប់រំឡើងវិញត្រូវតែធ្វើឡើងដើម្បីតបតទៅកាន់សកម្មភាពដែលផ្តល់គ្រោះថ្នាក់ទៅកាន់សង្គមជាតិ ។ ការថ្កោលទោសជាទម្ងន់ត្រូវបានប្រើប្រាស់ជាមួយសកម្មភាពណាដែលបានបង្កគ្រោះថ្នាក់ទៅកាន់សង្គមតែប៉ុណ្ណោះ ដូចនេះ រឿងរ៉ាវជាក់ស្តែង គឺមិនដូចអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះទេ ។

ដូចគ្នានេះដែរ ក្រមព្រហ្មទណ្ឌលេខ៩៥៦ របស់ប្រទេសកម្ពុជាបានចាត់ទុកអំពើក្បត់ជាតិ និងចារកម្មជាបទឧក្រិដ្ឋធ្ងន់ធ្ងរដែលត្រូវតែទទួលទោស ។ ក្របខណ្ឌច្បាប់នេះត្រូវបានប្រើប្រាស់នៅតាមប្រទេសនានាសព្វថ្ងៃនេះ ។ ជាការពិតណាស់ អំពើក្បត់ជាតិគឺជាបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរមួយដែលប្រទេសទាំងឡាយត្រូវតែបង្ក្រាប ។ ការកាត់ទោសប្រហារជីវិតត្រូវបានគេប្រើប្រាស់ជាទូទៅក្នុងឆ្នាំ១៩៧៥ ។ សព្វថ្ងៃនេះ មានប្រទេសប្រហែល ៧០ នៅតែបន្តប្រើប្រាស់គោលការណ៍នេះ សម្រាប់តបតទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងរដ្ឋាភិបាល ។ ច្បាប់នេះត្រូវបានប្រទេសចំនួន១២៤ ប្រើប្រាស់ វាមានចំនួន៨១ បើគិតជាភាគរយ ។ គោលនយោបាយដែលបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ គឺជាបទដ្ឋានដែលគេប្រើប្រាស់ទូទៅ ហើយវាមិនមែនជាបទឧក្រិដ្ឋនយោបាយនោះទេ ។ ជាការពិតការចាប់ខ្លួននេះបានធ្វើឡើងតែចំពោះជនដែលល្មើសច្បាប់ ឬបានប្រព្រឹត្តនូវបទឧក្រិដ្ឋនានាដែលបង្កឲ្យប៉ះពាល់ទៅលើបូរណភាពជាតិ ។ មេធាវី សុវណ្ណា បានបន្ថែមថា ព្រះរាជអាជ្ញាបានអះអាងថា ជីវប្រវត្តិរបស់បុគ្គលនានាត្រូវបានគេប្រមូលយកដើម្បីសម្គាល់ថា ម្នាក់នោះជាសត្រូវ ប៉ុន្តែវាមិនមែនជាការពិតនោះទេ ។ សត្រូវនាសម័យនោះត្រូវបានគេចាប់ខ្លួនដោយសារទង្វើឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត មិនមែនដោយសារជីវប្រវត្តិរបស់ជននោះទេ ។ ជីវប្រវត្តិត្រឹមតែជាឯកសារជំនួយរបស់អាជ្ញាធរដើម្បីដឹងចំនួនមនុស្សក្នុងឃុំនានា បូករួមបញ្ចូលការរៀបចំស្បៀង និងការផ្គត់ផ្គង់ផ្សេងៗ ។ បន្ថែមពីនេះ បក្សកុម្មុយនីស្តកម្ពុជាក៏បានរៀបចំឲ្យមានការស៊ើបអង្កេតដើម្បីឲ្យការចាប់ខ្លួនមានភាពត្រឹមត្រូវ និងស្របច្បាប់ ។ បើយោងទៅតាមប្រព័ន្ធច្បាប់ផ្សេងៗ ការសួរចម្លើយ គឺជាយន្តការដ៏សំខាន់មួយក្នុងការផ្ទៀងផ្ទាត់នៅរាល់សកម្មភាពនានា ដែលទាក់ទងនឹងសកម្មភាពល្មើសច្បាប់ ។ ជាបន្ទាប់ មេធាវី លីវ សុវណ្ណា ក៏បានផ្តល់វេទិកានេះទៅកាន់មេធាវី ដូរេន ចាន់ ។ មេធាវី ដូរេន ចាន់ នឹងធ្វើការបកស្រាយអំពីមន្ទីរសន្តិសុខចំនួន៤ ដែលមានដូចជា ក្រាំងតាចាន់ អូកន្សែង និងភ្នំក្រោល រីឯមេធាវី កុប៉េ និងបកស្រាយ

អំពីមន្ទីស-២១ ។

**គុកក្រាំងតាចាន់, អូរកន្សែង និង ភ្នំក្រោល**

មេធាវី ដូវេន ចាន់ បាននិយាយថា ព្រះរាជអាជ្ញាបានតវ៉ាថា មន្ទីរសន្តិសុខត្រូវបានបង្កើតឡើងដើម្បីធ្វើទារុណកម្ម និងសម្លាប់មនុស្សដោយខុសច្បាប់ ប៉ុន្តែមិនមានភស្តុតាងដើម្បីបញ្ជាក់ចំពោះការចោទប្រកាន់មួយនេះទេ ។ ការកាត់ក្តីមួយនេះគឺពឹងតែអំពីភស្តុតាង ឬឯកសារដែលប្រមូលក្រៅប្រព័ន្ធតុលាការ និងមិនសូវមានគុណភាព ។ សាក្សីដែលរស់រានមានជីវិតបាននិយាយទៅកាន់តុលាការថា វាគឺជាមន្ទីរឃុំឃាំងស្របច្បាប់ ហើយបង្កើតឡើងដើម្បីផ្តល់ការរៀនសូត្រទៅដល់ខុក្រិដ្ឋជន ។ ក្រាំងតាចាន់ គឺជាមន្ទីរសន្តិសុខដែលស្ថិតនៅស្រុកត្រាំកក់ ភូមិភាគនិរតី ។

ជាដំបូង មេធាវី ដូវេន ចាន់ បានលើកឡើងអំពីសាច់រឿងចំនួន២ ដែលមានទំនាក់ទំនងជាមួយមន្ទីរសន្តិសុខខាងលើ ៖

*១) កង្វះភាពជឿជាក់អំពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានឈ្មោះថា មៀ សុខា និង សយ សែន*

មេធាវី ដូវេន ចាន់ បាននិយាយថា ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់ភស្តុតាងគឺមានវ័យជំទង់នៅសម័យនោះ ប៉ុន្តែបាននិយាយថា ខ្លួនបានឃើញ និងដឹងរឿងទាំងអស់ ។ ការអះអាងរបស់គេពោរពេញដោយកង្វះនៃភាពជឿជាក់ និងមិនអាចយកជាការបាននោះទេ ។ ប្រសិនបើមេធាវីការពារក្តីប្រើប្រាស់ស្តង់ដាដែល សំ សុធី ប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះតុលាការកំពូលទៅលើសាក្សី នោះចម្លើយសាក្សី និងអាចយកជាការបានជាចម្លើយរបស់លោក សំ សុធី ទៀត ។ ចម្លើយរបស់អ្នកទាំងពីរពោរពេញទៅដោយការពន្លើស ហើយមិនមានភាពច្បាស់លាស់នោះទេ ។ ពួកគេប្រហែលជាមានការពិចារណាផ្សេងដែលបណ្តាលឲ្យមានការប៉ះពាល់ដល់ការផ្តល់ភស្តុតាងរបស់គេ ដូចនេះ អង្គប្រជុំមិនអាចពឹងផ្អែកទៅលើភស្តុតាងដែលអ្នកទាំងពីរបានផ្តល់នោះទេ ហើយទោះបីជាចម្លើយនេះមានធាតុផ្សំជាមួយភស្តុតាងផ្សេងក៏នៅតែមិនអាចយកជាការបានដែរ ។

*២) កង្វះភាពជឿជាក់នៃភស្តុតាងជាឯកសារ*

មេធាវី ដូវេន ចាន់ បាននិយាយថា ឯកសារដែលព្រះអាជ្ញាប្រើប្រាស់ភាគច្រើនត្រូវបានដកស្រង់ចេញពីកំណត់ត្រាស្រុកត្រាំកក់ ហើយសន្ទេបឯកសារបានតែពីតំបន់នេះប៉ុណ្ណោះ ។ នៅក្នុងចំណោមឯកសារកំណត់ត្រាទាំងអស់ ព្រះរាជអាជ្ញាប្រើប្រាស់ត្រឹមតែឯកសារដើមមួយទេ ហើយឯកសារដើមនេះមិនបានចង្អុលបង្ហាញពីចំណុចសំខាន់នៃឯកសារគោលនៃការកាត់ទោស ហើយមេធាវីការពារក្តីក៏មានវានៅក្នុងដៃដែរ ។ ឯកសារផ្សេងៗសុទ្ធតែបានមកពីឯកសារថតចម្លង ដូចនេះវាមិនមែនជាឯកសារដើមនោះទេ ហើយអង្គប្រជុំក៏បាននិយាយថា វាមិនមែនជាឯកសារដើមដែរ ។ ដូច្នេះ ឯកសារទាំងនោះពុំអាចយកជាការបានទេ ។ ព្រះរាជអាជ្ញាមិនបានព្យាយាមពិនិត្យមើលយថាភាពកំណត់ត្រារបស់ស្រុកត្រាំកក់ដែលគេបានយកមកប្រើប្រាស់នោះទេ ។ ទង្វើនេះបានបង្ហាញពីការប៉ាន់ស្មានទាំងស្រុងរបស់ព្រះរាជអាជ្ញាថា ភស្តុតាងរបស់គេមិនចាំបាច់មានការបញ្ជាក់នោះទេ ។ នៅក្នុងជំហរមួយនេះ មិនមានកំណត់ត្រានៅស្រុកត្រាំកក់មួយណាដែលមានភាពពិតប្រាកដនោះទេ ហើយកំណត់ត្រាទាំងនោះសុទ្ធតែមិនបានឆ្លងកាត់តុលាការ ដូចនេះកំណត់ត្រាទាំងនោះមានតម្លៃទាបណាស់ប្រសិនបើវាមិនមានការបញ្ជាក់ដោយផ្ទាល់ ឬអះអាងដោយផ្ទាល់ពីតុលាការ ។ បញ្ហាដែលបានលើកឡើងទាំងពីរបានកើតឡើងនៅក្នុងរឿងក្តីមួយនេះ ។

បន្ទាប់មក មេធាវី ដូវេន ចាន់ នឹងធ្វើការបកស្រាយអំពីរចនាសម្ព័ន្ធរបស់មន្ទីរសន្តិសុខ ក្រាំងតាចាន់ ។ នាងបាននិយាយថា ការផ្តល់ចម្លើយនៅក្នុងតុលាការបានបង្ហាញថា ការវិនិច្ឆ័យនៅមន្ទីរសន្តិសុខក្រាំងតាចាន់ គឺបានធ្វើឡើងនៅតំបន់១៣ ។ វាមិនអាចបញ្ជាក់ថា តាម៉ុក មានបានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការរបស់មន្ទីរសន្តិសុខក្រាំងតាចាន់ ហើយវាពិតជាមិនអាចទៅរួចចំពោះការចោទប្រកាន់ នួន ជា ក្នុងការចូលរួមនៅក្រាំងតាចាន់ទេ ។ ព្រះរាជអាជ្ញាបាននិយាយដោយគ្មានភស្តុតាងថា នួន ជា បានធ្វើដំណើរទៅក្រាំងតាចាន់ ប៉ុន្តែការលើកឡើងមួយនេះគឺពោរពេញទៅដោយភាពមិនពិត បើទោះបីជា នួន ជា ធ្វើដំណើរទៅកាន់ទីនោះមែន ក៏វាមិនអាចបញ្ជាក់ថា គាត់បានចូលរួមជាមួយសកម្មភាពនោះដែរ ។

**(តទៅលេខក្រោយ)**

**រ៉និត អារី**

# មគ្គុទ្ទេសក៍ទេសចរណ៍ទទួលចំណេះដឹងអំពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែង

មគ្គុទ្ទេសក៍ទេសចរណ៍ និងការីទេសចរណ៍ប្រមាណ៣០០នាក់ បានទទួលចំណេះដឹងអំពីតំបន់ប្រវត្តិសាស្ត្រទាំង១៤កន្លែង ក្នុងស្រុកអន្លង់វែង រួមមាន ១) កន្លែងដុតសព ប៉ុល ពត ២) កន្លែងកាត់ទោស ប៉ុល ពត ៣) ផ្ទះតាម៉ុក និងផ្ទះកណ្តាលនៅលើភ្នំដងរែក ៤) កន្លែងកែច្នៃគ្រាប់កាំភ្លើងលើភ្នំ២០០ ៥) កន្លែងលាក់ខ្លួនរបស់ ប៉ុល ពត និង ខៀវ សំផន ៦) ឃ្លាំងដាក់សម្ភារដើងភ្នំ ៧) កន្លែងដុតសព សុន សេន ៨) ស្រែគំរូ ៩) ទីតាំងការដ្ឋានដឹកជញ្ជូនរបស់ តាម៉ុក ១០) បឹងអន្លង់វែង ១១) ផ្ទះតាម៉ុក សារមន្ទីរតាម៉ុក ១២) មន្ទីរពេទ្យ តាម៉ុក ១៣) សាលារៀន តាម៉ុក និង ១៤) ស្ពាន តាម៉ុក តាមរយៈកិច្ចប្រជុំពិភាក្សា និងការធ្វើបទបង្ហាញរបស់មន្ត្រីមកពីក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ ខេត្តឧត្តរមានជ័យ និងក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ។

នៅព្រឹកថ្ងៃអង្គារ ទី២៧ ខែមីនា ឆ្នាំ២០១៨ នាសណ្ឋាគារអង្គរសេនជូរី ខេត្តសៀមរាប មានការបើកកិច្ចប្រជុំពិភាក្សាមួយដែលរៀបចំដោយក្រសួងទេសចរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជា និងគណៈកម្មការអន្តរក្រសួងចំនួនបួនផ្សេងទៀត ដើម្បីផ្សព្វផ្សាយតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដល់មគ្គុទ្ទេសក៍ទេសចរណ៍ និងការីទេសចរណ៍ក្នុងខេត្តសៀមរាប ។ នៅក្នុងកិច្ចប្រជុំនេះ មានការចូលរួមជាអធិបតីភាពពីឯកឧត្តម តុប សុភ័ក អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ លោកស្រី ធិនទី មុនីរស្មី ប្រធានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ លោកបណ្ឌិត ជុក ជំនោរ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ លោក កែន សុភី អនុប្រធាននាយក



ឯកឧត្តម តុប សុភ័ក អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ឡើងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំផ្សព្វផ្សាយតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដល់មគ្គុទ្ទេសក៍ទេសចរណ៍ និងការីទេសចរណ៍ នៅខេត្តសៀមរាប កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ។



មគ្គុទ្ទេសក៍ទេសចរណ៍ ឡើងសួរសំណួរទាក់ទងតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ។

ដ្ឋានអភិវឌ្ឍផលិតផលទេសចរណ៍ លោកបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាព អន្លង់វែង និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

បន្ទាប់ពីការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រ សក្តានុពលទេសចរណ៍ និងការអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអន្លង់វែង អ្នកចូលរួមនៅក្នុងកិច្ចប្រជុំនេះទាំងមូលបានស្នើសុំ និងបញ្ចេញមតិយោបល់ព្រមទាំងបានចូលរួមឆ្លើយនឹងសំណួររបស់បណ្ឌិត លី សុខឃាង ដែលបានសួរពាក់ព័ន្ធនឹងអ្នកទេសចរណ៍ថាគួរ ឬមិនគួរមកទស្សនានៅតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ។

ផ្តើមចេញពីការដឹងតិចតួច អំពីឈ្មោះស្រុកឬតំបន់អន្លង់វែង អ្នកមកចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយនេះ បានបង្ហាញឲ្យឃើញពីចំណាប់អារម្មណ៍ និងការយកចិត្តទុកដាក់ដោយបានស្នើសុំឲ្យមានដំណើរទស្សនកិច្ចសិក្សាចុះទៅដល់ទីតាំងផ្ទាល់ និងចែករំលែកឲ្យដឹងថា ទោះបីពីមុនមកមិនសូវមានអ្នកស្គាល់ ឬធ្លាប់ដឹងឮអំពីតំបន់នេះមានទីតាំងនៅកន្លែងណាក៏ដោយ ប៉ុន្តែបច្ចុប្បន្ន តំបន់អន្លង់វែង គឺជាទីតាំងមួយដ៏សំខាន់មួយ និងចាំបាច់សម្រាប់ការអប់រំផ្នែកប្រវត្តិសាស្ត្រសហគមន៍ ក៏ដូចជាទេសចរណ៍ ដោយសារទីតាំងនេះជាទីតាំងកាន់កាប់ចុងក្រោយរបស់ខ្មែរក្រហម និងស្ថិតនៅជាប់ព្រំដែនកម្ពុជាថៃក្នុងខេត្តឧត្តរមានជ័យ និងតាមជួរភ្នំដងរែក ។

លោក ឆាំង យុ បានឆ្លើយតបទៅនឹងសំណួរដ៏គួរឲ្យកត់សម្គាល់មួយចំនួនដែលលើកឡើងអំពីគម្រោងផ្លូវដើរភ្ជាប់ពីទីតាំងមួយទៅមួយទាំង១៨កន្លែង «ដូចជាសរសៃអំបោះដែលចងដៃដើម្បីសេចក្តីសុខ និងការពារពីជម្លោះព្រំដែន ពីព្រោះកាលណាមានលំហូរទេសចរណ៍ព្រំដែនក៏អាចការពារបានដែរ ដូចខ្សែអំបោះទាញពីអន្លង់វែង ទៅដល់តំបន់ក្បាលទន្សោង» ។ លោក ឆាំង យុ បានបន្ថែមថា មគ្គុទេសក៍ និងការីទេសចរណ៍ ត្រូវយល់ដឹងពីចំណុចពិសេសៗ និងចេះស្វែងរកចំណុចវិជ្ជមាន ដើម្បីណែនាំទៅកាន់ភ្ញៀវទេសចរណ៍ ជាជាងចំណុចអវិជ្ជមានច្រើន ដូចជាការឲ្យតម្លៃទៅលើធម្មជាតិ ទេសភាព មនុស្ស និងប្រជាជនក្នុងតំបន់ដែលជាប្រវត្តិសាស្ត្ររស់ ដែលមិនទាន់បានទៅដល់ ឬមិនធ្លាប់ប៉ះពាល់ ។ ជាក់ស្តែង នៅតំបន់អន្លង់វែងនេះ ទោះបីនៅរដូវក្តៅ ឬរដូវវស្សា គឺមាន «ផ្ការីកគ្រប់រដូវ» ។ មិនថាអាកាសធាតុក្តៅយ៉ាងណា ប៉ុន្តែ ព្រៃប្រឹក្សា និងផ្កាផ្ការលាន់ នៅតែរីកមានភាពស្រស់ស្អាត និងមានខ្យល់បក់ជានិច្ច ។ ផ្ទៃមេឃមានពណ៌ខៀវស្រឡះល្អជាងទីក្រុង ទិដ្ឋភាពពេលព្រះអាទិត្យលិច មានទំហំធំបំផុត និងអាចមើលឃើញច្បាស់ល្អ ដល់តំបន់ភ្នំគូលែន និងប្រសាទកោះកែរ ខេត្តព្រះវិហារ ។ **សេី សាយ្យាណា**

# កិច្ចប្រជុំផ្សព្វផ្សាយតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្ត
# នៅខេត្តសៀមរាប កាលពី










# ់វែង ដល់មគ្គុទ្ទេសក៍ទេសចរណ៍ និងការីទេសចរណ៍ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨

















# ៧ មករា ១៩៧៩ ដល់ ៧ មករា ២០១៨ ជាថ្ងៃកំណើតជីវិតទី២របស់ខ្ញុំ បាន៣៩ឆ្នាំហើយ

## មនុស្សសំណាងមួយនាក់ ក្នុងចំណោមមនុស្ស៥.០០០នាក់ ដែលមានជីវិតរស់នៅ រួចផុតពីការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម

*ប្រវត្តិពិតៗជាច្រើនឆ្នាំមកហើយ ដែលខ្ញុំលាក់ទុកក្នុងចិត្ត...*

### វគ្គសិក្សានយោបាយ

ពេលមកដល់ភ្នំពេញដំបូងនាអំឡុងឆ្នាំ១៩៧៥ ខ្ញុំបានសិក្សាវគ្គនយោបាយនៅសាលាតិចណូ ដែលមានសមមិត្ត កុំ ជាអ្នកបង្រៀន ។ ការបង្រៀនកាលពីសម័យនោះ គឺគ្មានអ្វីក្រៅអំពីការរៀនកម្ចាត់កម្មសិទ្ធិឯកជន កសាងនូវកម្មសិទ្ធិសមូហភាព និងកិច្ចដំណើរការកសាងបដិវត្តន៍សង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ ដែលយើងជាយុវជន ជាសសរទ្រូងដ៏រឹងមាំរបស់បក្ស ។ មិត្ត កុំ បានលើកឡើងទៀតថា កុំឲ្យវ័យរបស់យុវវ័យយើងកន្លងហួស យើងត្រូវតែខិតខំកសាងខ្លួន ដើម្បីរួមចំណែកកសាងប្រទេសឲ្យមានការរីកចម្រើន ទាន់យើងនៅជាយុវវ័យ ។ បន្ទាប់ពីចូលរួមសិក្សាវគ្គ



រូបថតអតីតបុគ្គលិក នៅមន្ទីរ ក-១២ ថតនៅដើមឆ្នាំ១៩៧៨ នៅពេលទៅទស្សនាសិល្បៈ ដែលសម្តែងដោយក្រុមសិល្បៈរូម៉ានី នៅសាលមហោស្រពទន្លេបាសាក់ ។ រូបថតរាប់ពីឆ្វេង ៖ មិត្តនារី ខី មិត្តនារី អឿន មិត្ត សារិន (ម្ចាស់អត្ថបទ) មិត្ត សាន មិត្ត រី ហៅ រី ឆ្នុក មិត្ត សារុន ហៅ តាសាច់បុក និង មិត្ត សំ បើកឡានឲ្យទូតគុយបា ។

រៀនសូត្រនយោបាយនេះចប់មក ខ្ញុំក៏ដូចជាអ្នកឯទៀតទៀតដែរ បាននាំគ្នាយកសម្ភារដែលប្រមូលបានយកទៅទុកដាក់ក្នុងឃ្លាំងទាំងអស់ ហើយលែងមានគំនិតចង់បានសម្ភារទាំងនោះមកជាកម្មសិទ្ធិឯកជនទៀតហើយ គឺម្នាក់ៗមានការប្តេជ្ញា និងយកតែកម្មសិទ្ធិសមរម្យ ដែលសម្រាប់ខ្ញុំជាអ្នកបើកឡាន មានតែកូនស្បោងមួយ មុងមួយ ភួយមួយ និងកូនសោឡានមួយតែប៉ុណ្ណោះ ។

ដល់រៀនវគ្គក្រោយៗទៀត ប្រហែលជាចូលឆ្នាំ១៩៧៧ ខ្ញុំបានចូលរួមរៀនវគ្គនយោបាយនៅបុរីកីឡា (ស្តាតអូឡាំពិក) ដែលហៅថាព-៦ របស់មជ្ឈិមបក្ស ដែលពេលនោះ ប៉ុល ពត, នួន ជា និង ខៀវ សំផន បានបង្រៀនកម្មាភិបាលមកពី ឃុំស្រុកតំបន់ទូទាំងប្រទេសយ៉ាងច្រើនកុះករ ។ សូមបញ្ជាក់ថា អំឡុងពេលរៀនសូត្រនោះ សូម្បីតែនោមក៏តម្រូវឲ្យនោមដាក់កន្ថោរដែរ មិនឲ្យនោមចោលទេ ។ មុនចាប់ផ្តើមរៀន អ្នកចូលរួមទាំងអស់ត្រូវគោរពទង់បក្សដែលមានរូបញញួរ និងកណ្តៀវ ហើយត្រូវច្រៀងចម្រៀងគោរពទង់បក្សមួយបទ ។ ក្រោកឡើងអស់អ្នកខ្ញុំគេទាំងប៉ុន្មាន ក្រោកឡើងអស់អ្នកក្រគោកយ៉ាករាល់ប្រាណ ក្តៅណាស់តឹងណែនស្ទើរប្រេះដើមទ្រូងធ្លាយ គ្រាម្តងនេះស្លាប់រស់មិនស្តាយ របបចាស់យើងបំផ្លាញឲ្យអស់ ឆាប់អស់អ្នកខ្ញុំគេក្រោកឈរឡើង ទៅថ្ងៃស្អែករបបថ្មីផងយើងបានមកវិញ ប្រយោជន៍ប៉ុន្មានធ្លាក់បានដៃយើង ។ តស៊ូនេះគ្រាចុងក្រោយបំផុតរួមគ្នាមកដល់ថ្ងៃមុខ អាំងទែណាស់សូណាល់ គឺជាសង្គមអនាគត ។

ប៉ុល ពត ស្ថិតក្នុងឯកសណ្ឋានខ្មៅ បង់កក្រមា និងស្ពាយកាដុងទឹកខ្លួនឯង ដោយមិនមានអ្នកណាបម្រើទេ ។ បើតាមការចងចាំរបស់ខ្ញុំ ដំបូង ប៉ុល ពត បាននិយាយថា នេះជាសំឡេងបក្សកុម្មុយនីស្តកម្ពុជា ហើយក្រោយមកទៀត ប៉ុល ពត បានលើកឡើងអំពីប្រវត្តិតស៊ូរបស់បក្សពេលនៅក្នុងព្រៃតាំងពីដើមរហូតដល់ចប់ ។ ប៉ុល ពត បានលើកឡើងទៀតថា បក្សយើងកំណត់យកឆ្នាំ១៩៦០ ជាចម្បង ជាថ្ងៃកំណើតរបស់បក្សយើង ហើយដែលយើងធ្វើដំបូងនៅវិរថភ្លើងមានគ្នាតែ៧នាក់ទេ ដោយសារខ្មាំងធ្វើទុក្ខបុកម្នេញ ។ តំណាងៗមកពីតាមបណ្តាភូមិភាគនៅទូទាំងប្រទេសមកប្រជុំគ្នានៅវិរថភ្លើង គឺចំថ្ងៃភ្ជុំតែម្តង ដូច្នេះបក្សយើងកំណត់ថា យកថ្ងៃភ្ជុំនេះជាថ្ងៃខួបកំណើតរបស់បក្សតែម្តង គឺថ្ងៃ៣០ កញ្ញា ជាថ្ងៃខួបកំណើតបក្ស ។

ក្រោយមកទៀត បក្សយើងនៅភ្នំពេញមិនបានចូលទេ នៅតស៊ូក្នុងព្រៃខាងភូមិភាគឦសាន ហើយបក្សយើងក៏ត្រូវជំងឺគ្រុនចាញ់ស្លាប់ទៅ មិនមែនបក្សយើងរាល់ថ្ងៃទេ ។ ពេល ប៉ុល ពត ឡើងនិយាយក៏មិនបានប្រកាសណែនាំប្រាប់ថា ខ្ញុំ ប៉ុល ពត លេខាបក្សអ្វីនោះទេគឺមិនមាននិយាយបញ្ចេញឈ្មោះអ្វីទាំងអស់ ។ ប៉ុល ពត បានបន្តទៀតថា បក្សយើងរីកធំធាត់យ៉ាងឆាប់រហ័ស ហើយបក្ខជនទាំងអស់ ទាំងបក្ខជនឆ្នាំ៤០ ទាំងបក្ខជនឆ្នាំ៥០ ទាំងបក្ខជនឆ្នាំ៦០ រហូតបក្ខជនបច្ចុប្បន្ននេះ គឺត្រូវកសាងខ្លួនឡើងជាថ្មី មិនថាបក្សចាស់ ឬបក្សថ្មីទេ ត្រូវកសាងខ្លួនជាថ្មីឡើងវិញទាំងអស់គ្នា ពីព្រោះពីមុនមកវាមិនស្អាតស្អំ ដោយសារមានការពាក់ព័ន្ធជាមួយវៀតណាមនេះ ប៉ុល ពត ចង់និយាយពីបក្ខជនឆ្នាំ៤០ និង៥០ ។ ហេតុនេះ ប៉ុល ពត បានកំណត់ថា ឆ្នាំ៦០នេះ បក្សយើងឯករាជ្យផុតពីអាណានិគមរបស់គេ ។

បន្ទាប់មកទៀត ប៉ុល ពត បាននិយាយអំពីមហាជ័យជម្នះរបស់បក្សចាស់ មហាជ័យជម្នះបក្សថ្មី ។ ប៉ុល ពត ចង់និយាយអំពីមហាជ័យជម្នះខ្មាំងស៊ីរូងផ្ទៃក្នុងដោយបានដាក់នាមថា មហាជ័យជម្នះនេះធំធេងលើសពីមហាជ័យជម្នះ១៧មេសា លើសពីមហាជ័យជម្នះលើកប្រព័ន្ធភ្លឺស្រែ ទំនប់ ប្រឡាយ ជាក្រឡាឈើត្រង់នៅពាសពេញផ្ទៃប្រទេសទៀត និងជាមហាជ័យជម្នះធំលើសសម័យមហាអង្គរទៀត ។ ប៉ុល ពត បានលើកឡើងទៀតថា ខ្មាំងនៅជាមួយយើងប្រៀបដូចស្រមោលអន្ទោលតាមប្រាណ ។ ការរកឃើញខ្មាំងដូចពួកក្បត់ដែលមាន កុយ ធួន ដោយសារតែរឿងសីលធម៌ទី៦ ហើយយូរៗទៅមានគំនិតក្បត់បក្សឯង ។ ហេតុនេះទើបបក្សយើងកំណត់ថា បើបុគ្គលណាខុសសីលធម៌ទី៦ គឺត្រូវកម្ទេចចោលតែម្តង នៅទូទាំងប្រទេសចាប់ពីថ្ងៃនេះតទៅ ។ ប៉ុល ពត ក៏បានឲ្យអ្នកចូលរួមទាំងអស់មើលពាក្យស្លោកធំៗដែលសរសេរនៅខាងស្តាំ និងខាងឆ្វេងដៃ ដែលមានផ្ទៃពណ៌ខ្មៅ និងអក្សរពណ៌សថា ទី១ កម្ទេច និងបោសម្អាត សេ.អ៊ី.អា អាមេរិក ដោយសំដៅទៅលើទាហាន លន់ នល់ មន្ត្រីអ្នករដ្ឋការដែលនៅសេសសល់ចាស់ៗនៅតាមបណ្តាសហករណ៍ នានានៅទូទាំងប្រទេស ។ ទី២ នៅខាងឆ្វេងដៃ គឺដាក់ថាកម្ទេច និងបោសសម្អាត កា.ហ្សេ.បេ សូវៀត

គឺសំដៅទៅលើអ្នកទៅរៀននៅសូវៀត និងភាគខាងជើង ។ ទី៣ កម្ទេច និងបោសសម្អាតខ្មាំងយួនវៀតណាមទីលេបទឹកដី ។ ទី៤ គឺខ្មាំង បង្កប់ស៊ីរូងផ្ទៃក្នុងជួរបក្ស ជួរបដិវត្តន៍ហើយ ប៉ុល ពត ក៏បានលើក ឡើងទៀតថា ការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង គឺឈរនៅលើ គោលជំហរទិតៀន និងស្វ័យទិតៀន ។ ប៉ុល ពត ក៏បានលើកឡើង ទៀតថា បើសមមិត្តណាមានពាក់ព័ន្ធជាមួយខ្មែរយៈខ្មាំង ត្រូវ សារភាពមក បក្សយើងមិនយកទោសពៃរ៍អ្វីទេ ចំពោះបុគ្គល ណាដែលស្គាល់ពីទោសកំហុសរបស់ខ្លួន ព្រោះបក្សយើងជាម៉ែ ជាឪ បក្សយើងជាឪពុកទី២ បន្ទាប់ពីម្តាយយើងបង្កើតមក មាន តែបក្សយើងទេ អប់រំសតិអារម្មណ៍ នយោបាយ គោលជំហរ ។ ចំពោះទី៥ ដែលជាខ្មាំងចុងក្រោយ គឺខ្មាំងសីលធម៌ ទី៦ កាលណោះ ខ្ញុំចាំថា ជនបដិវត្តន៍ទាំងអស់ ត្រូវគោរពសីលធម៌១២ប្រការ ។ សីលធម៌ទី៦ ចំលើរឿងស្រឡាញ់គ្នារវាងស្រី និងប្រុសនេះឯង ។ ប៉ុល ពត ក៏បានសង្កត់ធ្ងន់ទៀតថា ការស្រាវជ្រាវរកខ្មាំង គឺក្រោម នយោបាយដឹកស្មៅត្រូវដឹកទាំងឫស ។

ខ្ញុំយល់ថា ខ្មែរយើងស្លាប់រាប់លាននាក់ ដោយសារខ្មាំង ៥យ៉ាងនេះហើយ ក៏ដោយសារសាលាបង្រៀនកម្មាភិបាលនៅ បុរីកីឡានេះដែរ ព្រោះសាលាហ្នឹងជាសាលាបណ្តុះបណ្តាលកម្មាភិ បាលដែលមកពីថ្នាក់មូលដ្ឋានឲ្យមករៀន ។ បន្ទាប់មកទៀត ប៉ុល ពត និយាយអំពីបន្តលាក់ការណ៍បដិវត្តន៍ថា យើងបន្តលាក់ការណ៍ បដិវត្តន៍តទៅទៀត និងប្រពៃណីយាមកាមនៅដដែល ។ លាក់ការណ៍ បដិវត្តន៍នេះ មានដូចជាមិនដឹងមិនឮមិនឃើញ មិនចង់ដឹងការងារ មិត្តដទៃ ចង់គេទៅណាក៏មិនបាច់ចង់សួរដឹងពីគេទេ ហើយតាមបណ្តា ក្រសួង មន្ទីរនីមួយៗ សហករណ៍នីមួយៗ ត្រូវតែយាមកាមដដែល ដូចយើងពីសម័យសង្គ្រាម ។ ចំណុចទី៦ គឺឲ្យមានសញ្ជាតិតែមួយ ប៉ុណ្ណោះក្នុងកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុល ពត បានលើកឡើង ទៀតថា ខ្មែរយើងមានជនជាតិ១៦ គឺឲ្យមានតែសញ្ជាតិខ្មែរមួយ គត់ និងមិនឲ្យមានសាសនា មិនឲ្យមានសាសនាចាម និងទំនៀម ទម្លាប់បែបជនជាតិអ្វីទេ គឺមិនចំណេញដល់ការកសាងប្រទេស ។ ទី៧ ប៉ុល ពត បានលើកឡើងថា បក្សយើងបន្តការមិនចាយលុយ តទៅទៀត ។ ប៉ុល ពត បន្តទៀតថា បើចាយលុយនឹងធ្វើឲ្យខ្មាំង ទិញទឹកចិត្តបានហើយនឹងខាតមនុស្សដែលត្រូវកាន់លុយដូចជា បេឡាប៉ុន្មាន គណនេយ្យប៉ុន្មាន ចុះមួយប្រទេសប៉ុន្មាននាក់ ។ ខ្ញុំ ពេលនោះ មិនដឹងថាបេឡាហ្នឹងយ៉ាងម៉េច គណនេយ្យយ៉ាងម៉េច មិនទាំងដែលឮពាក្យនោះផង ។ ទី៨ វិស័យអប់រំ ប៉ុល ពត បាន លើកឡើងថា គាត់ឲ្យចេះតែអាន និងសរសេរទេ គឺនៅកន្លែងណា រៀនកន្លែងនោះតែម្តង សំខាន់គឺរៀនបច្ចេកទេស ខាងកសិករត្រូវ រៀនបង្កបង្កើនផលផង រៀនអក្សរផង ទៅនៅខាងកម្មករ ត្រូវរៀន បច្ចេកទេស ។ ចំពោះផ្នែកកីឡា ប៉ុល ពត បាននិយាយថា មិនមាន បញ្ជូនកីឡាទៅប្រកួតនៅលើឆាកអន្តរជាតិអ្វីទេ កីឡាយើងហ្នឹងគឺ កីឡាបង្កបង្កើនផល ។ ផ្នែកសង្គមកិច្ចសំដៅទៅលើផ្នែកថ្នាំពេទ្យ ប៉ុល ពត ថាឲ្យយកគំរូតាមសម័យបុរាណ គឺរកឫសឈើ មើមឈើ ដើម្បីធ្វើជាឱសថ ។ ប៉ុល ពត ក៏បានលើកឡើងអំពីសម័យសង្គ្រាម ជាមួយអាមេរិកដែរ ដោយបាននិយាយថា ចក្រពត្តិអាមេរិក គឺជា សត្រូវលេខមួយរបស់បក្ស និងប្រជាជនកម្ពុជាយើង ។

ទាំងអស់នេះ ខ្ញុំគ្រាន់តែចាំជាគោលខ្លះៗ ដើម្បីប្រតិចារឹក ទុកឲ្យកូនៗ ក្មួយៗជំនាន់ក្រោយបានដឹងថា ហេតុដូចម្តេចបានជា សង្គមជាតិក្លាយទៅជាយ៉ាងនេះ អ្នកខ្លះបានលើកឡើងថា ប៉ុល ពត មិនបានសម្លាប់មនុស្សទេ ។ ខ្ញុំយល់ថា ត្រូវហើយ ប៉ុល ពត មិនបាន សម្លាប់មនុស្សទេ ប៉ុន្តែគាត់បង្រៀនអ្នកដទៃឲ្យសម្លាប់មនុស្ស ។

បន្ទាប់ពីស្តាប់បទទេសនាមរបស់ ប៉ុល ពត រួចហើយ ក៏ បានឈប់សម្រាកដើម្បីបត់ជើងបត់ដៃ ។ សូមជម្រាបថា ការទៅ បត់ដៃបត់ជើងហ្នឹង ក៏តម្រូវឲ្យយើងបត់ដាក់ក្នុងពាងដែលបាន តម្រៀបជាជួររួចជាស្រេចសម្រាប់ទុកឲ្យយើង ។ បន្ទាប់ពីសម្រាក នួន ជា បានឡើងមកម្តង ដោយមិនបាននិយាយណែនាំឈ្មោះ របស់ខ្លួនប្រាប់ឲ្យអ្នកចូលរួមបានស្គាល់ទេ ។ ខ្ញុំនៅចាំថា នួន ជា បាននិយាយថា បន្ទាប់ពីនេះ ខ្ញុំសូមអានចម្លើយសារភាព ឯកសារ ជនក្បត់ដែលចាប់បានថ្មីៗ ។ នួន ជា បាននិយាយថា អា កុយ ធួន ហៅ ធុច អតីតជាប្រធានភូមិភាគឧត្តរ និងមួយទៀតឈ្មោះ សុទ្ធ ជាប្រធានគណៈតំបន់១០៦ តំបន់ស្វយ័ត សៀមរាប-ឧត្តរមាន ជ័យ ។ ឈ្មោះ យ៉ា ជាប្រធានភូមិភាគឦសាន និងឈ្មោះ ខឿន ជាគណៈមន្ទីរស-៧១ ឈ្មោះ ចាន់ ចក្រី ជាប្រធានកងពលនៅ ភូមិភាគបូព៌ា ឈ្មោះ សុខ និងឈ្មោះ ឈូក ។ អ្នកទាំងអស់នេះ មាន គម្រោងផែនការសម្លាប់បក្សដើម្បីយកអំណាចជាច្រើនលើក

ច្រើនសាតាំងពីក្នុងព្រៃរហូតមកដល់ពេលបែកការណ៍នេះ ហើយបានចាត់តាំងរចនាសម្ព័ន្ធរបស់ពួកវា គឺមាន កុយ ធួន ត្រូវកាន់ជាលេខាបក្ស ចាន់ ចក្រី ជាមេបញ្ជាការកងទ័ព ឌឿន ជារដ្ឋមន្ត្រីការបរទេស សុទ្ធ ជាប្រមុខរដ្ឋ យ៉ា កាន់ នៅគណៈរដ្ឋមន្ត្រី ។ ទាំងនេះជាការចងចាំរបស់ខ្ញុំពេលដែល នួន ជា បានអានឯកសារឲ្យអ្នកចូលរួមស្តាប់ ។ នួន ជា អានបន្តទៀតថា ចំពោះអ្នកខាងក្រោមៗ គឺគេរក្សាទុកដដែល ហើយផ្នែកបរទេស គឺមានទំនាក់ទំនងបរទេសជាមួយមិត្តចិនដដែល ក៏ដូចជាស្ថានទូតទាំងអស់ដែលមាននៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងទទួលយកទូតថ្មីៗថែមទៀត ប្រសិនបើចង់ដាក់ការទូតមកកម្ពុជា និងបន្តឲ្យមានការចាយលុយ ។ សកម្មភាពក្បត់របស់ពួកវា កុយ ធួន ជាមនុស្សដែលមានចរិតជាជនបដិវត្តន៍ដែលបានប្រព្រឹត្តខុសឆ្គងផ្នែកសីលធម៌ទី៦ ជាច្រើនលើកច្រើនសាតាំងពីនៅភូមិភាគឧត្តរមក ដើម្បីកុំឲ្យខូចឥទ្ធិពលរបស់ថ្នាក់ដឹកនាំបក្ស យើងក៏បានហៅមកនៅភ្នំពេញ ។ ក្រោយមក កុយ ធួន បានស្រឡាញ់នារីសិល្បៈម្នាក់ឈ្មោះ ខេង ដែលជាអ្នកចម្រៀងនៅក្នុងក្រុមសិល្បៈកម្ពុជាប្រជាធិបតេយ្យ និងជាប្រធានក្រុមសិល្បៈផង ។ តាមដែលខ្ញុំធ្លាប់ឃើញមិត្ត ខេង នេះមានសំឡេងពិរោះច្រៀងក៏ពិរោះ ធ្វើពិធីការនីក៏ពិរោះ រាងគាត់ស្អាតណាស់ ហើយខ្ញុំធ្លាប់បានជូនគាត់ម្តងទៅកាន់ក-៣៨ ។ នួន ជា បានអានទៀតថា សេចក្តីស្នេហារបស់នារី ខេង និង កុយ ធួន បានស៊ីជម្រៅជ្រៅទៅៗរហូតដល់មានគំនិតចង់សម្លាប់បក្សឯងយកអំណាច ព្រោះតែរឿងស្រី ដូច្នេះបក្សយើងកំណត់បុគ្គលណាដែលខុសសីលធម៌ទី៦ ចាត់ទុកជាជនក្បត់ ហើយត្រូវកម្ទេចចោលទាំងអស់នៅទូទាំងប្រទេសចាប់ពីថ្ងៃនេះទៅ ។ ក្រោយមកទៀត កុយ ធួន បានព្យាយាមបំបែកយុទ្ធជនឈ្មោះ ឡុង (ជាអ្នកចម្រៀងក្នុងក្រុមមិត្ត ខេង និងជាកងការពារថ្នាក់ដឹកនាំ) និងមិត្ត ខេង មិនឲ្យទាក់ទងគ្នា ហើយពេលនោះមិត្ត ឡុង ក៏បានរាយការណ៍ប្រាប់ ប៉ុល ពត អំពីរឿង កុយ ធួន បំបែកមិត្ត ឡុង មិនឲ្យស្រឡាញ់គ្នា ។ បន្ទាប់ពីបែកការណ៍រឿងនេះដល់ ប៉ុល ពត កុយ ធួន បានបញ្ជាឲ្យយកមិត្ត ឡុង ទៅសម្លាប់ចោលតែម្តង ។ រហូតដល់ពេលបក្សសួររកមិត្ត ឡុង កុយ ធួន បានប្រាប់ថា មិត្ត ឡុង ទៅលេងផ្ទះ ។ បក្សរង់ចាំមើលមិនឃើញមិត្ត ឡុង ត្រឡប់មកវិញនេះ ជាកំហុសទីមួយដែលបក្សយើងចាប់បាន ។

ក្រោយមកទៀត កុយ ធួន ក៏បានឲ្យនារី ខេង ហៅមិត្តនារីអ្នកដាំបាយ (ខ្ញុំមិនចាំឈ្មោះ) ឲ្យដាក់ថ្នាំបំពុលបក្សក្នុងម្ហូបបាយ ប៉ុន្តែចៃដន្យ ថ្ងៃនោះបក្សយើងក៏ឈឺធ្មេញ រួចក៏ឃើញកាយវិការនារីបម្រើបាយមានភាពរញ៉េរញ៉ៃខុសប្លែកពីធម្មតា បក្សយើងក៏ហៅនារីនោះមកសួរ មិនទាន់ទាំងបានសួរផង គ្រាន់តែដើរមកជិតបក្ស មិត្តនារីនោះក៏ស្រែកយំ ហើយរៀបរាប់ថា ខ្ញុំខុសហើយៗ អត់មាននិយាយអ្វីកើតទេ ស្រែកតែខ្ញុំខុសហើយៗ ។ បក្សយើងសង្ស័យក៏យកបាយ និងសម្លទៅចាក់ឲ្យឆ្កែស៊ី ឆ្កែក៏ងាប់ យកបាយទៅបាចឲ្យមាន់ស៊ី មាន់ក៏ងាប់អស់ ។ បន្ទាប់ពីនោះទៀត បក្សយើងនៅធ្វើការតាមដានបុគ្គល កុយ ធួន នេះរហូត ។ លុះដល់ថ្ងៃបុណ្យខួបជ័យជម្នះ ១៧ មេសា ១៩៧៥ ដែលធ្វើនៅស្តាត អូឡាំពិក ។ នៅពេលនោះ កុយ ធួន បានរើសយកយុទ្ធជនដៃឯកមួយចាំបាញ់សម្លាប់បក្ស ហើយ កុយ ធួន ពេលនោះក៏ទៅជាគណៈអធិបតីនៅក្នុងវេទិកានោះដែរ ។ កុយ ធួន កំណត់ថា ម៉ោង៩ ត្រូវឲ្យផ្ទុះអាវុធ ហើយពេលនោះជិត ដល់ម៉ោង៩ កុយ ធួន ក៏បាត់ពីវេទិកាទៅបន្ទប់ទឹក ។ កុយ ធួន ចេះតែចាំចេះតែឆ្ងល់ថា ម៉េចបានមិនឮស្នូរកាំភ្លើងផ្ទុះ នៅពេលនោះហើយដែលកងសន្តិសុខចាប់ខ្លួន កុយ ធួន ដាក់ខ្នោះតាំងពីពេលនោះមក ។ ចំណែកឯយុទ្ធជនដៃឯកត្រូវកងសន្តិសុខចាប់បានតាំងពីផ្លូវចូលមកម្ល៉េះ ។

នួន ជា ក៏បានអានឯកសារទាក់ទងនឹង ចាន់ ចក្រី ម្តងថា ចាន់ ចក្រី ក៏មានគម្រោងបាញ់សម្លាប់ ប៉ុល ពត ដែរ ។ ចាន់ ចក្រី បានឲ្យកងពិសេសទៅបាញ់កម្ទេចផ្ទះដែលបក្សយើងស្នាក់នៅ នៅខាងមាត់ទន្លេបាសាក់ ។ លើកទី១ ចូលទៅមិនបានសម្រេចដែលពេលនោះចូលទៅបាញ់ពេលយប់ ដោយបន្លំខ្លួនជិះទូកធ្វើជាអ្នកនេសាទ ។ លើកទី២ មកចាំបាញ់នៅក្បែរកោះមួយនៅទន្លេបាសាក់ ប៉ុន្តែផ្អើលអ្នកនេសាទ ផែនការនេះក៏មិនបានសម្រេចទៀត ។

បន្ទាប់មកទៀត ចាន់ ចក្រី ក៏បានផ្ញើសំបុត្រទៅ សុខ នៅតំបន់២៣ ដែលសំបុត្រនោះផ្ញើទៅតាមឡានរបស់អគ្គសេនាធិការមជ្ឈិម ។ លុះទៅដល់ អ្នកកាន់សំបុត្របានយកទៅឲ្យ សុខ នៅតំបន់២៣ ។ សុខ ជាមនុស្សមិនចេះអក្សរ ហេតុនេះហែកសំបុត្ររួចឲ្យអ្នកបើកឡានអានសំបុត្រនោះឲ្យស្តាប់ សំបុត្រនោះមានន័យថា គោរព

ជូនបង សុខ សូមបងផ្ញើត្រយូងចេកឲ្យខ្ញុំឲ្យបានច្រើន ព្រោះអីប្រពន្ធខ្ញុំជិតគ្រប់ខែហើយ ត្រូវការយកមកធ្វើម្ហូបដើម្បីជប់លៀងពីខ្ញុំចាន់ចក្រី ។ ក្នុងន័យនេះ ចក្រី ចង់មានន័យថា ចង់ឲ្យ សុខ ផ្ញើ B-៤០ ឲ្យបានច្រើន ។ អានរួចក៏ត្រូវបែកការណ៍ត្រឹមនេះ ដោយសារតែ សុខ មិនចេះអក្សរ លើសពីនេះទៀត អ្នកបើកឡាន គឺជាផ្ទៃក្នុងរបស់បក្សដែលបក្សចាត់តាំងឲ្យទៅ ។

នួន ជា បន្តអានឯកសារដែលទាក់ទងនឹងសមមិត្ត សុទ្ធ ថា សុទ្ធ កាលដែលមិនទាន់ទៅកាន់នៅតំបន់ស្វយ័តជិនាន់សង្គ្រាមអាកាសនៅក្នុងព្រៃ បក្សយើងទៅដល់ទីណា B-៥២ ទម្លាក់ត្រង់នោះ ហើយបក្សយើងចេះតែឆ្ងល់អាមេរិកហេតុអ៊ីក៏ដឹងម្ល៉េះ? ទៅត្រង់នេះដឹង ទៅត្រង់នោះដឹង ។ ដល់ថ្នាក់បក្សទៅកន្លែងណាដែលអាមេរិកទម្លាក់រួចបក្សទៅកន្លែងនោះ រំលងបានពីរបីថ្ងៃ អាមេរិកមកទម្លាក់ទៀត ។ ក្រោយមក បក្សបានបញ្ជូនមិត្ត សុទ្ធ នេះឲ្យទៅតំបន់១០៦ សៀមរាប-ឧត្តរមានជ័យ ក៏មកខាងក្នុងៗទៀត ក៏មិនមានសកម្មភាពអ៊ីដែរ បក្សក៏មិនចាប់អារម្មណ៍អ៊ីដែរ ។ ក្រោយមក តាមចម្លើយសារភាព សុទ្ធ នេះ ជា សេ.អ៊ី.អា របស់អាមេរិក ។ សុទ្ធ បានទៅទាក់ទង សេ.អ៊ី.អា ខាងព្រំប្រទល់ឧត្តរមានជ័យ ទាក់ទងដើម្បីឲ្យអាមេរិកមកវាយយកខ្មែរយើង ។ លើកទី១ សុទ្ធ និងអង្គរក្ស បានទៅចាំជួប សេ.អ៊ី.អា អាមេរិកនៅព្រំដែន ប៉ុន្តែមិនបានជួប ។ ទៅលើកទី២ ក៏ភាគីខាង សេ.អ៊ី.អា ខាង សុទ្ធ និងអង្គរក្សក៏មិនបានមកជួបខាង សេ.អ៊ី.អា អាមេរិកទៀត ។ ទៅលើកទី៣ ទើបបានជួប សេ.អ៊ី.អា និងបានសំណេះសំណាល និងស្នើឲ្យអាមេរិកវាយយកខ្មែរ ។

បន្ទាប់មក នួន ជា បាននិយាយអំពីសិក្ខាកាមទាំងឡាយសមមិត្តណាខ្លះដែលមានពាក់ព័ន្ធជាមួយខ្សែក្បត់ ត្រូវសារភាពត្រង់ៗ បក្សយើងមិនយកទោសពៃរ៍អ៊ីទេ ឲ្យតែមិត្តសារភាពជូនបក្ស ។ នួន ជា ក៏បានលើកដូចអ៊ីដែល ប៉ុល ពត លើកឡើងដែរថា បក្សយើងជាម៉ែជាឪ បក្សយើងមិនដែលយកទោសពៃរ៍សមមិត្តណាទេ ឲ្យតែសមមិត្តយល់ពីទោសកំហុសរបស់ខ្លួន ។ នួន ជា ក៏បានសួរថា មានសមមិត្តណាខ្លះដែលមានជាប់ពាក់ព័ន្ធធ្វើការងារជាមួយសូមលើកដៃ។ ក៏នាំគ្នាលើកដៃព្រូចំពោះអ្នកដែលពាក់ព័ន្ធ ហើយតាមខ្ញុំសង្កេតមើលអ្នកដែលលើកមានប្រហែលជា៦០ភាគរយក្នុងចំណោមអ្នកដែលបានទៅរៀន ។ នួន ជា លើកឡើងទៀតថា ចាំដាក់ចូលក្នុងពេលធ្វើជីវទស្សន៍ ហើយប្រសិនជាសមមិត្តយើងលាក់ បក្សយើងជាបក្សភ្នែកម្នាស់ អ៊ីចឹងសមមិត្តលាក់ក៏មិនជិតដែរ ហេតុនេះយើងមិនត្រូវលាក់ទេ ត្រូវតែលាតត្រដាងជូនបក្ស ។ ខ្ញុំនៅចាំបានពាក្យខ្លះទៀតដែល នួន ជា បាននិយាយគឺគាត់នឹងកសាងជនបទឲ្យទៅជាទីក្រុង ហើយកសាងទីក្រុងឲ្យទៅជាជនបទ ។ នួន ជា បានលើកឡើងទៀតថា កម្ពុជាប្រជាធិបតេយ្យប្រៀបបីដូចជាកង់ប្រវត្តិសាស្ត្រដែលកំពុងតែវិលអ៊ីចឹងបើសមមិត្តណាហ៊ានប្រឆាំង លូកដៃដាច់ដៃលូកជើង ដាច់ជើងហើយ។ អ៊ីចឹងមិនត្រូវប្រឆាំងនឹងកង់ប្រវត្តិសាស្ត្ររបស់បក្សទេ ។ បើសិនជាសមមិត្តណាម្នាក់ហ៊ានប្រឆាំង គឺត្រូវកម្ទេចចោល ដោយទុកមួយក៏មិនចំណេញ ដកចេញមួយក៏មិនខាត ។ នួន ជា ក៏បាននិយាយទៀតថា ទីណាមានការជិះជាន់ ទីនោះមានការតស៊ូ និងរើបម្រះ ។ នួន ជា បានលើកឡើងពីជំនាន់សង្គមសក្តិភូមិ មានការបះបោរចលនាតស៊ូជិះជាន់ ប្រជាជនយើងបានរើបម្រះដូចជានៅស្រុកសំឡូត ។

បន្ទាប់ពីសម្រាកបាយថ្ងៃត្រង់រួច ខៀវ សំផន បន្តពី នួន ជា ។ ពេលនោះ ខៀវ សំផន ដែលស្ថិតនៅក្នុងវណ្ណៈអធន គឺវណ្ណៈដែលគ្មានទ្រព្យ អាវរបស់គាត់រហែក ចំណែកស្បែកជើងវិញ គឺសឹកដល់អម្បោះ មើលទៅរាងរខេករខាកជាង ប៉ុល ពត និង នួន ជា ដែលតាមខ្ញុំយល់គាត់ចង់បង្ហាញពីការតស៊ូវណ្ណៈ ។ ពេលនោះ ខៀវ សំផន ចាប់ផ្តើមដោយលើកយកពីព្រឹត្តិការណ៍ជាតិ និងអន្តរជាតិថា ប្រទេសជាច្រើនចង់មកចងស្ពានមានមេត្រីចង់ដាក់ទូតជាមួយកម្ពុជាយើង ប៉ុន្តែប្រទេសខ្លះក៏យើងទទួល ហើយប្រទេសខ្លះក៏យើងមិនទទួលដែរ ។ កម្ពុជាយើងទីមួយ គឺមិនទទួលជំនួយបរទេសទេ ដោយប្រកាន់យកគោលជំហរឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ។ ទីពីរ ខៀវ សំផន បានលើកឡើងអំពីវិនាសសកម្មរបស់ចក្រពត្តិអាមេរិក ដែលបានបំផ្លិចបំផ្លាញមកលើទឹកដីកម្ពុជា គឺទម្លាក់គ្រាប់បែក មានរហូតទៅដល់ហាសិបប្រាំពីរលានតោនឯណោះ បើយើងយកមកចែកនឹងប្រជាជនប្រាំពីរលាននាក់ វាស្មើនឹងប្រាំបីតោនក្នុងប្រជាជនម្នាក់ដែលត្រូវរងគ្រោះដោយសារគ្រាប់ ។ ខ្ញុំចាំច្បាស់ណាស់អំពីការលើកឡើងនេះ ព្រោះតែខ្ញុំជា

ជនរងគ្រោះម្នាក់ដោយសារការទម្លាក់គ្រាប់របស់អាមេរិក ។

តមកទៀត ខៀវ សំផន បាននិយាយអំពីទំនាស់របស់ខ្មាំងយួនវិញម្ដង ។ គាត់លើកឡើងថា យួន ប្រណែននឹងយើង គ្រាន់តែយើងរំដោះមុននៅថ្ងៃ១៧មេសា ហើយ យួន រំដោះបាននៅថ្ងៃ៣០មេសា ។ សូម្បីតែបក្សយើងទៅប្រជុំនៅទីក្រុងកូឡំបូ ឆ្នាំ១៩៧៦ នៅប្រទេសស្រីលង្កា ដែលប្រជុំនៅសន្និសីទមិនចូលបក្សសម្ព័ន្ធ ហើយនៅពេលនោះលោកស្រីប្រធានាធិបតីប្រទេសស្រីលង្កាឲ្យបក្សយើងធ្វើជាប្រធានអង្គប្រជុំ ឃើញដូចនេះ ខ្មាំងយួនប្រណែនយើងទៀត ។ ខៀវ សំផន បន្តទៀតថា ក្រោយពីសង្គ្រាមអាកាសរបស់អាមេរិកបានបញ្ចប់នៅថ្ងៃ១៥ ខែសីហា ឆ្នាំ១៩៧៣ ហើយនៅខាងភាគីវៀតណាម បានចរចារវាងវៀតណាមទាំងពីរ ចំពោះខាងកម្ពុជាវិញគឺមិនចរចាទេ ដាច់ខាតត្រូវតែវាយតែម្ដង ។ ខៀវ សំផន បានបន្តទៀតថា អ្នកណាឈ្លោះគ្នាហើយទៅត្រូវគ្នាវិញយ៉ាងដូម្ដេច? ដាច់ខាតគឺត្រូវតែវាយតែម្ដងៗ ។ ដោយបក្សយើងឈ្លាសវៃ បក្សយើងក៏បានជម្លៀសប្រជាជនវៀតណាមចេញពីស្រុកទាំងអស់ ទាំងទាហាន ទាំងប្រជាជន ទាំងតំបន់ខាង លន់ នល់ ក៏ដូចជាខាងតំបន់រំដោះ ។ បក្សមានគោលការណ៍បង្កើនប្រជាជនឲ្យបានដប់លានទៅដប់ប្រាំលាននាក់ក្នុងរយៈពេលប្រាំទៅដប់ឆ្នាំនាពេលខាងមុខ គឺយុវជនដែលមានអាយុ២៥ឆ្នាំ ឯនារីមានអាយុ២០ឆ្នាំ ត្រូវរៀបការជាសមូហភាពចាំបក្សយើងរៀបការឲ្យ (បក្ខជនយកបក្ខជន សម្ព័ន្ធយកសម្ព័ន្ធ មហាជនយកមហាជន) មូលហេតុអីបានថា ចាំបក្សយើងរៀបការឲ្យ ព្រោះខ្លាចមិត្តនារីនោះកើតជំងឺឃ្លង់ ខ្លាចមិត្តយុវជននោះកើតជំងឺរបេង ឬក៏មានជាប់ពាក់ព័ន្ធជាមួយខ្សែរយៈក្បត់ នាំឲ្យម្នាក់ៗគ្មានអនាគត់ ។ ដាច់ខាតមិនឲ្យសមមិត្តម្នាក់ៗដើររើសខ្លួនឯងឡើយ ។ មូលហេតុដែលបក្សយើងឲ្យរៀបការជាសមូហភាព ព្រោះវាចំណេញអត់ខាតពេលវេលា ។ ខៀវ សំផន បានបន្តទៀតថា ឧទាហរណ៍កាលពីសង្គមចាស់ មានអ្នកខ្លះក្រទេ ឃើញគេដែលជាអ្នកមានរៀបការកូនគគ្រឹកគគ្រេង ក៏ធ្វើតាមគេដឹកស៊ី រាំរែកហោរកញ្ច្រៀវ សប្បាយអត់មានគិតថា ពេលរួចទៅខាតរកលុយសងចិនមិនបាន ក៏ចាប់ផ្ដើមលក់គោ លក់ក្របី លក់ស្រែភ្លឺ ដើម្បីយកលុយទៅសងបំណុលគេ រួចក៏ចាប់ផ្ដើមធ្លាក់ខ្លួនក្រ ព្រោះតែរឿងរៀបការកូន ។ អញ្ចឹងមកដល់ដំណាក់កាលកសាងបដិវត្តន៍សង្គមនិយម សព្វថ្ងៃនេះ បក្សយើងត្រូវតែមានផែនការរៀបអាពាហ៍ពិពាហ៍ជាសមូហភាពនៅទូទាំងប្រទេស ។

នៅតាមបណ្ដាសហករណ៍ កសិករនីមួយៗ នៅតាមបណ្ដាសហជីព កម្មករនីមួយៗ នៅតាមបណ្ដាអង្គភាពកងទ័ពនីមួយៗ ត្រូវឯករាជ្យម្ចាស់ការលើបញ្ហាស្បៀង និងមិនត្រូវដើរទៅសុំពីសហករណ៍នេះ មិនត្រូវដើរទៅសុំនៅអង្គភាពនោះ មកបំពេញឲ្យសហករណ៍ខ្លួន ឬសហជីពខ្លួន ឬអង្គភាពខ្លួនឡើយ ។ ហូបចុកត្រូវឲ្យមានលក្ខណៈជាសមូហភាព តាមសហករណ៍ តាមសហជីព តាមអង្គភាពកងទ័ព ត្រូវហូបតាមកង ត្រូវហូបតាមក្រុម ត្រូវហូបតាមពួក មិនត្រូវហូបជាសេរីមានលក្ខណៈបុគ្គលឡើយ ។ បានជាបក្សយើងមានផែនការឲ្យហូបជាសមូហភាព ព្រោះខ្លាចខ្មាំងមកបន្លំ ។

ខៀវ សំផន បាននិយាយថា អ្នកដាំបាយត្រូវតែចេះកែច្នៃ ១-មានបាយនោះមួយមុខទៅ ២-មានសម្លនោះមួយមុខទៅ ៣-មានទឹកត្រីនោះមួយមុខទៅសរុបមកត្រូវធ្វើឲ្យបានបីមុខនេះ អញ្ចឹងត្រូវចាំ ។ រៀងរាល់ថ្ងៃទី១០ ថ្ងៃទី២០ ថ្ងៃទី៣០ ដែលជាថ្ងៃឈប់សម្រាកពីការងារស្នូលត្រូវមានបង្អែមហូបម្ដង បើយើងហូបបង្អែមរាល់ថ្ងៃខ្លាចកើតជំងឺទឹកនោមផ្អែម ហើយរាល់ថ្ងៃទី១០ ថ្ងៃទី២០ ថ្ងៃទី៣០ ដែលជាថ្ងៃឈប់សម្រាកពីការងារស្នូលនេះ ត្រូវទៅធ្វើការងារសង្គមនិយមដូចជាដាំបន្លែបង្កាគ្រប់បែបយ៉ាង ដើម្បីឧបត្ថម្ភដល់សហករណ៍ ឬសហជីពរបស់ខ្លួន ឬអង្គភាពរបស់ខ្លួនត្រូវចេះសន្សំសំចៃតាំងពីអំបិល ប្រហុក ផ្អក មិនត្រូវលើកទាំងពាងធំមកហូបទេ ត្រូវចេះរំលែកពីពាងធំមកដាក់ពាងតូច ឬក្រឡតូចៗយកមកហូប ។ តាមបណ្ដាសហជីព ឬសហករណ៍ ក៏ដូចជាអង្គភាពកងទ័ព ត្រូវបំពាក់គោលជំហរវណ្ណៈអធន ដោយយកវណ្ណៈកសិករក្រ និងកសិករកណ្ដាលថ្នាក់ក្រោមជាគំរូ មានន័យថា កសិករក្របានហូបព្រឹកខ្វះល្ងាច កសិករកណ្ដាលថ្នាក់ក្រោមក្នុងមួយឆ្នាំខ្វះហូបបីខែ ដូច្នេះម្នាក់ៗត្រូវចេះតស៊ូវណ្ណៈក្នុងការហូបចុកដោយបំពាក់គោលជំហរវណ្ណៈទាំងពីរនេះជាមូលដ្ឋានគ្រឹះ ។

**(តទៅលេខក្រោយ)**

**ស សារិន**

# ព្រលឹងមាសម្តាយ

***(តពីលេខមុខ)***


អ៊ុង វណ្ណា ម្ចាស់អត្ថបទ

តែសេចក្តីឈឺចាប់ចុងក្រោយនេះទេ ដែលអាចប្រៀបប្រដូចបាន វាស់វែងបានទៅតាមការដ្ឋានការងារសស្រោកសស្រាំ គ្មានសម្រាកចាប់ពីកុមារអាយុ ៥ឆ្នាំឡើងទៅ សុទ្ធតែត្រូវចុះឈ្មោះបញ្ចេញកម្លាំងពលកម្ម ទើបបានទទួលរបបអង្ករប្រចាំថ្ងៃនេះ ជាយុទ្ធសាស្រ្តសកម្មប្រយុទ្ធរបស់អង្គការ ។ នៅក្រៅម៉ោងធ្វើការរួមប្រជាកសិករថ្មី តែងតែខំឆ្លៀតពេលដាំដំណាំយុទ្ធសាស្រ្ត ដំឡូងឈើ ដំឡូងជ្វា ត្រសក់ ត្រឡាច ឃ្លោក ល្ពៅ គ្មានឈប់ឈរទេ ។ យើងចេញពីភ្នំពេញមកក្នុងរដូវប្រាំង ដើមរដូវវស្សា៧៥ ជាក្តីទន្ទឹងរង់ចាំបេះយកភោគផលដែលយើងខំដាំដុះគ្មានទំនេរដៃ និងដាំមិនឲ្យសល់ដីមួយចំអាមនេះ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយម៉ោងទៅមួយម៉ោង យើងតាមគយគន់ដំណាំព្រោងព្រាតនៅលើដីឡូត៍ជាប់ផ្ទះដែលបក្សចែកឲ្យនេះ ក្នុងក្តីរំពឹងថា ជាពន្លកត្រួយខ្ចីនៃជីវិតគ្រួសារ ។ ដំណាំដែលតែងតែលូតលាស់បកត្រួយរវិច ក្តីសង្ឃឹមរបស់ក្រពះ ក៏ចេះតែរីកដុះដាលធំធាត់ឡើង ក្នុងរវាង៣ខែទៅ៦ខែខាងមុខ ខ្ញុំនឹងលែងរមូលឈឺផ្សារដោយការអត់ឃ្លានទៀតហើយ មាគ៌ាដឹកនាំរបស់អង្គការគួរឲ្យស្ងើចសរសើរណាស់ ពោរពេញទៅដោយភាពស្ងប់ស្ងាត់ឥតជ្រួលជ្រើម អ្នកណាក៏ដាំ អង្គការក៏ដាំ ជាន់ទាបរហូតដល់បក្សដឹកនាំជាន់ខ្ពស់ក៏ដាំ ។ សំណាកសាកសព និងគ្រាប់រំសេវនៃសង្រ្គាមបានក្លាយជាប្រភពជីជាតិនៃភោគផលដំណាំក៏ល្អត្រកុំត្រកាល ។ យើងច្បាស់ជារួចផុតពីការរើសគ្នោតទុំ បេះត្រកួនទៀតហើយ ។

កន្លះខែម្តង អ្នកសកម្មការងារអាចសុំអនុញ្ញាតច្បាប់ពីអង្គការភូមិទៅរកដោះស្រាយជីវភាពប្រចាំថ្ងៃ ។ អង្គការបានប្រាប់ដំណឹងយើងអំពីការបើកផ្សារណាត់ សម្រាប់ដោះដូរស្បៀង នៅកំពង់ចម្លងព្រែកក្តាម និងកំពង់ហ្លួង ដែលប្រើប្រាស់អង្ករជារូបិយបណ្ណ ឬហិរញ្ញវត្ថុកណ្តាល សម្រាប់ការដោះដូរសេចក្តីត្រូវការ ។ ខ្ញុំក៏ដូចជាប្រជាជនដទៃទៀត តែងរកឱកាសសុំច្បាប់ទៅដោះស្រាយជីវភាព ។ ខ្ញុំមិនបានទៅព្រែកក្តាមទេ ព្រោះថា តាមពិតមានតែប្រជាជនមូលដ្ឋានចាស់ទេ ដែលនៅសល់ស្រូវអង្ករពីរដូវប្រាំងដើមឆ្នាំ៧៥ អាចទៅដោះដូរត្រីសាច់ ប្រហុក ផ្អក ពោត សណ្តែក នៅផ្សារព្រែកក្តាមបាន ។ ប្រជាជនថ្មីបានទទួលរបបអង្ករកន្លះកំប៉ុងក្រោមកម្លាំងពលកម្មមួយថ្ងៃៗ ពី១២ ទៅ ១៨ម៉ោង តើអ្នកណាម្នាក់អាចយកអង្ករមានតម្លៃនេះទៅដោះដូរវត្ថុផ្សេងៗបាននោះ? ពេលនេះ តើមាសពេជ្រកែវកងពីទូរស្នូរកានឯណាមានតម្លៃប្រៀបស្មើនឹងបាយមួយដុំបាន? ដូច្នោះ ខ្ញុំជាមួយនឹងមិត្តអ្នកជម្លៀសថ្មីពីរបីនាក់ធ្វើដំណើរទៅខាងកំពង់ហ្លួងវិញ ជាទីដែលយើងអាចស្វែងយល់ពីទិដ្ឋភាពនៃការដូរដោះក្នុងផ្សារផង និងអាចឆ្លៀតរកបេះត្រកួនផ្ទីរមកលាយជាមួយបាយ ឬស្លដាក់បន្លែឲ្យបានច្រើនជាទ្រនាប់នៃការឈឺផ្សាក្រពះរបស់យើងបានផង ។ យើងបានឃើញថ្ពល់ជាតិឡើងវិញនៅថ្ងៃនេះ ហាក់ដូចបានឃើញអ្នកម្តាយត្រឡប់មកពីផ្សាររាងកាយស្គមស្គាំង សម្លៀកបំពាក់ចម្រុះពណ៌ ប្រជាពលករមួយចំនួនធ្វើដំណើរថ្មើរជើង ឬកង់មានបាវជាប់នឹងខ្នង បោះពួយយ៉ាងលឿនសំដៅទៅស្រែត្រកួន ។ នៅលើដងថ្នល់ជាតិ យូរៗជួបនឹងរថយន្តមួយៗ សមមិត្តដែលជិះក្នុងរថយន្តទាំងនោះ ទាំងនារីទាំងយុទ្ធជន ប្រកបដោយសាច់ឈាមស្រស់ថ្លាទ្រលុកទ្រលន់ក្នុងសម្លៀកបំពាក់ខ្មៅក្រិប បង់កក្រមាក្រហម មើលទៅហាក់ដូចជាផ្ការីកក្រឡង់ អើតចេញពីគ្របកបទុមខ្មៅ រថយន្តបោះពួយពីជើងទៅត្បូង ពីត្បូងទៅជើង ។ មានតែយុទ្ធមិត្តអ្នកតស៊ូទាំងនេះទេ ដែលមានវាសនាចេញចូលទីក្រុងភ្នំពេញ តើទិដ្ឋភាពភ្នំពេញសព្វថ្ងៃនេះយ៉ាងណាទៅ ផ្ទះ សាលា រៀន សៀវភៅយើងយ៉ាងណាទៅ? ឱ! ភ្នំពេញអើយខ្ញុំនឹកអ្នកខ្លាំងណាស់!

នៅតាមដងផ្លូវព្រះវិហារកំពង់ហ្លួងដួលបាក់បែកយ៉ាងដំណំ សំបកកន្ទុះគ្រាប់បែក គ្រាប់ផ្លោង តូច-ធំ ឆ្អឹងខ្មោចទាហាន និងប្រជាករគ្រប់ប្រភេទគ្រប់វ័យ នៅតែដេកសណ្ដូកគងគាក់ព័ទ្ធព័ន្ធលើគ្នា លាក់ក្រោមស្មៅលតាវល្លិ៍ខែវស្សា ដែលដុះទ្រុបទ្រុលបញ្ចេញស្លឹកធំៗ ស្លឹកបាស់ ជ្រលង់ ផ្ទីរ លូតលាស់ប៉ុនចានឡូ នេះជាឱកាសរកវល្លិ៍ជួបផ្ដៅហើយ ។ ឃើញភ្លាម ថ្មើរជើងយើងក៏ប្រញាប់ប្រញាល់នាំគ្នាចូលបេះឥតសំចៃ តែឈានជើងមួយជំហានណា ក៏ជាន់លើលលាដ៏ក្បាល ឆ្អឹងស្មង អដ្ឋិសន្ថលិកអ្នកដែលត្រូវសង្គ្រាមផ្ដាច់ផ្ដិលជីវិតទៅដែរ គ្មានរួចមួយជំហានណាទេ ។ ក្ដីសង្វេគ អណោចអាធ័ម បានដាស់ការចងចាំរបស់យើងឡើងវិញឲ្យឈឺពើតផ្សា ។

ឱ! កំពង់ហ្លួងដួងមាសដាក់កម្មចិញ្ចៀនកន្សែងស្រែកផ្ដាំឲ្យចិត្តចងចាំអាល័យ បើបងរៀបការប្រាថ្នាគូថ្មី បងអើយកុំភ្លេចហៅស្រីចងដៃប្រុសថ្ងៃកុំខាន... ។

ឱ! កំពង់ហ្លួងអើយ! ដើមឡើយជាមួយនឹងបទចម្រៀងរឿងព្រាត់ស្នេហាដ៏ពិរោះក្រអួនរបស់អ្នកស្រី សូរ សាវឿន ប៉ុន្តែក្ដីសង្វេគអនិច្ចារបស់ខ្ញុំចំពោះអ្នកពេលនេះ មិនមែនពីព្រោះតែរឿងស្នេហារបស់នរណាម្នាក់នោះទេ ប៉ុន្តែគឺជាក្ដីសង្វេគឈឺផ្សាចំពោះវាសនាជាតិខ្មែរទាំងមូល ដែលត្រូវនិរាស្ត្រព្រាត់ប្រាស់ពីផ្ទះសម្បែង ពីផ្នូលជាតិ ពីព្រះវិហារ ពីបដិមា ជាទីសក្ការៈ! យើងបាត់បង់អស់ហើយ អ្វីៗសុទ្ធតែជាចក្រពត្តិទាំងអស់ ។ តើបដិវត្តន៍នេះជាអ្វីទៅ? បើយើងសម្លឹងមើលតាមបណ្ដោយផ្លូវជាតិទៅទិសខាងភ្នំពេញ ផ្ទះតូច-ធំ អគារបាក់បែកនៅឈរជង្គ្រឹងស្ងាត់ឈឹងកណ្ដោកណ្ដែងគ្មានម្ចាស់ អីវ៉ាន់ធ្លាក់រប៉ាត់រប៉ាយ ។ ចុះគំនរអ្វីស្ពងៗនោះ នៅក្បែរឡានឆេះនោះ? តោះយើងទៅមើល ។ ឱ! គឺជាគំនរសម្លៀកបំពាក់ និងសៀវភៅ ឯកសារគ្រប់ប្រភេទ ឆេះខ្លោចខ្មៅពាក់កណ្ដាល ឱ! ប្រហែលជាពេលដែលកំពុងដុតត្រូវភ្លៀងបង្អុរមក ហើយបានជានៅសល់យ៉ាងនេះ ។ ចុះហេតុអ្វីក៏មិនទុកចែកឲ្យប្រជាជនប្រើ ។ ទេ! យើងដឹងហើយថា អង្គការដឹកស្មោគឺដឹកទាំងឫស អង្គការកម្ទេចចោលទាំងអស់នូវកាកសំណល់ចក្រពត្តិ ទុកឲ្យប្រជាជនកសាងជីវិតដោយដៃទទេចុះ ឱ! សៀវភៅ ដ៏មានសារប្រយោជន៍អើយ តើអ្នកឈឺផ្សាយ៉ាងណា?

## ស្រែខ្ញាញ់ ខ្ញាញ់ស្រែ

ខែសីហា ឆ្នាំ១៩៧៥ ក្នុងវាលស្រែនៃសហករណ៍នីមួយៗនាស្រុកខដុង្គ កំពុងតែលេងខ្លួនមូលដើម កន្ទុយឆ្នាំងមួយៗ បញ្ចេញក្លិនប្រហើរពិដោរឈ្ងុយឈ្ងប់ ។ ឱ! ដីព្រៃដ៏សើងជាបន្ទាក្រាសក្រៃដែលយើងបានកាប់ឆ្ការឲ្យក្លាយជាវាលរាប ឥឡូវយើងស្ទូងជាស្រូវលូតលាស់បានល្អត្រកាលពេញវាលហើយ យើងចង់ឃើញអ្នកទំឆាប់ៗទៅ អ្នកជាសេចក្ដីសង្ឃឹមនៃការមានហូបចុកគ្រប់គ្រាន់ឥឡូវនេះកាន់តែខិតទៅមុខហើយ ។ នៅតាមកូនផ្ទះរបស់យើងស្លឹកគ្រៃ ឃ្លោក ត្រឡាច ល្ពៅ ដំឡូង លាស់ត្រួយរវិច យើងអាចបេះស្លឹកផ្ទីរ ត្រួយល្ពៅជាបន្លែបានបណ្ដើរហើយ ហើយទៅមុខទៀត យើងនឹងបានស្គាល់រសជាតិមើមដំឡូងដ៏ផ្អែមឡើងវិញហើយ តើអ្នកឆ្ងាញ់យ៉ាងណា? រមូលពោះប្រួចៗ ស្រក់ទឹកមាត់ប្រាវ នឹកឃើញរសជាតិដែលយើងស្គាល់តែតាមក្ដីស្រមៃទាំងនេះ យើងនឹងបានស្គាល់រសជាតិផ្អែមនៃបាយសុទ្ធដែលគ្មានលាយត្រកួន ឬស្លឹកដំឡូងនាពេលប៉ុន្មានខែខាងមុខនេះ ឆ្ងាញ់យ៉ាងណាទៅ! យប់នេះកសិករអភ័ព្វនៃភូមិធំ ឃុំខ្វាត់ព្រាយទាំងមូលកំពុងនិទ្រាលក់ក្នុងក្ដីផ្ញើកងុយលង់លើយ ដោយការនឿយហត់ជាមួយទម្ងន់នៃពលកម្មយ៉ាងធុនជាបពីពេលថ្ងៃ ស្រាប់តែស្នូរស្លឹកត្នោតដែលប្រក់លើកូនខ្ទមលាន់ព្រាកៗ ហើយគ្រែឫស្សី ឬធាងត្នោតដែលយើងកំពុងសម្រាន្តបានញ័រគ្រលែងឡើង ។

ក្រោកឡើងៗម្ចាស់ផ្ទះ អង្គការឲ្យរៀបចំអីវ៉ាន់កន្លះម៉ោងដើម្បីធ្វើដំណើរទៅច្រូតស្រូវឯបាត់ដំបង ។ ខ្ញុំស្ទុះទៅក្រៅខ្ទម ដើរបណ្ដើរ ញីភ្នែកបណ្ដើរ នៅពីមុខខ្ទមយើងមានរទេះមួយបញ្ឈរចាំរួចជាស្រេច ក្រឡេកមើលទៅកូនខ្ទមសងខាងពីរបីទៀត ក៏សុទ្ធតែមានរទេះមួយៗ នៅឈរចាំពីមុខដូចគ្នាជាមួយនឹងអ្នកបរម្នាក់ដែលកំពុងដឹកក្របីឲ្យស៊ីស្មៅនៅក្បែររទេះផង ។ ឱ! នោះគឺជាផែនការដែលបានគ្រោងទុកយ៉ាងច្បាស់លាស់ ។ មិត្តបងអើយ តើអង្គការឲ្យដឹកយើងខ្ញុំទៅណា? អ្នកម្ដាយសួរទៅអ្នកបររទេះដែលជាប្រជាជនអ្នកមូលដ្ឋានចាស់ ។ ទៅច្រូតស្រូវនៅស្រែខ្ញាញ់ រៀបចំអីវ៉ាន់ឲ្យឆាប់ទៅ អង្គការនៅទីនោះនឹងផ្គត់ផ្គង់របបអង្ករដល់បងប្អូនយើងមួយថ្ងៃ៣កំប៉ុង ព្រោះនៅបាត់ដំបង ស្រូវកំពុងតែទុំខ្ទង់ដួលពេញវាលស្រែកម្លាំងយោធាទីនោះ មិនអាចប្រមូលផល

ស្រូវទាន់ពេលវេលាទេ ទើបអង្គការឲ្យបញ្ជូនសហករណ៍យើងទៅជួយ ។អ្នកបររទេះឆ្លើយរ៉ាយរ៉ាប់មកយើង ។ មិនអាចទុកចិត្ត យើងបានឆ្លៀតដាក់ដាំបាយលាយត្រកួនមួយឆ្នាំងពេញក្តាម ដាក់ទៅហូបតាមផ្លូវ ព្រោះមិនដឹងជាដល់ត្រង់ណាទើបអង្គការឲ្យយើងឈប់ដាំបាយហូបទេ ។ អ្នកម៉ែប្រាប់មកខ្ញុំ ។ រួចម៉ែដើរទៅក្រោយរកបេះក្តិបត្រឡាច ននោង ដកដំឡូងយើងដែលទើបនឹងចុះមើមប៉ុនកូនដៃ ។ យើងទន្ទឹងវាដោយក្តីស្រេកឃ្លានយូរមកហើយ ជិតដល់ពេលបានផល យើងត្រូវជម្លៀសចេញទៅមុខទៀត ។ ឱ! មហាវាលទុរភិក្សអើយ អីក៏វែងដូចលំហាចក្រវាឡយ៉ាងនេះ ។

ប្រយោគថា ទៅដល់បាត់ដំបងយើងនឹងបានទទួលរបបអាហារពាក់ប៉ុងម្នាក់ក្នុងមួយថ្ងៃ ធ្វើឲ្យក្រុមគ្រួសារខ្លះដែលអង្គការមិនទាន់ដាក់ទិសឲ្យចាកចេញទៅ ក៏ស្ម័គ្រចិត្តសុំទៅជិះខ្លាញ់ជាមួយនឹងក្រុមលើកទី១នេះដែរ ពីព្រោះថា ការហូបឆ្អែតជាសេចក្តីប៉ងប្រាថ្នាដ៏ធំបំផុត និងតែមួយគត់របស់យុគសម័យពលកម្មធ្ងន់អាហារស្តួចស្តើង និងមិនចាយប្រាក់នេះ ។

បាត់ដំបងជាខេត្តល្បីសុះសាយថា ជាជង្រុកស្រូវនៃប្រទេសកម្ពុជា ។ កាលពីជំនាន់សម្តេចឪ ពលរដ្ឋខ្មែរគ្រប់រូបនរណាក៏ដឹងដែរថា ខេត្តបាត់ដំបងតែឯង អាចផ្គត់ផ្គង់ផលិតផលស្រូវសម្រាប់ចិញ្ចឹមជីវិតមនុស្សបានពាក់កណ្តាលនៃចំនួនប្រជាជនទូទាំងប្រទេស ។ ព័ត៌មានថា អង្គការដាក់ទិសឲ្យទៅច្រូតស្រូវនៅបាត់ដំបងនោះ ជាការជឿជាក់បាន ។

សំឡេងត្រដោករទេះឡើង ពាបទយ៉ាងកងរំពង ពីមន្ទីរសហករណ៍ អ្នកបររទេះគ្រប់រូបប្រញាប់ប្រញាល់ទាញក្របីបញ្ចូលនឹមរួចបង្ខំអ្នកម្ចាស់លំនៅឲ្យលើកអីវ៉ាន់ដាក់ រួចចេញដំណើរភ្លាម សូរសន្ទឹកគោ ជើងគោ ជើងក្របី ត្រដោក កណ្តឹងរឹងៗ រ៉េកៗ ស្នូរកង់រទេះង៉េតង៉តលាន់ឮឡើងពីគ្រប់ច្រកល្ហកនៃសហករណ៍បន្តកន្ទុយគ្នាមកតាមទិសតែមួយ សំដៅទៅកំពង់ហ្លួងគ្មានឮសូរមាត់មនុស្សមួយម៉ាត់ណាទេ គ្មានការជជែកសន្ទនាគ្នាទេ ម្នាក់ៗមានតែការស្ងាត់ស្ងៀមស្ងួនឡឹង ។ ទ្រឹស្តីបទដាំដើមគជាមេរៀនដែលលាន់ឮរំពងក្នុងអារម្មណ៍យើង ។ ព្រលឹមស្រាងៗ យើងទៅដល់កំពង់ហ្លួងកប៉ាល់ដ៏ធំៗពីរបណ្តែតខ្លួនលើដងគង្គារ រង់ចាំអ្នកដំណើរអភ័ព្វកប៉ាល់នីមួយៗផ្ទុកចំណុះ២០០នាក់ ។ ពួកយើងត្រូវគេប្រាប់ឲ្យចុះព្រឹបៗ យ៉ាងត្រៀបត្រាទៅក្នុងនាវា ។ ម៉ោងប្រមាណ៧ព្រឹក ក្បួននាវាកំសត់បានស្រែកវោទ៍ លាប្រាំងទៅសមាជិកគ្រួសារខ្លះបង្ខំចិត្តដាក់សាកសពសាច់សន្តានចោលនៅតាមចិញ្ចើមផ្លូវជាតិលេខ៥ គ្របដោយស្លឹកឈើទាំងសោកសង្រេង ។ នាវាចរទៅមុខយ៉ាងលឿនលយ មិនដឹងថាអង្គការដឹកយើងទៅកាន់ទីណាខ្លះទេ ទោះបីជាទិដ្ឋភាពព្រឹក្សព្រៃនៃដងទន្លេមេគង្គនេះស្រស់ត្រកាលយ៉ាងណាក្តី តែក្នុងចិត្តយើងសែនព្រួយចម្បែង ។ ភ្នំអ៊ីនៅដេកសណ្តូកក្នុងលំហទឹកល្ហាចល្ហឹមនៃរដូវវស្សាយ៉ាងនេះ បឿនត្រកួនធំៗរាប់ហិកតា ក្រាស់ឃ្មឹកអណ្តែតលើផ្ទៃទឹក មានទងថ្លៅសៗ ប៉ុនៗម្រាមដៃ ប្រហែលជាគ្មានអ្នកណាអាចមកបេះទេ បានជាល្អយ៉ាងនេះ យើងចូលមកដល់ទីក្រុងហើយ គេហដ្ឋានខ្លះ មានស្លាកអាសយដ្ឋាននៅព្យួរជាប់នៅឡើយ ដែលនាំឲ្យយើងដឹងបានថានេះជាទីក្រុងកំពង់ឆ្នាំង ដូច្នោះ ភ្នំដែលមានរាងដូចស្រ្តីយក្សមួយដេកសណ្តូកនោះ គឺប្រាកដជាភ្នំនាងកង្រីហើយ ។ ឱ! បទចម្រៀងកំពង់ឆ្នាំងបាំងភ្នំកង្រីរបស់លោក ស៊ីន ស៊ីសាមុត ពិតជាត្រូវនឹងទិដ្ឋភាពនេះមែន ។ នាវាបានចូលចតនៅក្រុងកំពង់ឆ្នាំង ។

ក្បួនរថយន្តកាំមីញ៉ុង៧គ្រឿង តម្រៀបគ្នាត្រៀបរង់ចាំដឹកយើងទៅមុខទៀតហើយ ។ គេដឹកយើងតាមបណ្តោយផ្លូវជាតិលេខ៥ ដែលពុះជ្រែកវាលស្រែបៃតងស្រស់ខ្ចីគួរឲ្យរីករាយណាស់ បាត់ដំបងច្បាស់ជាមិនចាញ់កំពង់ឆ្នាំងឡើយ ។ រថយន្តទាំងបានទម្លាក់យើងនៅខេត្តពោធិ៍សាត់ ក្បួនរថភ្លើង២ខ្សែ បានបន្តដឹកជញ្ជូនយើងបន្តទៅខេត្តបាត់ដំបង ។ ចេញផុតពីទីរួមខេត្តពោធិ៍សាត់មកដល់ស្រុកមោងឫស្សីវាលដែលពោរពេញទៅដោយគុម្ពស្រូវដ៏ធំៗបានត្រូវជំនួសដោយវាលស្មៅ វាលកំប្លោក វាលស្មោរណែនណាន់ ។ ឱ! តើបាត់ដំបងយ៉ាងណាទៅ? ទទេ! គ្មានស្រូវសោះ គួរឲ្យបុកពោះភិបៗមែន ។ ២០គីឡូ ខាងជើងមោងឫស្សីសំឡេងគ្រឿងចក្ររបស់រថភ្លើងបានថយចុះចង្វាក់ ល្បឿនកង់រថភ្លើងក៏ចេះរង្វេលទៅៗ ។ គិតគេដាក់យើងចុះនៅតំបន់ឥតស្រូវនេះទេដឹង? ជាការពិតណាស់ រថភ្លើងបានអស់ល្បឿនឈប់ង៉ក់នៅទីនេះ ។

សំឡេងឃោសនសព្ទរបស់សមមិត្តអ្នកដឹកនាំដំណើរបានលាន់ឮឡើងដល់កន្លែងចុះហើយ សូមបងប្អូនជញ្ជូនអីវ៉ាន់ចុះមក

ហើយធ្វើដំណើរទៅតាមយោធាមួយកងដែលមកទទួលយកបងប្អូនទៅកាន់សហករណ៍ដើម្បីធ្វើការរួមចំណែកកសាងមាតុភូមិជាទីស្នេហានៃយើង ។ នៅទីនេះ ពុកម៉ែ មារមីង យុវជន យុវនារី នឹងបានរួមចំណែកពេញលេញក្នុងការប្រយុទ្ធស្ដាមាតុភូមិយើងឲ្យបានរុងរឿង ។ ស្មានមិនដល់មែនពាក្យពេជ្រដ៏មានន័យរបស់យុទ្ធមិត្តបដិវត្តន៍ ទៅជាធ្វើឲ្យស្រងាកចិត្តស្ទើរទ្រហោយំ ដើរកាត់វាលកណ្ដាលថ្ងៃក្ដៅហែង ស្រែនីមួយៗឃើញតែស្នាមរណ្ដៅជីកក្ដាមពាសពេញ ឈានស្ទើរតែមិនផុតមួយជំហានណាឡើយ នេះច្បាស់ជាមានអ្នកមករស់នៅទីនេះមុនយើងជួបប្រទះនឹងការខ្វះខាតខ្លាំងហើយទើបដើរជីកក្ដាមក្លាយជារណ្ដៅពេញស្រែ ពេញវាលយ៉ាងនេះ ហើយគ្មានស្រូវសោះ តើយើងនឹងទៅជាយ៉ាងណាទៅ?

វាលស្រែខេត្តបាត់ដំបង ជ្រកខ្លួនក្រោមព្រៃរនាម ស្រែនីមួយៗមានទំហំរាប់សិបហិកតា មានផ្ទៃដីរាបស្មើដូចថាស ហើយព័ទ្ធជុំវិញទៅដោយដំបូកដែលមានសណ្ឋានជាទួលធំៗ ប្រកបដោយដើមឈើធំៗ ខ្ពស់ៗ ស្រោងស្រាង ។ វាមានសណ្ឋានដូចៗគ្នា ដំបូកណាក៏មានដើមកកោះ ស្រឡៅ និងហ៊ុមព័ទ្ធដោយវល្លិ៍ត្រើកយ៉ាងទ្រុបទ្រុលដូចៗគ្នា ស្រែណាក៏មានដំបូកដែរ ស្រដៀងគ្នា ដូចៗគ្នា រកចំណាំពុំបានឡើយ ។ ទីនេះហើយជាទីទួលធំ ដែលបងប្អូនអាចសង់ជម្រក ដើម្បីរួមចំណែកធ្វើពលកម្មស្ដាសេដ្ឋកិច្ចជាតិយើងដែលត្រូវខ្ទេចខ្ទាំដោយសង្រ្គាមចក្រពត្តិ៥ឆ្នាំនេះ អង្គការទុកពេលឲ្យបងប្អូនសង់ជម្រក៥ថ្ងៃ ។ នៅទីនេះ បងប្អូនអាចរកកូនឈើរនាមត្រង់ៗមកសង់ខ្ទម បងប្អូនអាចច្រូតកាត់ស្បូវ ដើម្បីក្រងប្រក់ដំបូលខ្ទមបាន មានវល្លិ៍ត្រើក កន្ទ្រំបាយរី អាចធ្វើជាអាហារសម្រន់ជីវភាពបណ្ដោះអាសន្នបាន ទម្រាំអង្គការយើងដោះស្រាយខ្ចីអង្ករពីប្រទេសចិនប្រជាមានិតដែលដឹកនាំដោយលោកប្រធានម៉ៅ ដ៏មហិមាបាននឹងយកមកចែកឲ្យបងប្អូន ។

ខ្ញុំសូមពន្យល់បងប្អូនបន្ថែម ដើមឈើយុទ្ធសាស្ត្រខ្លះដែលមាននៅទីនេះ ព្រោះយើងខ្ញុំជាកងទ័ពមានពិសោធន៍មុន ក្នុងការតស៊ូរំដោះយកបងប្អូនពីចក្រពត្តិមក កងទ័ពឆ្លងកាត់ការលំបាកអត់ឃ្លានវេទនា ហាលខ្យល់ ហាលភ្លៀងយ៉ាងណាគួរតែពេលនេះបងប្អូនពុកម៉ែ មារមីង រៀនសូត្រតាមគំរូវីរភាពរបស់កងទ័ពយើង ឫសអាជៀង ក៏ដូចជាឫសរកា វាមានជាតិទឹក អាចជញ្ជក់បឺតសម្រន់បំបាត់ការស្រេកទឹកបាន ។ កាលយើងវាយលុកចូលទីក្រុងបាត់ដំបង ពេលខ្លះខ្ញុំអត់ទឹករាប់អាទិត្យ នាំគ្នាកកាយជីករកតែមើមអាជៀងនេះ ។ សូមតាមខ្ញុំមក មកមើលវាជាចំណាំ នេះជាកន្ទ្រំបាយរី ដើមវាជាវល្លិ៍តូចៗ ស្លឹកវាស្រដៀងនឹងស្លឹករកា ឬស្លឹកប្រក្រុងនេះឯង តែមើមវាធំប៉ុនកូនល្អី យើងឈូសវាឲ្យស្ដើងដូចទំពាំង រួចយកទៅស្ងោររំងាស់ជាមួយត្រួយអំពិល ឬត្រួយថ្នឹងដែលមានជាតិជូរជាច្រើនម៉ោង រួចត្រាំទឹកវា២យប់ ទើបយកមកលាយនឹងបាយ ឆ្ងាញ់ដូចមើមក្ដួចយ៉ាងនោះឯង ។ ខ្ញុំដឹងហើយថាបងប្អូនពុកម៉ែ មារមីង ទើបមកពីភ្នំពេញ ខ្លះជាសិស្ស និស្សិត មន្ត្រីសេដ្ឋី ប៉ុន្តែកិច្ចការកសាងជាតិនៅពេលនេះ ត្រូវតែអ្នកតស៊ូបដិវត្តន៍ដែលជាវណ្ណៈកម្មករ កសិករ ទើបអាចជាអ្នកដឹកនាំការងារបាន ពីព្រោះថា អ្នកមកពីភ្នំពេញអ្នកខ្លះដើរជាន់ស្រូវខ្ទេចខ្ទីអស់ ហើយស្រែកសួររកដើមស្រូវនៅឯណា? «នេះជាសេចក្ដីពន្យល់របស់បញ្ញាការយោធាម្នាក់»

រាត្រីកាលមកដល់ យើងហូបបបរលាយវល្លិ៍ត្រើកដោយពន្លឺភ្លើងភ្នក់ សន្ទឹកចចកលូ ចុក...ចូរៗៗៗ ម៉ែកូនយើងទាំង៥នាក់ប្រវាទិបគ្នា ទិ! ពេលនេះ អត្ថបទទុក្ខម្ដាយទុរគតរបស់បណ្ឌិត ប៉ាងខាត់ ក៏នៅតែមិនកម្សត់ដូចជាវាសនា៣ថ្ងៃ ក្រោយពីយើងចុះពីរថភ្លើងមកនេះទេ គ្មានបើកអង្ករមួយគ្រាប់សោះ ទឹកក៏ក្របំផុតដែរ មនុស្សប្រុសភាគច្រើនបានកើតជំងឺហត់ ទន់ជើងដើរពុំរួច សង់ខ្ទមក៏ពុំហើយ រកបេះអីហូបក៏ទៅមិនរួច ពួកគាត់ទន់ជង្គង់ដេកស្លាប់នៅនឹងកន្លែង ។ មរណភាពមនុស្សប្រុសក្នុងគ្រោះទុរភិក្សនេះ ក៏មិនប្លែកអីពីពេលសង្រ្គាមដែរ ។ ធម្មជាតិបានផ្ដល់ឲ្យស្ត្រីភេទនូវសារធាតុបម្រុងច្រើនជាង ដែលនាំឲ្យស្ត្រីអាចទ្រាំទ្រនឹងការអត់ឃ្លានបានយូរជាងបុរស ។

មកដល់ថ្ងៃទី១៣ហើយ នៃការចុះពីរថភ្លើងគ្មានបានទទួលការឧបត្ថម្ភមួយគ្រាប់សោះ យប់នេះភ្លៀងធ្លាក់មួយមេប្រកបដោយគ្រាប់ធំៗ ធ្វើឲ្យយើងរងាររឹងថ្គាម ។ ភូមិខ្លែងជួរ ស្រុកគាស់ក្រឡពីមុននោះ ដីស្រែរាំងស្ងួត ប្រេះបែកក្រហែង រកទឹកទទួលទានបានយ៉ាងពិបាក ។ ប្រជាជនជម្លៀសថ្មីនៅទីនេះ ត្រូវតែស្វែងទៅទីឆ្ងាយប្រហែលពីរគីឡូម៉ែត្រទើបជួបនឹងអូរមួយដែលមានទឹកល្អក់ខាប់ដូចខ្ទះ ។ យើងដងយកមកកូរនឹងសាជូរ ទុកឲ្យរងក្រោយពីពេលរង

ក្នុងមួយ ប៉ោតៗមានភក់ល្បាប់ពាក់កណ្តាលប៉ោត ។ ស្រាប់តែភ្លៀងធ្លាក់មួយមេ ធ្វើឲ្យទឹកហូរកាត់តាមបណ្តោយវាលរាប និងទំនាប៥យប់ ៥ថ្ងៃ ទើបអស់ ។ ភូមិសាស្ត្រនេះ ពិតជាចម្លែកមែន ។ ព្រឹកនេះភ្លៀងរាំងហើយ បញ្ហាស្វែងទៅរកដងទឹកពីទីដ៏ឆ្ងាយនោះលែងចោទទៀតហើយ អ្នកដែលនៅមានកម្លាំងខំប្រឹងដំហានអូសរាងកាយ ក៏ទ្រុឌទ្រោមទៅកាន់ព្រៃរនាមក្បែរៗនេះ ដើម្បីរកវល្លិ៍ត្រើក ជញ្ជាត់ក្តាម ឬកូនក្អុកក្អាត់ បេះយកត្រួយស្តៅ ត្រួយអំពិលមកសម្រន់ក្រពះ ។ ដើរកាត់ភូមិមួយត្រួសក៏អាចដឹងថា ភ្លៀងមួយមេយប់មិញនេះ បានធ្វើឲ្យបុរស៣នាក់ បានស្លាប់ដោយសាររងាររងើពោះ ព្រោះរាងកាយអ្នកទាំង៣ មិនអាចទប់ទល់នឹងអាកាសធាតុចម្លែកនៅក្នុងព្រៃរនាមនេះបាន ហើយនឹងមាន២នាក់ផ្សេងទៀតស្លាប់ដោយសាររាកមួល ។

បុរស និងយុវជន ចាប់ផ្តើមស្លាប់ជាបន្តបន្ទាប់ជារៀងរាល់ថ្ងៃ ។ ចំណែកឯនារី យុវនារី ដែលអាចធន់ទ្រាំបន្តជីវិតបានវែងជាងនេះ ក៏ធ្លាក់ក្នុងសភាពឈឺរ៉ាំរ៉ៃ ស្ទើរតែខ្យល់បក់រលំ ។ បុរសដែលអាចរស់រានជីវិតបាន ច្រើនតែជាអ្នកដែលមានពិសោធកិច្ចការស្រែចម្ការ អ្នកថ្នឹកនឹងការចាប់សត្វ ការឡើងដើមកកោះក្រឡាញ់ កាប់យកផ្លែចិញ្ចឹមជីវិត ។

ខ្វៃងជួរ គឺជាឈ្មោះភូមិដែលអ្នកមូលដ្ឋានរស់នៅ ចំណែកយើងប្រជាជនថ្មីត្រូវបានអង្គការដាក់ទិសឲ្យរស់នៅក្នុងវាលរនាមចម្ងាយប្រមាណ១គីឡូម៉ែត្រពីភូមិខ្វៃងជួរ ។ យើងមិនអាចចូលជិតជើងភូមិគេបានទេ គេមានវិធានការការពារភូមិយ៉ាងមាំទាំណាស់ ។ អ្នកដែលហ៊ានដើរទៅជិតភូមិនោះ នឹងត្រូវកុមារឈ្លបដែលអង្គការចាត់តាំងឲ្យយាមភូមិនោះ បង្អៅឆ្កែឲ្យដេញខាំដូចសត្វធាតុ ។ ប្រវត្តិមួយដែលមិនអាចបំភ្លេចបាន នៅខ្វៃងជួរមានគ្រួសារមួយដោយពុំអាចអត់ទ្រាំនឹងក្តីស្រេកឃ្លាន បាននាំគ្នាកាយយកសពដែលត្រូវគេយកទៅកប់ថ្មីៗ ដើម្បីវះយក ថ្លើម បេះដូងសួត មកលួចលាក់ស្ងោរហូប ការញៀនក្នុងការហូបសាច់មនុស្សធ្វើឲ្យគាត់ដាច់ចិត្តកាច់កកូនតូចរបស់គាត់ ដែលមានអាយុ១ឆ្នាំស្ងោរជាអាហារ ។ ដោយមានការតាមដានពីអង្គការជាយូរមកហើយ ជីវិតឪពុកម្តាយរូបនោះហាក់បានសន្មត់ទុកឲ្យរលត់ទៅជាមួយនឹងព្រលឹងកូនង៉ែតរបស់គាត់ ។ អង្គការបានតាមទាន់ និងបានសម្លាប់ប្តីប្រពន្ធអភ័ព្វ ដោយបន្សល់នូវកូនអាយុ៨ឆ្នាំម្នាក់ហើយក្រោយមក អង្គការបានយកទៅដាក់នៅកងចល័តកុមារ ។

រដូវវស្សាឆ្នាំ១៩៧៦ ស្នូរជួងបន្លឺឡើងពីស្នាក់ការភូមិ យុវជន យុវនារី ចេញពីកូនខ្ទមនានា លុយទឹកពីភូមិខ្វៃងជួរទៅកាន់ស្នាក់ការ ។ រាងកាយដ៏ល្ហិតល្ហៃដូចដងកណ្តុបប្រមាណ៦០នាក់ បានមកជួបជុំគ្នា យើងអង្គុយចោងហោងជាពីរជួរលើទួលដំបូកខ្ពស់មួយដែលព័ទ្ធទៅដោយជំនន់ទឹកភ្លៀងលិចពាសវាលពាសកាល ។ ដើម្បីសម្រេចទិសដូនអង្គការ បក្សយើងមានផែនការរៀបចំយុវជន យុវនារី ជាពីរកងអនុសេនាតូច ដែលមានសមាជិក៣០នាក់ ដើម្បីទៅចូលរួមលើកទំនប់ទឹកនៅភ្នំធិបតី ។ យើងត្រូវកសាងអាងទឹកសម្រាប់ធ្វើស្រូវឲ្យបាន១ឆ្នាំ៣ដង និង១ហិកតា ៣ទៅ ៦តោន ឲ្យបានដាច់ខាត ។ យុវជន យុវនារីជាទីស្នេហាទាំងអស់ ពេលនេះគឺជាពេលវេលាដ៏មានប្រយោជន៍សម្រាប់អ្នកដែលមានវាសនាខ្ពង់ខ្ពស់បានចូលរួមស្តា និងកសាងជាតិមាតុភូមិជាទីស្នេហានៃយើងដែលត្រូវឆេះខ្ទេចខ្ទីដោយសង្គ្រាមមហាចក្រពត្តិ មហាព្រៃផ្សៃមហាហ្វាស៊ីស ឲ្យមានពន្លឺរស្មីឡើងវិញ ។ មិត្តដឹងហើយចលនាប្រវត្តិសាស្ត្រកំពុងតែរីកទៅមុខ ឥតឈប់ឈរនរណាមួយដែលហ៊ានរាំងស្ទះចលនាបដិវត្តន៍នោះ ច្បាស់ជាលូកដៃដាច់ដៃ លូកជើងដាច់ជើងជាមិនខាន ។ ក្តាប់មាគ៌ាបក្សបានហើយ តើមិត្តយើងប្តេជ្ញាបានឬមិនបាន? សំណួររបស់កម្មាភិបាលមូលដ្ឋានខ្វៃងជួរ ។

ប្តេជ្ញា! ប្តេជ្ញា! ប្តេជ្ញា! នេះជាសម្រែកព្រមគ្នារបស់កងយុវជន យុវនារី អភ័ព្វល្ហិតល្ហៃ ។ ល្អណាស់ តោះចេញដំណើរតាមខ្ញុំ ។ សមមិត្តកម្មាភិបាល បានដឹកនាំដំណើរទៅកាន់ទំនប់ភ្នំធិបតី ។ មកដល់ជើងភ្នំធិបតី រូបភាពគម្រោងទំនប់ដ៏ធំល្វឹងល្វើយមានទ្រង់ទ្រាយធំហួសប្រមាណ ខ្នងលើទំហំ៤ម៉ែត្រ បាតក្រោម៨ម៉ែត្រ កម្ពស់១ម៉ែត្រ ទៅ២ម៉ែត្រ ទៅតាមភូមិសាស្ត្រដីជ្រោ ឬដីទួល ។ ពលករជញ្ជូនដីណែនណាន់តាន់តាប់ខ្មៅខ្មួលដូចជាកណ្តៀរពូនដំបូក មិនយូរប៉ុន្មាន ទំនប់ភ្នំធិបតីក៏លេចជារូបរាងលូនសណ្តូកកាត់វាលស្រែ ផុតកន្ទុយភ្នែក បង្អួតខ្លួននឹងរនាមព្រៃព្រោចដែលគោងរយើងរយោងទៅដោយវល្លិ៍ដ៏ស្រស់ខៀវខ្ចី ក្រឡេកភ្នែកមើលហ្វូងកណ្តៀរអ្នកពូនទំនប់នោះវិញ សុទ្ធតែជាមនុស្សស្គមកំព្រឹង ភ្នែករូង ស្ពក់ស្លឹង សក់ក្បាលរឹងក្រញ៉ាង កន្ទ្រើងកន្ទ្រើង មិន

ស័ក្តិសមសោះនឹងបានទទួលកិត្តិយសជាម្ចាស់នៃមាតុភូមិដែលមានប្រព័ន្ធប្រឡាយខ្វាត់ខ្វែងក្រឡាចត្រង្គជាទីស្នេហានៃយើងដូចដែលសមមិត្តបញ្ជាការយោធា និងកម្មាភិបាលបដិវត្តន៍ធ្លាប់បានលើកឡើងក្នុងអង្គប្រជុំនានានោះ ។ ឱ! ទំនប់ដីឆើតឆាយអើយ អ្នកឃើញឬទេថា ពលកររាប់រយនាក់ បានទន់ជង្គង់រហូតដួលគ្រឹបរមៀលតាមជើងទំនប់សន្លប់បាត់ស្មារតី ខ្លះទ្រាំមិនបានក៏លាចាកលោកទៅ ខ្លះរងាររញ៉េររញ៉ៃក៏ក៏នៅតែត្រូវខិតខំបំពេញតួនាទីស្ថាបនា និងរចនាលម្អអ្នករហូតដួលដេកផ្កាប់មុខក្នុងទឹកជំនន់ទឹកភ្លៀងស្លាប់បាត់បង់ជីវិតទៅក៏មាន ។ មិត្តភក្តិខ្លះដែលខំជួយត្រកងលើកអ្នកដួលឡើង ត្រូវកម្មាភិបាលបដិវត្តន៍ស្រែកគំរាមប៉ុនប៉ងធ្វើឃាតថែមទៀតក៏មាន ។ មិត្តឯងចេះដឹងអី ទុកភារកិច្ចនេះឲ្យគ្រូពេទ្យបដិវត្តន៍ មិត្តឯងគិតតែខំសម្រេចកង់ទំនប់ខ្លួនឲ្យទាន់ផែនការទៅ ។ នេះជាភាសាដែលកម្មាភិបាលបដិវត្តន៍សម័យនោះសូត្រចាំមាត់យ៉ាងពិរោះដូចសារិកាកែវវង ។

ថ្ងៃមួយ អ្នកឈឺធ្ងន់មួយចំនួន ត្រូវបានបក្សសណ្តោសប្រណីដឹកទៅកាន់មន្ទីរពេទ្យស្តៅហប់ ។ ប៉ុន្តែមន្ទីរពេទ្យហប់ គឺជាឋាននរកអវជ័យនៃលោកិយដ៏ចម្លែក ។ អ្នកជំងឺគ្រុនចាញ់រាប់សិបនាក់ដេកសន្លប់ អ្នកខ្លះញាក់ញ័ររងើ្កគ្រែដូចចាប់អង្រន់ ខ្លះខំវាចេញទៅអង្គុយអាំងថ្ងៃ ទាំងថ្ងូរហើសស្ទើរដាច់ដង្ហើម អ្នកខ្លះហើមជើងដើរពុំរួច ត្រូវបន្ទោរបង់ចោលក្រោមគ្រែឫស្សីដែលដេករួមគ្នាគំនរដេះ និងហ្វូងរុយ ព្រមទាំងសត្វដង្កូវជ្រើមរងើមពពាក់ពពូនក្នុងវង្វង់ឆ្អាបឆ្អេះយ៉ាងគ្រេកគ្រអាល ក្លិនអាសោចហោះហើរពេញបរិវេណអគារ និងមន្ទីរពេទ្យនោះស្ទើរស្ទះដង្ហើមស្លាប់ អ្នកជំងឺដេកយកក្រមាខ្ទប់ដង្ហើមជិតៗ ។ អគារខាងចុងផុតខាងនោះសម្រាប់អ្នកជំងឺហើមធ្ងន់ ដែលនៅសល់តែដង្ហើមចង្រិតដ្ដឹកៗ អ្នកជំងឺនៅទីនោះមានជាងម្ភៃនាក់ ទាំងប្រុសទាំងស្រីហើមស្លឹងៗ ខ្លួនគេមានទម្ងន់ដូចត្រូវភ្នំសង្កត់លើ កម្រើកបានទាំងពិបាកបំផុត រាងកាយអាក្រាតនទលគកដូចៗគ្នាទាំងអស់ ពោះធំកំប៉ោង សក់វែងធ្លាក់ដល់កែងជើង ទំនងជាតាំងពីចេញពីភ្នំពេញមកធ្លាក់ខ្លួនឈឺចូលមន្ទីរពេទ្យរហូតគ្មានបានកាត់សក់សោះ បានជាយ៉ាងនេះ ។ មន្ទីរពេទ្យខ្មែររំពងទៅដោយសម្រែក ស្រែករោទិ៍ថ្ងូរគ្រលួចរកញាតិសន្តាន វត្ថុស័ក្តិសិទ្ធឲ្យមកជួយ ។ ខ្មែរអើយពោរពេញដោយទុក្ខវេទនា និងសេចក្តីឈឺចាប់ ។ តើព្រាយបិសាចអ្វីកំពុងសណ្ឋិតគ្របសណ្តំអារម្មណ៍ ស្មារតីនៃយុវជន កម្មាភិបាលបដិវត្តន៍នៅទីនេះ ធ្វើឲ្យសមមិត្តយើងមិនចេះញញោចនឹងសម្រែកឈឺចាប់របស់ជនជាតិខ្លួនឯងយ៉ាងនេះ?

ឱ! ទីនេះគ្មានខុសអ្វីពីនរកភ្នែកស្រស់ទេ មានពូៗអ្នកគ្រុនញាក់ខ្លះដែលនៅដើរបាន បានខំទាំងត្រដររដើររកកកាយដីដើម្បីរកសាកសពអ្នកជំងឺដូចគ្នា ដែលទើបកប់ថ្មីៗ ហែកយកថ្លើមបេះដូងហូបឆៅ ហើយវាសនាអ្នកទាំងនោះ ត្រូវបានកម្មាភិបាលមន្ទីរពេទ្យសំពងដោយត្បូងចប រួចកប់ជាមួយនឹងសាកសពដែលខ្លួនបរិភោគនោះ ។ ការហូបសាកសពជាការចំអកនិន្ទា និងប្រមាថមើលពីចម្ងាយពីសំណាក់រៀមច្បងបដិវត្តន៍ជាអ្នក១៨ មីនា ប៉ុន្តែវាជាព្រឹត្តិការណ៍ដ៏ខ្លោចផ្សាណាស់សម្រាប់ពួកយើងប្រជាជន ១៧ មេសា ដែលរងការអត់ឃ្លានយ៉ាងដាច់សង្វែងដូចគ្នា ។ ពេលនោះយើងស្រែករកតែពុទ្ធោ ព្រះជាម្ចាស់អើយ រតនវត្ថុស័ក្តិសិទ្ធលើលោកអើយ សូមផ្តល់ឲ្យយើងនូវគ្រាប់កាំភ្លើង មួយគ្រាប់មកផ្តាច់យកសង្ខារយើងទៅ វាប្រសើរជាងរស់នៅដោយត្រូវគ្រាប់បាយដែលធ្វើឲ្យយើងរមួលឈឺផ្សាពីមួយថ្ងៃទៅមួយថ្ងៃ មួយខែទៅមួយខែ មួយឆ្នាំទៅមួយឆ្នាំ យ៉ាងសោកសង្រេងរីងរៃ ។ ប្រយោគថា ស៊ូស្លាប់ដោយត្រូវគ្រាប់បែក ប្រសើរជាងរស់នៅត្រូវគ្រាប់បាយ វាមានឥទ្ធិពល និងតក្កភាពជាក់ស្តែងណាស់នោះ គឺជាសេចក្តីឈឺចាប់នៃមនុស្សដែលត្រូវគេធ្វើឲ្យរស់ក្នុងភាពមិនមែនជាមនុស្ស ។

(តលេខក្រោយ) **អ៊ុំ ចណ្ណា**

# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ *http://d.dccam.org/Projects/Magazines/Magazine_Searching.htm* និង *truthcambodia.com* ។ ព័ត៌មានបន្ថែមសូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០ ១២ ៩៩៦ ៧៥ ០ ឬ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# ដំណើរស្វែងរកម្ដាយមីងដែលបាត់ខ្លួន

នាងខ្ញុំឈ្មោះ ហេឡែន គ្រាន បច្ចុប្បន្នរស់នៅប្រទេសអូស្ត្រាលី ។ នាងខ្ញុំបាត់ម្ដាយមីងម្នាក់ឈ្មោះ លឿង ធីក ហា ។ ម្ដាយមីងរបស់ខ្ញុំរស់នៅប្រទេសវៀតណាម ដែលមានអាសយដ្ឋាន ៤២១/៩ បេន ភូ ឡាម ទីក្រុងហូជីមិញ នៅមុនសម័យខ្មែរក្រហម ។ នៅឆ្នាំ១៩៧៤ ម្ដាយមីងរបស់ខ្ញុំ ដែលពេលនោះមានអាយុ១៨ឆ្នាំ បានមកលេងបងប្អូនដែលរស់នៅប្រទេសកម្ពុជា តែជាអកុសល ពេលរបបខ្មែរក្រហមចូលមកដល់ គាត់មិនបានវិលត្រឡប់ទៅប្រទេសវៀតណាមវិញទេ ។ បងប្អូនរបស់ម្ដាយមីងខ្ញុំនៅពេលនោះ មានផ្ទះនៅលើផ្លូវលេខ៨០ មុំសាលាយុគន្ធរ ក្រុងភ្នំពេញ ប្រទេសកម្ពុជា និងមានបើកហាងលក់គ្រឿងលម្អរ ។

នាងខ្ញុំបានភ្ជាប់មកជាមួយនូវរូបថតចំនួន៧សន្លឹក និងព័ត៌មានដែលទាក់ទងជាមួយរូបថតទាំងនេះដូចខាងក្រោម៖

◆ **រូបថតទី១**


尋人啓事
梁耀池，現居澳洲南部，現找尋：
①大妹夫：吳乃瑜及大妹：梁巧堅。外甥：、鑑江、鑑津，甥女：景芳、景芬、景珍(全住金邊市，育干托街80號)。
②妹夫：吳光華及小妹：梁慧堅(細堅)。甥女：鳳儀、靜儀
③女兒：梁淑霞，前住越南堤岸富林街421/9。(1974年曾住金邊市，解放後失去聯絡)。
如有仁人君子知其下落，請與下列地址聯絡，不勝感激，當
。

ជាសេចក្ដីប្រកាសរកម្ដាយមីងដែលបានបាត់ខ្លួន ផ្ញើរចេញពីប្រទេសអូស្ត្រាលី ទៅកាន់កាកបាទក្រហមអន្តរជាតិនៅប្រទេសកម្ពុជាពីឆ្នាំ១៩៨០ ទៅ ១៩៨២ ដើម្បីស្រាវជ្រាវរកព័ត៌មាន ។ នៅក្នុងសេចក្ដីប្រកាសនេះ មានដុកនូវអាសយដ្ឋានសាច់ញាតិដែលម្ដាយមីងខ្ញុំស្នាក់នៅ កំឡុងពេលដែលគាត់មកលេងប្រទេសកម្ពុជា និងដាក់ឈ្មោះជីតារបស់ខ្ញុំ គឺ លឿង ដែលបានប្រកាសរកម្ដាយមីងខ្ញុំ ។

◆ **រូបថតទី២**




រូបទីពីរនេះ គឺបានសរសេររៀបរាប់អំពីទីតាំងរបស់រោងកុនមួយដែលស្ថិតនៅពីមុខផ្ទះរបស់បងប្អូន និងសាច់ញាតិរបស់ម្ដាយមីងខ្ញុំនៅក្នុងប្រទេសកម្ពុជានាសម័យនោះ ។

◆ **រូបថតទី៣**



រូបថតខាងលើ បងប្អូនរបស់ខ្ញុំនៅក្រុងភ្នំពេញ ប្រទេសកម្ពុជា ដែលមីងរបស់ខ្ញុំបានមកស្នាក់នៅជាមួយ ។



◆ **រូបថតទី៤**

រូបថតទី៤នេះ គឺជារូបមីង របស់ខ្ញុំនៅពេលដែលគាត់ មានអាយុចន្លោះ ១៨ ទៅ ២០ឆ្នាំ ។ គាត់បានបាត់ខ្លួននៅ ប្រទេសកម្ពុជានៅពេលដែល គាត់មានអាយុប្រមាណជាង ២០ឆ្នាំ ។

◆ **រូបថតទី៥**

រូបថតទី៥ នេះ គឺជារូប ម្តាយរបស់ខ្ញុំដែលត្រូវជា បងស្រីបង្កើតរបស់ម្តាយមីង ដែលបានបាត់ខ្លួននៅប្រទេស កម្ពុជា នៅក្នុងអំឡុងរបបខ្មែរ ក្រហមគ្រប់គ្រង ។ ម្តាយខ្ញុំ នៅក្នុងរូបថតនេះមានអាយុ ចន្លោះ១៤-១៥ឆ្នាំ ។



◆ **រូបថតទី៦**

រូបថតទី៦ គឺជាការជួបជុំគ្រួសាររបស់ខ្ញុំ រួមមាន ជីដូនជីតា ម្តាយ មីង និង ពូ ។ រូបមីងរបស់ខ្ញុំគឺមានគូសរង្វង់នៅខាងស្តាំ ។

◆ **រូបថតទី ៧**




រូបថតទី៧ យាយតារបស់ខ្ញុំ ដែលត្រូវជា ឪពុក និង ម្តាយ របស់មីងដែលបានបាត់ខ្លួន ។

ប្រសិនបងប្អូនបានស្គាល់ម្តាយមីងខ្ញុំដូចមានរៀបរាប់ ខាងលើ សូមទំនាក់ទំនងមកនាងខ្ញុំ ហេឡែន ត្រាន តាមរយៈ អ៊ីម៉ែលៈ helen_tran@live.com និងម្តាយរបស់ខ្ញុំ លឿង ធីក ធឿង ។ សូមអរគុណ។ ដោយសេចក្តីគោរពពីខ្ញុំ **ហេឡែន**



# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់
# នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ វ៉ាន់ថាន់ ពៅដារ៉ា ទូរសព្ទលេខ ០១២ ៨៤៦ ៥២៦ ឬ អ៊ីម៉ែល ៖ truthpdara@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

*ដើម្បីយុត្តិធម៌និងការចងចាំ*
*ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ*

*ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក*
*អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩*

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
*ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨*

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 219, March 2018 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.